កំណាប់វប្បធម៌ និងតំរូវការរបស់សហគមន៍តាមរយៈរឿងនិទាន

# រឿងនិទាន និងកំណាព្យទាក់ទងនឹង

# ទន្លេមេគង្គ សេសាន សេកុង និងស្រែពក



*Folk Stories Related to the Mekong, Sesan, Sekong and Srepok Revers*

*Part. 3*

សមាគមថែរក្សាបរិស្ថាន និង វប្បធម៌
Culture and Environment Preservation Association
CEPA

ការផ្សាយរបស់សមាគមថែរក្សាបរិស្ថាន និងវប្បធម៌

ភាគទី៣

**សមាគមថែរក្សាបរិស្ថាន និង វប្បធម៌ (សេប៉ា_CEPA)** បានបង្កើតឡើងនៅឆ្នាំ ១៩៩៥ ដោយនិស្សិតមួយក្រុម ជាអង្គការមិនមែនរដ្ឋាភិបាល មិនរកកំរៃ មិនពាក់ព័ន្ធនឹងគណបក្សនយោបាយ ឬក្រុមនយោបាយណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងត្រូវបានទទួលស្គាល់ដោយក្រសួងមហាផ្ទៃនៅឆ្នាំ១៩៩៦។

**ទស្សនៈវិស័យ**

សេប៉ាប្រាថ្នាចង់បាននូវ : សង្គមឯករាជ្យមួយដែលថែរក្សាបាននូវវប្បធម៌ និងបរិស្ថានដោយធ្វើកិច្ចសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធដើម្បីធានាបាននូវការអភិវឌ្ឍប្រកបដោយនិរន្តរភាព ស្ថិរភាព និងសុវត្ថិភាពសំរាប់កូនខ្មែរជំនាន់ក្រោយ។

**គោលដៅ**

ធានាអោយបាននូវការថែទាំ និងការពារបរិស្ថាន និងធនធានធម្មជាតិក្នុងព្រះរាជាណាចក្រកម្ពុជាប្រកបដោយសមធម៌ឆ្ពោះទៅរកនិរន្តរភាពនៃការប្រើប្រាស់ និងការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ និងកូនខ្មែរជំនាន់ក្រោយ ។

**បេសកកម្មរបស់សេប៉ា គឺ**

- ធ្វើកិច្ចសហប្រតិបត្តិការជាមួយថ្នាក់មូលដ្ឋាន និងរាជរដ្ឋាភិបាលដើម្បីលើកកម្ពស់សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ប្រជាពលរដ្ឋ និងជំរុញអោយមានការការពារបរិស្ថាន និងវប្បធម៌របស់ខ្លួនតាមរយៈការស្រាវជ្រាវ ការអប់រំ ការផ្លាស់ប្តូរព័ត៏មាន-បទពិសោធន៍ និងការបណ្តុះបណ្តាលសកម្មជន។
- បង្កើននូវឱកាសសំរាប់សហគមន៍ក្នុងការលើកស្ទួយជីវភាពរបស់ពួកគាត់ និងអនុវត្តនូវគោលការណ៍សមភាព និងសមធម៌រវាងបុរស និងនារីដើម្បីធានាបាននូវការថែរក្សាព្រៃឈើ វប្បធម៌ និងការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព។
- ពង្រឹងនូវសិទ្ធិរបស់ប្រជាជនមូលដ្ឋានក្នុងការប្រើប្រាស់ និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយសមភាព និងសមធម៌។
- ជំរុញការងារបណ្តាញក្នុងការទំនាក់ទំនងជាមួយនឹងអ្នកពាក់ព័ន្ធដើម្បីធានាបាននូវសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ និងថែរក្សានូវវប្បធម៌អន្តោគ្រាម ។

**សកម្មភាព និងយុទ្ធសាស្រ្ត**

- កម្មវិធីការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព (គម្រោងសហគមន៍ព្រៃឈើ និងសហគមន៍នេសាទ)
- កម្មវិធីតស៊ូមតិដើម្បីការគ្រប់គ្រងធនធានទឹកប្រកបដោយនិរន្តរភាព (គម្រោងគ្រប់គ្រងធនធានទឹកដោយនិរន្តរភាព គម្រោងតស៊ូមតិថ្នាក់ជាតិ-អន្តរជាតិ និងគម្រោងផ្សព្វផ្សាយ និងគេហទំព័រ)
- កម្មវិធីអភិវឌ្ឍន៍ធនធានមនុស្ស (គម្រោងបណ្តុះបណ្តាលសកម្មជនបរិស្ថាន សហគមន៍ និងបុគ្គលិក)
- កម្មវិធីបន្សាំការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

## បញ្ជីរាយនាមអ្នកនិពន្ធ

លោក តឹក វណ្ណារ៉ា
លោក ពាក្យ សារ៉ែន
លោក គង់ ចាន់ធី
លោក អ៊ុំ ឱមខាន់
លោក នុត ប៊ុន
លោក ស៊ិន យឿន
លោកស្រី មុត សុភា
លោក ភេ ឈុំ
លោក យ៉េន ម៉ី
លោក ភួយ ខាំផែង
លោក គិ វ៉ាន់សៃ
លោក ខាំភន ស៊ីទុន
លោក សៃ មោង
លោក ចាន់ ចុន
លោក ស៊ីម ដាន

ម.ឯ.ឯ.ក AIDOC
Code: 137-004
Date:
Donated by:

លោក ឡុង នឹក
លោកស្រី ភឹម សុភី
លោក ញឹម សៀន
លោក ដែង ចាន់
លោក ចាន់ វ៉ាន់ឌី
លោកស្រី ចាន់ ដន
លោក សន វ៉េម
លោក មី ភី
លោក ទូន ហឿង
លោក ឡុង វ៉ាន់
លោក ព្រំ ស៊ី
លោក លៀង ចាន់
លោក គៀង វុធ
លោក ប៉ៃ ថងញ៉ុត
លោក ថុង កែវ

## កែសម្រួលអត្ថបទ និងរៀបចំ

លោក តឹក វណ្ណារ៉ា
លោក ហុង ឆាយ
ក. អ៊ឹម សុផាណារី
ក. អ៊ិត ចាន់ធឿន

## រចនាគំរូ និងថតរូប

លោក តឹក វណ្ណារ៉ា

## គណៈកម្មការត្រួតពិនិត្យ

លោក ប៊ូសារឿន
លោក ទេព ប៊ុណ្ណារិទ្ធ
លោក តឹក វណ្ណារ៉ា
លោក សម សាឯម
លោក ហាក់ វិមាន

# តារាងមាតិកា


សាររបស់លោកប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្ទឹងត្រែង.................... ៥

សាររបស់លោកអនុប្រធានមន្ទីរបរិស្ថាន និងជានាយកតំបន់រ៉ាមសារ ខេត្តស្ទឹងត្រែង ៧

សាររបស់នាយកប្រតិបត្តិសមាគមថែរក្សាបរិស្ថាន និងវប្បធម៌.......................... ៩

បុព្វកថា...........................................................................................១៣

១. មហិទ្ធិឫទ្ធិភ្នំក្រឡាពុះ..................................................................១៦

២. មហិទ្ធិឫទ្ធិភ្នំបាយឆៅ..................................................................២៥

៣. ស្រែស្រូវស្រុកលើ.......................................................................៣០

៤. ចរិតគ្រប់គ្រាន់និយម....................................................................៣៣

៥. សមុទ្រឈើ.................................................................................៣៥

៦. កោះនៅក្នុងភូមិអូររុន..................................................................៣៧

៧. អន្លង់អាចម៍ក្រពើបីពាន់.................................................................៤១

៨. ប្រវត្តិភូមិអូរស្វាយ និងព្រឹត្តិការណ៍សំខាន់ៗ.......................................៤៣

៩. អន្លង់កន្ទុយកោះ ឬអន្លង់ដើមស្វាយ...................................................៤៩

១០. ត្រពាំងក្បាលដំរី.........................................................................៥១

១១. ប្រវត្តិភូមិកោះព្នៅ.......................................................................៥៣

១២. ប្រពៃណីនេសាទត្រីរបស់អ្នកភូមិកោះព្នៅ.............................................៥៧

១៣. ប្រវត្តិភូមិកោះឈើទាលធំ និងព្រឹត្តិការណ៍សំខាន់ៗ................................៥៩

១៤. ប្រវត្តិអន្លង់ក្នុងភូមិកោះឈើទាលធំ......................................................៦៦

១៥. បង្គោលបារាំង.......................................................................................៦៩

១៦. ប្រវត្តិភូមិរ៉ុនសៀន.................................................................................៧២

១៧. អន្លង់ក្នុងភូមិរ៉ុនសៀន............................................................................៧៦

១៨. ប្រវត្តិភូមិកោះហិប.................................................................................៨០

១៩. កំពង់ឆ្កែ...............................................................................................៨៣

២០. ពូជស្រូវខ្មែរលើ......................................................................................៨៩

២១. កំណាព្យ សំលេងទឹកហូរ........................................................................៩៩

# សាររបស់លោកប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្ទឹងត្រែង

ជាបឋម ក្នុងនាមមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្ទឹងត្រែង និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមធ្វើការកោតសរសើរ និងគាំទ្រចំពោះសមាគមថែរក្សាបរិស្ថាន និងវប្បធម៌ ហៅកាត់ថា អង្គការសេប៉ា ដែលបានផ្តួចផ្តើម និងបន្តការសិក្សាស្រាវជ្រាវចងក្រងជាសៀវភៅរឿងនិទានទាក់ទងនឹងទន្លេមេគង្គ សេសាន សេកុង និងស្រែពក ភាគទី៣ នេះឡើង ដែលរឿងនិទានភាគ៣នេះ បានផ្សារភ្ជាប់ទៅនឹងទំនៀមទំលាប់ ប្រពៃណី និងការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋពឹងផ្អែកលើធនធានទឹក និងធនធានធានធម្មជាតិនៃអាងទន្លេមេគង្គ និងដៃរបស់វា ក្នុងខេត្តស្ទឹងត្រែង ។

ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកនិពន្ធទាំងអស់ ដែលបានខិតខំប្រឹងប្រែងក្នុងការតែងនិពន្ធ និងរៀបចំជាសៀវភៅនេះឡើង ក្នុងន័យចូលរួមអភិវឌ្ឍន៍សង្គម ការពារបរិស្ថាន អភិរក្ស អភិវឌ្ឍន៍វប្បធម៌ និងថែរក្សាវប្បធម៌អន្ដោគ្រាមដែលមាននៅក្នុងទឹកដីខេត្តស្ទឹងត្រែង ។

តាមទស្សនៈរបស់ខ្ញុំ ខ្ញុំមានជំនឿថា សៀវភៅរឿងនិទាននេះ ពិតជាមាន-សារៈប្រយោជន៍ក្នុងការអភិរក្ស និងអភិវឌ្ឍន៍ឡើងវិញនូវអត្តសញ្ញាណ និងព្រលឹងវប្បធម៌របស់ជនអន្ដោគ្រាម និងប្រជាជនដែលកំពុងមានវត្តមានរស់នៅតាមបណ្តោយដងទន្លេមេគង្គ សេសាន សេកុង និងស្រែពកនៃខេត្តស្ទឹងត្រែង ដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍សង្គមជាតិ ។ នេះជាការចូលរួមចំណែកដ៏សំខាន់ក្នុងការកសាងឯកសារបេតិកភណ្ឌវប្បធម៌អរូបី ដែលបានកើតឡើងតាំងពីអតីតកាល និងជាគ្រឹះដ៏រឹងមាំ

ឈានទៅធ្វើការអភិវឌ្ឍន៍វប្បធម៌ និងអត្តសញ្ញាណជាតិឱ្យបានរីកចំរើនជឿនលឿន ដើម្បីបំពេញបន្ថែមតាមតំរូវការរបស់ប្រិយមិត្តអ្នកអាន និងអ្នកដែលស្នេហាវិស័យវប្បធម៌ផងដែរ ។

ជាទីបញ្ចប់ ខ្ញុំសូមគោរពជូនពរចំពោះ បុគ្គលិកទាំងអស់នៃសមាគមថែរក្សាបរិស្ថាន និងវប្បធម៌ អ្នកនិពន្ធទាំងអស់ សាធារណៈជន មហាជន និងប្រជាពលរដ្ឋគ្រប់រូប ដែលរស់នៅលើទឹកដីអង្គរដ៏បវរនៃយើង សូមឱ្យមានសុខភាពដ៏ល្អបរិបូរណ៍ ទទួលបាននូវពុទ្ធិពរទាំងប្រាំប្រការគឺ : អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈកុំបីឃ្លៀងឃ្លាតឡើយ ។

សូមឱ្យតំលៃវប្បធម៌ខ្មែរស្ថិតនៅក្នុងបេះដូង និងដួងព្រលឹងរបស់ប្រជាជនខ្មែរគ្រប់រូបជានិច្ចនិរន្តន៍ ! វប្បធម៌រលត់ជាតិរលាយ វប្បធម៌ពណ្ណរាយជាតិថ្កើងថ្កាន!!!

ធ្វើនៅស្ទឹងត្រែង, ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៨

**សម សាឯម**

# សាររបស់លោកនាយកតំបន់រ៉ាមសារ
# និងជាអនុប្រធានមន្ទីរបរិស្ថាន ខេត្តស្ទឹងត្រែង

តាងនាមឱ្យប្រជាជននៅក្នុងតំបន់រ៉ាមសារ និងក្នុងនាមជានាយកតំបន់រ៉ាមសារ និងជាអនុប្រធានមន្ទីរបរិស្ថាន ខេត្តស្ទឹងត្រែង ខ្ញុំសូមសំដែងនូវការកោតសរសើរយ៉ាងជ្រាលជ្រៅចំពោះសមាគមថែរក្សាបរិស្ថាន និងវប្បធម៌ (សេប៉ា) ដែលបានសហការល្អ និងខិតខំចូលរួមចំណែកយ៉ាងសកម្មក្នុងកិច្ចការពារធនធានធម្មជាតិនៅក្នុងតំបន់រ៉ាមសារ ខេត្តស្ទឹងត្រែង តាមរយៈការជួយសម្របសម្រួលរៀបចំជាសហគមន៍ព្រៃឈើ សហគមន៍នេសាទ សហគមន៍គ្រប់គ្រងធនធានទឹក និងគំរោងសិក្សាស្រាវជ្រាវដោយអ្នកភូមិ។ គំរោងទាំងនោះ បានដើរតួយ៉ាងសំខាន់សំរាប់លើកស្ទួយជីវភាពរស់នៅរបស់ប្រជាជន និងធ្វើផែនការគ្រប់គ្រងដើម្បីធ្វើការការពារអភិរក្សជីវៈចំរុះ និងការប្រើប្រាស់ធនធានឱ្យមាននិរន្តរភាពទាំងពេលបច្ចុប្បន្ន និងសំរាប់អនាគត។ ជាមួយគ្នានេះដែរ សេប៉ា បានផ្តួចផ្តើម និងបន្តស្រាវជ្រាវចងក្រងជាសៀវភៅរឿងនិទានទាក់ទងនឹងទន្លេមេគង្គ សេសាន សេកុង និងស្រែពកជាបន្តបន្ទាប់ ដើម្បីបង្ហាញប្រាប់ប្រជាជនឱ្យដឹងពីប្រវត្តិនៃភូមិនីមួយៗ កោះនីមួយៗ និងតំបន់នីមួយៗ និងស្គាល់តំលៃធនធានធម្មជាតិដ៏មហាសាលដែលកំពុងមានវត្តមាននៅក្នុងតំបន់រ៉ាមសារ ខេត្តស្ទឹងត្រែង។ តា មរយៈសៀវភៅរឿងនិទាន គឺជាការលើកតំលៃ និងកិត្តិយសតំបន់រ៉ាមសារនៅកំរិតថ្នាក់មូលដ្ឋាន ជាតិ តំបន់ និងអន្តរជាតិ ដើម្បីចូលរួមចំណែកក្នុងការអភិរក្ស និងអភិវឌ្ឍន៍តំបន់រ៉ាមសារ ខេត្តស្ទឹងត្រែងឱ្យមាននិរន្តរភាព។

ជាការពិត ស្ទើរគ្រប់រឿងនិទានដែលមាននៅក្នុងសៀវភៅរឿងនិទានទាក់ទងនឹងទន្លេមេគង្គ សេសាន សេកុង និងស្រែពកភាគ៣នេះគឺបានបង្ហាញពីតំបន់

រ៉ាមសារ ទន្លេមេគង្គលើខេត្តស្ទឹងត្រែង ដែលមានទីតាំងស្ថិតនៅតាមបណ្ដោយដងទន្លេមេគង្គខាងជើងទីរួមខេត្តស្ទឹងត្រែងចម្ងាយ៥គីឡូម៉ែត្រ រហូតដល់ព្រំប្រទល់ប្រទេសឡាវ មានផ្ទៃដីសរុបចំនួន១៤៦០០ហិកតា។ កោះចំនួន៤០នៅក្នុងតំបន់រ៉ាមសារ ភាគច្រើនសុទ្ធតែភូមិ និងចំការរបស់ប្រជាពលរដ្ឋ ដែលរួមមាន៤ឃុំ គឺ ឃុំសាមគ្គី ក្នុងស្រុកស្ទឹងត្រែង, ឃុំកោះស្នែង, ឃុំអូរស្វាយ, ឃុំព្រះរំកិល ក្នុងស្រុកថាឡាបរិវ៉ាត់ ហើយមានភូមិចំនួន២១ជាចំនុះ ដែលមានប្រជាពលរដ្ឋប្រមាណ១២.០០០នាក់ ស្មើនឹង២២៨៥គ្រួសាររស់នៅ ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមគាំទ្រយ៉ាងពេញទំហឹង និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកនិពន្ធទាំងអស់ ដែលបានខិតខំសរសេរ និងចក្រងជាសៀវភៅរឿងនិទានដ៏មានសារៈសំខាន់នេះឡើង ក្នុងន័យចូលរួមចំណែកចែករំលែកចំណេះដឹងដល់ប្រជាជនខ្មែរទាំងមូល និងចូលរួមក្នុងកិច្ចការអភិរក្ស និងអភិវឌ្ឍន៍តំបន់រ៉ាមសារឱ្យមាននិរន្តរភាព។ ជាមួយគ្នានេះ ខ្ញុំក៏សូមធ្វើការកោតសរសើរផងដែរដល់អាជ្ញាធរ និងប្រជាពលរដ្ឋក្នុងមូលដ្ឋាន ដែលបានខិតខំស្រាវជ្រាវរំលឹកអំពីព្រឹត្តិការណ៍រឿងរ៉ាវតំណាលនានា ដែលទាក់ទងនឹងរឿងនិទានទាំងនេះជូនដល់ក្រុមអ្នកនិពន្ធ ដើម្បីធ្វើការចងក្រង ។

ជាទីបញ្ចប់ ខ្ញុំសូមគោរពជូនពរដល់អ្នកនិពន្ធទាំងអស់ បុគ្គលិកសមាគមថែរក្សាបរិស្ថាន និងវប្បធម៌ និងប្រជាជនខ្មែរទាំងអស់ សូមប្រកបដោយសុខភាពល្អ ជោគជ័យ និងសិរីមង្គលគ្រប់ប្រការជានិច្ចនិរន្តរ៍ ។

ធ្វើនៅស្ទឹងត្រែង, ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៨

**ហាក់ ទិមាន**

# សាររបស់នាយកប្រតិបត្តិសមាគមថែរក្សាបរិស្ថាន និងវប្បធម៌

សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ មានការប្តេជ្ញាខ្ពស់ក្នុងការចូលរួមចំណែកថែទាំ ការពារបរិស្ថាន និងការ ប្រើប្រាស់ប្រកបដោយសមភាព និងសមធម៌នៃធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីឆ្ពោះទៅរកការអភិវឌ្ឍដែលមានតុល្យភាពរវាងបរិស្ថាន សង្គម និងសេដ្ឋកិច្ច។ ដើម្បីឱ្យបានសំរេចតាមការប្តេជ្ញានេះ យើងមានបេសកកម្មដូចខាងក្រោម :

- ធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្រប់ផ្នែក និងស្ថាប័ននៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ដើម្បីលើកកម្ពស់សិទ្ធិ សេដ្ឋកិច្ច សង្គមរបស់ប្រជាពលរដ្ឋ ដោយការជំរុញឱ្យមានការការពារបរិស្ថាន និងវប្បធម៌តាមរយៈការស្រាវជ្រាវ ការអប់រំ ការផ្លាស់ប្តូរព័ត៌មាន បទពិសោធន៍ និងវគ្គបណ្តុះបណ្តាលសកម្មជនបរិស្ថាន។
- បង្កើននូវឱកាសរបស់សហគមន៍ក្នុងការលើកស្ទួយជីវភាពរបស់ខ្លួន ព្រមទាំងជំរុញឱ្យមានសមភាព និងសមធម៌រវាងបុរស និងស្ត្រី ដើម្បីធានានូវការថែរក្សាប្រពៃណីវប្បធម៌ យុត្តិធម៌សង្គម និងការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព។
- ពង្រឹង និងលើកកម្ពស់នូវសិទ្ធិរបស់ប្រជាជនមូលដ្ឋាន ក្នុងការប្រើប្រាស់ និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយសមភាព និងសមធម៌។
- ជំរុញការងារបណ្តាញក្នុងការងារទំនាក់ទំនងជាមួយនឹងអ្នកពាក់ព័ន្ធនានា ដើម្បីបង្កើននូវការយល់ដឹងអំពីសង្គម និងការថែរក្សានូវវប្បធម៌អន្លោគ្រោម។

ដើម្បីសំរេចបាននូវគោលដៅរបស់ខ្លួន សមាគថែរក្សាបរិស្ថាន និងវប្បធម៌

(CEPA) យើងមានកម្មវិធីយុទ្ធសាស្ត្របួនគឺ ៖

- **កម្មវិធីចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព ៖** គឺជាកម្មវិធីដែលបង្កើននូវសមត្ថភាពរបស់សហគមន៍មូលដ្ឋាន ក្នុងការប្រើប្រាស់ និងគ្រប់គ្រងធនធានជលផល ព្រៃឈើ ដីធ្លី និងអភិវឌ្ឍន៍សហគមន៍ទេសចរណ៍ធម្មជាតិក្នុងគោលបំណងរកប្រាក់ចំណូលប្រកបដោយសមភាព សមធម៌ និងនិរន្តរភាព។
- **កម្មវិធីតស៊ូមតិ ដើម្បីគ្រប់គ្រងធនធានទឹកដោយនិរន្តរភាព ៖** គឺជាកម្មវិធីដែលបញ្ចុះបញ្ចូលដើម្បីស្វែងរកការគាំទ្រសំលេង និងសិទ្ធិរបស់ពលរដ្ឋ ដោយសង្កត់ធ្ងន់លើការបង្កើនការយល់ដឹង និងបំប៉នសមត្ថភាព ដល់ប្រជាពលរដ្ឋ និងសហគមន៍ជនជាតិដើមភាគតិច ដែលទទួលរងផលប៉ះពាល់អវិជ្ជមានពីគំរោងការអភិវឌ្ឍនានាក្នុងអាងទន្លេមេគង្គ។
- **កម្មវិធីអភិវឌ្ឍន៍ធនធានមនុស្ស ៖** គឺជាកម្មវិធីដែលបង្កើននូវចំណេះដឹង និងជំនាញដល់និស្សិត និងសហគមន៍។
- **កម្មវិធីបន្សាំបំរែបំរួលអាកាសធាតុ និងកាត់បន្ថយគ្រោះមហន្តរាយ ៖** ដើម្បីឱ្យប្រជាជនដែលងាយរងគ្រោះ ពីគ្រោះមហន្តរាយទឹកជំនន់ទាំង១០ភូមិ ដែលកំពុងរស់នៅតាមដងទន្លេសេសាន ស្រុកវើនសៃ ក្នុងខេត្តរតនគិរី អាចកាត់បន្ថយនូវហានិភ័យគ្រោះទឹកជំនន់ តាមរយៈសកម្មភាពបន្សាំ និងកាត់បន្ថយគ្រោះមហន្តរាយដោយប្រើយន្តការសហគមន៍។

ដើម្បីបង្កើនការយល់ដឹងដល់សហគមន៍មូលដ្ឋាន មន្ត្រីរដ្ឋាភិបាល បុគ្គលិកអង្គការ-មិនមែនរដ្ឋាភិបាល និងប្រជាជនកម្ពុជាអំពីចំណេះដឹង និងបទពិសោធន៍នៃការ

ប្រែប្រួលបរិយាកាស ដែលធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធជីវចម្រុះ បរិស្ថាន និងជីវភាពរស់នៅរបស់ប្រជាជន ជាពិសេសសង្កត់ធ្ងន់ទៅលើរបៀបនៃការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ តាមរយៈការរៀបចំកិច្ចពិភាក្សាក្នុងកម្មវិធីវិទ្យុ វេទិកា កិច្ចប្រជុំ និងសិក្ខាសាលាជាមួយនឹងអ្នកពាក់ព័ន្ធនានា។

ឆ្លើយតបទៅនឹងគោលដៅ បេសកម្ម និងកម្មវិធីខាងលើ ខ្ញុំសូមស្វាគមន៍ចំពោះការបន្តចងក្រងជាសៀវភៅរឿងនិទានទាក់ទងនឹងទន្លេមេគង្គ សេសាន សេកុង និងស្រែពកភាគ៣នេះឡើង ដែលរឿងទាំងនេះផ្សាភ្ជាប់ទៅនឹងទំនៀមទំលាប់ប្រពៃណី និងការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋតាមដងទន្លេមេគង្គ និងដៃរបស់វាជាពិសេសនៅក្នុងតំបន់រ៉ាមសារ ខេត្តស្ទឹងត្រែង។

ជាមួយគ្នានេះដែរ តាមទស្សនៈរបស់ខ្ញុំ សៀវភៅនេះ បានចូលរួមចំណែកផ្តល់ចំណេះដឹងដល់ប្រិយមិត្តអ្នកអានទាំងអស់ ដើម្បីយល់កាន់តែច្បាស់ពីប្រវត្តិសង្គមវប្បធម៌ សេដ្ឋកិច្ចគ្រួសារ និងការគ្រប់គ្រងធនធានធម្មជាតិរបស់ប្រជាពលរដ្ឋដែលកំពុងរស់នៅតាមដងទន្លេមេគង្គ សេសាន សេកុង និង ស្រែពកផងដែរ ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកនិពន្ធទាំងអស់នៃសមាគមថែរក្សាបរិស្ថាន និងវប្បធម៌ និងប្រជាពលរដ្ឋដែលកំពុងរស់នៅតាមដងទន្លេមេគង្គ សេសាន សេកុង និងស្រែពក ដែលបានខិតខំប្រឹងប្រែងក្នុងការតែងនិពន្ធជាសៀវភៅនេះឡើង ក្នុងន័យចូលរួមថែរក្សា ស្តារ និងអភិវឌ្ឍន៍សង្គមវប្បធម៌ ការពារបរិស្ថាន និងវប្បធម៌អន្តោប្រាណ។ តាងនាមឱ្យសេប៉ា (CEPA) និងខ្លួនខ្ញុំផ្ទាល់ សូមសរសើរដោយស្មោះ ចំពោះការបន្តស្មារតីរួបរួមគ្នា និងបង្កើតសមិទ្ធផលដ៏មានអត្ថប្រយោជន៍ចំពោះប្រិយមិត្តអ្នកអានទាំងអស់ និងប្រជាពលរដ្ឋកម្ពុជាយើង។

ជាថ្មីម្តងទៀត ក្នុងនាមនាយកប្រតិបត្តិសមាគមថែរក្សាបរិស្ថាន និងវប្បធម៌ ខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះម្ចាស់មូលនិធិ FORUMSYD, OXFAM AMERICA, SWEDISH SOCIETY FOR NATURE CONCERVATION រាជរដ្ឋាភិបាល និងគ្រប់ស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិ ចំពោះការគាំទ្រគ្រប់បែបយ៉ាងដល់សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ (CEPA) ក្នុងការឈានទៅសំរេចទស្សនៈវិស័យដ៏យូរអង្វែងរបស់សមាគម និងសូមថ្លែងអំណរគុណយ៉ាងពិសេសចំពោះក្រុមអ្នកនិពន្ធ និងគណៈកម្មការត្រួតពិនិត្យ ដែលចំណាយពេលវេលា និងកម្លាំងកាយចិត្ត ព្រមទាំងប្រាជ្ញាធ្វើឱ្យសមិទ្ធផលដ៏ពិសិដ្ឋនេះកើតឡើងសំរាប់ប្រិយមិត្តអ្នកអានទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាយើង ។



**ទេព ប៊ុណ្ណារិទ្ធ**

នាយកប្រតិបត្តិ

សមាគមថែរក្សាបរិស្ថាន និងវប្បធម៌

# បុព្វកថា

ជីវភាពរស់នៅរបស់ប្រជាជនក្នុងខេត្តស្ទឹងត្រែងដោយពឹងផ្អែកលើធនធានធម្មជាតិ គឺជាវប្បធម៌ដែលមានតាំងពីយូរលង់ណាស់មកហើយ។ តាមរយៈវប្បធម៌ទាំងនេះ បានឆ្លុះបញ្ចាំងពីតថភាពសង្គមក្នុងអតីតកាល និងបច្ចុប្បន្នកាល ហើយវាក៏ជាកត្តាសំរាប់វាស់វែង និងចង្អុលបង្ហាញសំរាប់អនាគតកាលផងដែរ។

ដើម្បីធ្វើការអភិវឌ្ឍឱ្យចំទិសដៅ និងឆ្លើយតបទៅនឹងតំរូវការចាំបាច់របស់ប្រជាជន យើងចាំបាច់ត្រូវតែយល់ដឹងឱ្យកាន់តែស៊ីជម្រៅទៅលើសង្គមវប្បធម៌នៃសហគមន៍នីមួយៗមុននឹងយើងចាប់ផ្តើមគំរោងអភិវឌ្ឍន៍ទៅកាន់តំបន់ណាមួយដើម្បីលើកកំពស់កំរិតជីវភាពរស់នៅរបស់ប្រជាជននៅក្នុងសហគមន៍នោះ។

តាមទស្សនទាននេះ រឿងនិទាន ទំនៀមទំលាប់ ប្រពៃណី វប្បធម៌ ដែលបានកើតឡើង និងកំពុងកើតឡើងតាមដងទន្លេមេគង្គ សេសាន សេកុង និងស្រែពក ដែលជាតំបន់សំបូរដោយធនធានធម្មជាតិ ក៏ជាសូចនករមួយសំរាប់ធ្វើការវាស់វែង និងធ្វើ-ការឆ្លុះបញ្ចាំងអំពីបែបផែននៃការអភិវឌ្ឍនាពេលអតីតកាល បច្ចុប្បន្នកាល និងសំរាប់អនាគតផងដែរ។ វាពិតជាមានសារៈសំខាន់ណាស់ សំរាប់ធ្វើការប្រៀបធៀបចំពោះការអភិវឌ្ឍនាពេលកន្លងមក និងស្វែងរកកត្តាគន្លឹះសំខាន់ៗ ដែលជាយន្តការជួយឱ្យមានការអភិរក្ស និងអភិវឌ្ឍន៍ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ទាំងពេលបច្ចុប្បន្ន និងអនាគត។

បញ្ហាទាំងនេះ សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ បានមើលឃើញយ៉ាងច្បាស់ និងបានកំពុងយកចិត្តទុកដាក់ចំពោះបំណងថែរក្សាវប្បធម៌អន្តោគ្រាម និងការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ ដែលអាចឆ្លើយតបទៅនឹងតំរូវការពិត

ប្រាកដរបស់សហគមន៍ និងប្រជាជនក្រីក្រ។ ដើម្បីសំរេចបានគោលបំណងទាំងនេះ សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ ហៅកាត់ថា សេប៉ា បានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការប្រមូលចងក្រងជាឯកសារផ្សេងៗដូចជា សៀវភៅរឿងនិទាន ទំនៀមទំលាប់ប្រពៃណី ដែលទាក់ទងនឹងប្រជាជន និងជនអន្តោគ្រាមតាមដងទន្លេមេគង្គ សេសាន សេកុង និងស្រែពកភាគ៣នេះឡើង ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសហគមន៍ ការគ្រប់គ្រងធនធានធម្មជាតិក្នុងតំបន់ទាំងនោះប្រកបដោយនិរន្តរភាពក្នុងការលើកកម្ពស់ជីវភាពរស់នៅទាំងមនុស្សជំនាន់បច្ចុប្បន្ន និងជំនាន់ក្រោយ។

សៀវភៅនេះ ផ្តោតទៅលើវប្បធម៌អន្តោគ្រាម សង្គមវប្បធម៌ និងការចិញ្ចឹមជីវិតរបស់សហគមន៍ដោយពឹងផ្អែកទៅលើធនធានធម្មជាតិ។ ទន្ទឹមនឹងនេះដែរ តាម-រយៈរឿងនិទានដែលមាននៅក្នុងសៀវភៅនេះ ក៏ជាការចូលរួមចំណែកក្នុងការបង្កើនចំណេះដឹង បង្កើនភាពជឿទុកចិត្តគ្នាក្នុងសង្គម ការគ្រប់គ្រងថែរក្សាវប្បធម៌ និងធនធានធម្មជាតិ ក្នុងការគាំទ្រចំពោះការអភិវឌ្ឍប្រកបដោយនិរន្តរភាព យុត្តិធម៌សង្គម សមធម៌ និងសមភាព។



**តឹក វណ្ណារ៉ា**

មន្ត្រីគ្រប់គ្រងកម្មវិធីទំនាក់ទំនង និងស្រាវជ្រាវ

សមាគមថែរក្សាបរិស្ថាន និងវប្បធម៌

# *Preface*

*Livelihood depend on natural resources of people living in Stung Treng Province is a culture that has been happened in many centuries previous. Through these cultures show the social reality in the past, present and its indicates for the future development perspective.*

*To develop with the good future direction and response to the needs of the people, we need to understand deeply on socio-culture of each community before we starting to develop projects to which areas for improving community liveli-hood.*

*Through this view, folk stories, traditional culture, modernize culture were happened and happening on the Mekong, SeSan, Sekong and Srepok Rivers are indicates to show how to develop in the past, present and the future. It is for comparing to previous development and find the keys important mechanisms in order to ensure sustainable natural resources management in present time and in the future.*

*Culture and Environment Preservation Association (CEPA) seem very clearly on these issues and has strong commitment in objective to preserve indigenous cul-ture and community based natural resources management which can response to the needs of community and poor people.*

*To achieve these objectives, Culture and Environment Preservation Association (CEPA) has been collected information to build documents such as* ***folk stories and poem*** *related to the people and indigenous people living along Mekong, SeSan, Sekong and Srepok Rivers part 3 to participate in sustainable community development, natural resources management in order to improve livelihood of people in present time and in the future.*

*The book focus on indigenous culture, socio-culture and livelihood of community people depend on natural resources. Through these stories have been wrote in this book is a contribution to build knowledge and increasing belief in the society, cultural resources management and natural resources management in order to support sustainable development, social justice, equity and equality.*

# ១. មហិទ្ធិឫទ្ធិភ្នំក្រឡាពុះ

## ១. ស្ថានភាពទូទៅ

ភ្នំក្រឡាពុះស្ថិតនៅទឹកដីភូមិក្រឡាពុះ ឃុំតាឡាត ស្រុកសេសាន ខេត្តស្ទឹងត្រែង ដែលមានចម្ងាយប្រមាណជា ២០ គីឡូម៉ែត្រ ពីភូមិ និងមានព្រំប្រទល់ជាប់នឹងស្រុកសៀមប៉ាង។ ប្រសិនបើយើងធ្វើដំណើរដោយថ្មើរជើងឡើងលើភ្នំនេះ គឺត្រូវចំណាយពេលជាងមួយម៉ោងកន្លះ ទើបទៅដល់កំពូល ។ ភ្នំនេះសំបូរទៅដោយធនធានធម្មជាតិចំរុះ ដូចជា ព្រៃឈើធំៗខ្ពស់ៗ សត្វព្រៃគ្រប់ប្រភេទ ។ ដោយសារមហិទ្ធិឫទ្ធិរបស់ភ្នំក្រឡាពុះនេះ ធ្វើឱ្យធនធានធម្មជាតិទាំងនោះនៅមានតរៀងមក ។ ជាឧទាហរណ៍ សត្វអាចគេចផុតពីដៃព្រាន ដោយមហិទ្ធិឫទ្ធិភ្នំជួយបិទបាំងពីភ្នែកព្រាន ឬធ្វើឱ្យព្រានបាញ់ខុស ។ នៅទីនោះ ក៏មានអូរមួយហូរចេញពីភ្នំដែរ ។ អូរនោះមានឈ្មោះថា អូរក្រឡាពុះ ហើយមានទឹកហូរជាប់ជាប្រចាំ (ទឹកច្រប់) ចេញពីភ្នំ។ ប្រជាពលរដ្ឋចំនួន៦ភូមិដែលមកពីស្រុកចំនួនពីរ គឺស្រុកសៀមប៉ាង និងស្រុកសេសាន បានទៅរកអនុផលព្រៃឈើនៅទីនោះជាប្រចាំ។

## ២. ផលប្រយោជន៍នៃធនធាននៅភ្នំក្រឡាពុះ

ប្រជាជនយើងជាច្រើនតំណមកហើយតែងតែទៅរកផល និងអនុផលព្រៃឈើនៅភ្នំក្រឡាពុះ ដូចជា ជ័រស្អុង ជ័រទឹក ផ្លែសំរ៉ង ស្លែង ព្រមទាំងធនធានផ្សេងៗទៀតដែលមាននៅទីនោះ។

មានប្រជាជនជាច្រើនភូមិ ដែលបានចូលទៅរកធនធានដើម្បីចិញ្ចឹមគ្រួសារនៅភ្នំក្រឡាពុះ ដូចជា ភូមិខ្សាច់ថ្មី ភូមិស្វាយរៀង ភូមិក្រឡាពុះ ឃុំតាឡាត ស្រុក

សេសាន និងភូមិបានហួយ ភូមិដនទ្បូង ជាពិសេសជនជាតិលន់ ដែលគេចូលចិត្ត រស់នៅតាមតំបន់ព្រៃក្រាស់ៗ ស្រុកសៀមប៉ាង។ ប្រជាពលរដ្ឋទាំងនេះមានទំលាប់ពឹង ផ្អែកទៅលើធនធានធម្មជាតិនៅលើភ្នំនេះតាំងពីដូនតាមកម្ល៉េះ។ នៅពេលចូលទៅរក ផល និងអនុផលព្រៃឈើនៅទីនោះ ប្រជាពលរដ្ឋតែងតែបែរបន់សុំសេចក្តីសុខ និងទៅ រកធនធានទាំងនោះឱ្យបានច្រើន ។ នៅពេលទៅដល់ទីនោះគឺត្រូវប្រយ័ត្នមាត់ប្រយ័ត្ន កផងដែរ ព្រោះនៅទីនោះមានតំណមច្រើនណាស់ បើនិយាយខុសមាត់គឺមានបញ្ហា កើតឡើងភ្លាមតែម្តង ដូចជាធ្វើអោយរកអ្វីៗមិនបាន លុះត្រឡប់មកផ្ទះវិញក៏វង្វេង ផ្លូវ ។ល។ ហើយលក្ខណៈបែបនេះ គឺនៅមានរហូតមកដល់សព្វថ្ងៃនេះ។

## ៣. ព្រឹត្តិការណ៍ពិសេសៗ

### ត្រីអណ្តែង

យោងតាមប្រសាសន៍លោកអ៊ុំ**ហា ខង** ជាទីប្រឹក្សាសហគមន៍ធនធានទឹក នៅ ភូមិស្រែគរ១បានបញ្ជាក់អោយដឹងថាគាត់ជាអ្នកធ្លាប់បានដើរទៅរកធនធាន និងដើរ ទៅជាមួយព្រានព្រៃដើម្បីបរបាញ់សត្វព្រៃកាលពីឆ្នាំ១៩៨០ ដល់ ១៩៩០ នៅតាមអូរ ក្រឡាពុះសំបូរត្រីណាស់ ជាពិសេសត្រីអណ្តែង ។ ការចាប់ត្រីអណ្តែងមកហូបក៏ត្រូវ មានតំណមដែរ ។ ឧទាហរណ៍ បើយើងមានគ្នាចំនួន៣នាក់ យើងស្ទូចត្រីបានតែ៣-៤ ក្បាល សំរាប់តែហូបមួយចម្អែតប៉ុណ្ណោះ គឺមិនអោយយើងយកច្រើនទេ បើចង់បាន លើសពីនោះ គឺមិនបានជាដាច់ខាត ហើយត្រីទាំងនេះប្រសិនបើយកមកផ្ទះក៏យក មិនបានដែរ គឺវាអាចធ្វើអោយអ្នកយកមកនោះវង្វេងពេញព្រៃរកផ្លូវមកផ្ទះវិញមិន- ឃើញ។ បើចង់រកផ្លូវមកផ្ទះវិញឃើញ ត្រូវហូបត្រីឱ្យអស់នៅទីនោះ ឬបោះចោលនៅ ក្នុងព្រៃនោះវិញ។

## ដុំមាស

តាមប្រសាសន៍ លោកអ៊ុំ ហា ខង បានអោយដឹងថានៅតាមអូរ តាមចង្អេះៗ និងលើកំពូលភ្នំក្រឡាពុះ យើងមើលទៅឃើញមាសស្នេកស្កុះនៅទីនោះ រងិបរងុបដូចអាចម៍ជន្លេន យើងអាចរើសកាន់ពិនិត្យមើលបាន មិនមានបញ្ហាអ្វីទេ តែបើយើងយកមាសនោះមកផ្ទះ គឺមិនបានទេ គឺធ្វើអោយយើងវង្វេង។ មានមនុស្សបីនាក់ គាត់មានបំណងចង់បានមាសទាំងនោះមកប្រើប្រាស់ ដោយគាត់ប្រើវិធីសាស្ត្រដាំបាយដំណើបយកទៅហូបនៅទីនោះ។ នៅពេលធ្វើដំណើរដល់ទីនោះ អ្នកទាំងបីបាននាំគ្នាហូបបាយនៅទីនោះ ពេលនោះគាត់ទាំងបីនាក់ប្រើល្បិចកល ដោយពូតដុំបាយដំណើបជាមួយនឹងដុំមាស រួចហើយអោយឆ្កែវាលេបបាយនោះចូលទៅក្នុងពោះជាច្រើនដុំ បន្ទាប់ពីនោះគាត់ទាំងអស់គ្នាក៏នាំគ្នាត្រឡប់មកផ្ទះវិញ ។ នៅពេលធ្វើដំណើរត្រឡប់មកវិញ គាត់បានកាប់មែកឈើចំណាំពីកន្លែងដែលចាប់ផ្តើមចេញដំណើរនោះ។ គាត់ទាំងអស់គ្នាបាននាំគ្នា ដើរចុះឡើងៗក៏មកដល់កន្លែងដែលគាត់បានដាក់ចំណាំនោះដដែល។ ម្នាក់ៗមិនអស់ចិត្តក៏ចាប់ដើរបន្តទៀត រហូតទាល់តែអស់បាយអស់ទឹកគ្រប់ៗគ្នា ហើយទាល់តែឆ្កែដែលលេបបាយដំណើបជាមួយនឹងដុំមាសនោះជុះអាចមិចេញមកវិញអស់ទើបអ្នកទាំងអស់គ្នាឈប់វង្វេង និងរកផ្លូវមកផ្ទះវិញបាន។

រឿងមួយទៀត ដោយអ្នកទាំងនេះមានបំណងចង់យកឈ្នះ គេក៏នាំគ្នាយកខ្សែអំបោះសទៅចងចាប់ពីច្រកចូលភ្នំរហូតដល់ចំណុចដុំមាស រួចក៏នាំគ្នារើសមាសនោះយកមកផ្ទះក៏នាំគ្នាដើរតាមខ្សែអំបោះមកផ្ទះវិញ លុះដើរចុះ ដើរឡើងក៏មកដល់កន្លែងដើមវិញ ( កន្លែងរើសមាស ) ដើរម្តងហើយម្តងទៀត នៅតែរកច្រកចេញមិនឃើញក៏នាំគ្នាយកមាសទៅទុកកន្លែងដើមវិញ ហើយដើរចេញតាមខ្សែអំបោះដែលចងនោះវិញ ក៏បានរកផ្លូវឃើញមកផ្ទះវិញ ។

លោក **ចាន់ ថុន** ប្រធានសហគមន៍ធនធានទឹកភូមិស្រែគរ១ មានប្រសាសន៍ថា មានតាចាស់ម្នាក់ គាត់ដើរទៅភ្នំក្រឡាពុះ ដោយកាន់ឈើច្រត់ដើម្បីការពារខ្លួន ហើយឈើច្រត់នោះនៅខាងចុងវាមានរន្ធប៉ុនមេដៃ ហើយនៅពេលគាត់ដើរកាត់ចំណុចមាស គឺឈើច្រត់គាត់បានបុកចំៗដុំមាសអោយមាសចូលក្នុងរន្ធឈើច្រត់ លោកតានោះគាត់មានល្បិចខ្ពស់ធ្វើបែបជាមិនដឹងរឿងថា ឈើច្រត់ដែលគាត់កាន់នោះត្រូវបានមាសចូលក្នុងរន្ធទេ ចរិតគាត់ធ្វើជាដើរកាត់ធម្មតា ។ ដោយមហិទ្ធិឫទ្ធិភ្នំនេះខ្លាំង ធ្វើអោយគាត់ដើរចុះឡើងៗដោយរកច្រកចេញមិនឃើញវង្វេងនៅលើភ្នំនោះ ។ នៅពេលតាដឹងខ្លួនថាគាត់វង្វេង ហើយក៏សូមទោសអ្នកតា រួចលើកឈើច្រត់គោះនឹងថ្មអោយមាសជាប់នោះជ្រុះចេញវិញអស់ទើបគាត់អាចរកផ្លូវឃើញ ។

ចំណែកឯនៅលើកំពូលភ្នំ លោកអ៊ុំ ហា ខង បានរៀបរាប់អោយដឹងទៀតថា មានគងមាស ដើមចេក ដើមល្ហុង ដើមម្ទេស ដើមខ្នុរ និងដើមថ្នាំជក់នៅទីនោះ ប៉ុន្តែលោកបានបញ្ជាក់ថា របស់របរ និងដំណាំទាំងនោះ ពេលខ្លះក៏ឃើញ ហើយពេលខ្លះទៀតមើលមិនឃើញពេលដែលយើងឡើងទៅទីនោះ ។

**មាន់គក** ( មាន់ឈ្មោល)

លោក **ចាន់ ថុន :** បានតំណាលរឿងតពីលោកតា សួយ ហឿន ក្រុមប្រឹក្សាឃុំបាននិយាយថា កាលពីមុនមានមាន់គកមួយក្បាលរងាវនៅពេលយប់ លុះដល់ព្រឹកឡើងអ្នកនោះក៏បានដើរទៅមើលកន្លែងមាន់រងាវនោះស្រាប់តែឃើញមាន់មាសមួយធំប៉ុនមាន់គកយើង។ នៅពេលដែលឃើញដូចនេះគាត់ ( អ្នកជួប) ចាប់អារម្មណ៍ និងស្រឡាញ់មាន់នោះយ៉ាងខ្លាំង ហើយគាត់បានកាន់អង្អែលមាន់នោះលេងធម្មតា លុះថ្ងៃក្រោយមក ដោយគាត់ចង់ទៅមើលមាន់នោះទៀតស្រាប់តែមិនឃើញ មិនដឹងជាទៅ

ទីណាបាត់តាំងពីនោះមករហូតមកដល់បច្ចុប្បន្ននេះ ពុំដែលមានអ្នកណាម្នាក់បានឃើញ មាន់នោះទៀតទេ ។

## រូបចម្លាក់គោ

**លោកជា វ៉ាន់នី** :នៅក្នុងឆ្នាំ១៩៥៨ កាលពីជំនាន់ចិន ទៅធ្វើរ៉ែត្បូងថ្មនៅចំណុច ភូមិតាឡាត គាត់បានដើរទៅរកធនធាននៅភ្នំក្រឡាពុះនេះ ស្រាប់តែបានឃើញ ចម្លាក់គោមួយប៉ុនសត្វគោធម្មតាធ្វើពីថ្ម បែរមុខទៅទិសខាងកើតនៅចំណុចកណ្ដាល បាតអូរ តាំងពីពេលនោះរហូតមកដល់បច្ចុប្បន្ននេះ រូបគោនោះពុំដឹងជាទៅណាបាត់ទេ ដោយពុំដែលឮថាមានអ្នកបានជួបទេ ។

## រូងភ្នំ

លោក **បៃ ថងញ៉ុត** ប្រធានសហគមន៍ធនធានទឹក ភូមិស្វាយរៀងបានផ្ដល់ព័ត៌មានបន្ថែមថា នៅចំណុចភ្នំក្រឡាពុះមានរូងភ្នំមួយទំហំជិត២ម៉ែត្រ មានកំពស់ផុតក្បាល ហើយរូងភ្នំនេះគឺតាមដែលគាត់ដឹងគឺមិនដែលមាននរណាម្នាក់ហ៊ានចូលទេ ។ រូងនេះមានសភាពងងឹតឈឹងយើងមិនអាចមើលអ្វីឃើញទេ ។

## ប្រវត្តិគងមាស

គងមាសស្ថិតនៅលើកំពូលភ្នំក្រឡាពុះ កាលពីជំនាន់បារាំង គេធ្លាប់បានប្រើប្រាស់ឧបករណ៍ទំនើបដើម្បីយកគងមាសនោះ ដោយគេប្រើកៅឡាក់ស្ទូចយក ។ ក្រុមអ្នកស្ទូច បានស្ទូចវាឡើងបន្តិចម្ដងៗ លុះជិតមកដល់លើ ទីដែលអ្នកទាំងអស់គ្នា អាចឃើញគងនោះ ក្រុមស្ទូចត្រេកអរពន់ពេកក៏នាំគ្នាហៅយ៉ាងទ្រហឹងអឹងកងដោយម្នាក់ៗ

គិតថាបានជោគជ័យ លុះបន្ទាប់មកគងនោះ ក៏ស្រាប់តែដាច់ធ្លាក់ជ្រុះទៅវិញបាត់ស្រមោលតែម្តងដោយគ្មានមូលហេតុ។ តាំងពីពេលនោះមក គងមាសនេះ លែងដែលបង្ហាញខ្លួនអោយនរណាម្នាក់បានឃើញទៀតទេ រហូតមកដល់សព្វថ្ងៃនេះ ។

## ដើមម្ទេស និងដើមថ្នាំជក់

**ដើមម្ទេស** មានទំហំធំមុខកាត់ប្រហែលជាងមួយម៉ែត្រ កម្ពស់ប្រហែល ១៥ ម៉ែត្រមានមែកត្រសុំសាខាផ្តល់ម្លប់ត្រឈឹងត្រឈៃ អ្នកដែលបានទៅដល់ដើមម្ទេសនោះ តែងតែសរសើរថាអស្ចារ្យណាស់ និងបេះផ្លែរបស់វាហូបជាមួយបាយសម្លដ៏មានឱជារស។ រសជាតិរបស់វាហិរដូចម្ទេសនៅស្រុកយើងដែរ ។ បើនិយាយពីអាយុកាលរបស់ដើមម្ទេសវិញ គឺអ្នកដែលនៅជាចាស់ទុំនៅក្នុងភូមិបានប្រាប់ថា គាត់កើតមកឮថាមានដើមម្ទេសនៅលើភ្នំនេះហើយ តែបើតាមការស្មានប្រហែលជា ២០០ឆ្នាំ (ពុំមានព័ត៌មានជាក់លាក់ទេ) ។

## ដើមថ្នាំជក់

មានទំហំមុខកាត់ជាងមួយម៉ែត្រ មានកម្ពស់ប្រហែល ១៦ម៉ែត្រ មានមែកដូចដើមម្ទេសដែរ ស្លឹករបស់វាយើងអាចបេះបាន ហើយជក់នៅទីនោះ រសជាតិរបស់វាដូចគ្នានឹងថ្នាំរបស់យើងដាំដែរ។ ចំណែកឯអាយុកាលរបស់ដើមថ្នាំជក់វិញ គឺអ្នកដែលនៅជាចាស់ទុំនៅក្នុងភូមិបានប្រាប់ថា គាត់កើតមកឮថាមានដើម ថ្នាំជក់នៅលើភ្នំនេះតរៀងមក មិនខុសពីដើមម្ទេសទេ តែបើតាមការស្មានប្រហែលជា១៩០ឆ្នាំ ឯអ្នកខ្លះទៀតនិយាយថា មានអាយុប្រហាក់ប្រហែលគ្នា ។

## ថ្មស៊ីដែក

កាលពីជំនាន់ប៉ុលពតក្នុងឆ្នាំ១៩៧៧-១៩៧៨ មានទាហានជនជាតិគ្រឹង៥ ទៅ៦នាក់ បានទៅបរបាញ់សត្វនៅទីនោះ នៅពេលពួកគាត់អស់កម្លាំង ក៏នាំគ្នាឈប់សំរាកនៅលើថ្មមួយផ្ទាំងធំទំហំ៣ម៉ែត្រដែលមានផ្ទៃរាប។ ឃើញដូចនេះ អ្នកដើរបរបាញ់ក៏នាំគ្នាទុកកាំភ្លើងនៅលើថ្ម ហើយនាំគ្នាដេកសំរាកនៅលើថ្មនោះ។ មួយសន្ទុះក្រោយមក អ្នកទាំងអស់គ្នាក៏បបួលគ្នាបន្តដំណើរតទៅទៀត តែនៅពេលដែលទៅចាប់កាំភ្លើងដើម្បីបន្តដំណើរ ស្រាប់តែកាំភ្លើងបានផុយអស់ក្លាយទៅជាផេះអស់សល់តែស្នូក ដែលធ្វើអំពីឈើប៉ុណ្ណោះទើបនាំគ្នាឆ្ងល់ហើយគិតថា ប្រហែលជាខ្មោចលង ឬអ្នកតាព្រៃភ្នំខឹងទើបធ្វើដូចនេះ តែមិនចាប់អារម្មណ៍ថា មានថ្មស៊ីដែកនោះទេ។ លុះមកដល់សម័យរដ្ឋកម្ពុជា ទើបដឹងថាមានថ្មស៊ីដែក ហើយបាននាំគ្នាទៅរកមើលកន្លែងផ្ទាំងថ្មធំនោះ តែរកមិនឃើញទេដោយអ្នកតាព្រៃភ្នំ ដែលមានមហិទ្ធឫទ្ធិលាក់កំបាំងបាត់មិនអោយជនដែលមានគំនិតខិលខូចយកបាននោះទេ។ ព័ត៌មានទាក់ទងនឹងថ្មស៊ីដែក ទើបតែលេចឮនៅឆ្នាំ១៩៩៥-១៩៩៦នេះទេ ហើយក៏យករឿងដែលកើតមាននៅលើភ្នំក្រឡាពុះនោះមកសន្និដ្ឋានថា មានថ្មស៊ីដែកនៅលើភ្នំនោះតែម្តងទៅ នៅមិនទាន់មានព័ត៌មានច្បាស់ការណ៍នៅឡើយ។

## ធាតុជំនាន់ដើម

នៅជើងភ្នំក្រឡាពុះ ចុងអូរកាកាល ខាងកើត មានធាតុមួយទំហំ៤ម៉ែត្រគុណនឹង៤ ហើយមានកម្ពស់៧ម៉ែត្រ។ ធាតុនេះមិនដឹងជាសង់នៅសតវត្សណាទេ។ នៅខាងមុខច្រកចូលមានរូបចម្លាក់មនុស្សពីរនាក់ឈរអមច្រកចូលទៅរកធាតុ ហើយមានខ្លោងទ្វារ និងទ្វារចាក់សោជាប់ទំហំប៉ុនកជើង ហើយសោនោះមិនអាច

ចាក់ ឬ វាយវាបានទេ ។ នៅក្នុងធាតុនោះមិនដែលមានអ្នកណាម្នាក់ហ៊ានចូលទៅដល់ទេ ដោយម្នាក់ៗមានអារម្មណ៍ភ័យខ្លាច ។ នៅជិតធាតុនេះ មានវាលស្មៅមួយគ្មានដើមឈើទេ តែមានថ្មមួយដុំយ៉ាងធំ និងមានកម្ពស់ប្រវែង១០ម៉ែត្រ ដែលបាំងធាតុនោះមិនអោយយើងមើលឃើញ ។ នៅឆ្នាំ១៩៩៨ អ្នកនៅភូមិហាតប៉ក់ ស្រុកវ៉ឺនសៃ ខេត្តរតនគិរី មានបំណងចង់ទៅរកធាតុនោះក្នុងគោលបំណងចង់យកអ្វីៗនៅក្នុងនោះ តែពេលដែលទៅរកគឺរកមិនឃើញឡើយ ។

ចំពោះប្រវត្តិនៃធាតុនេះ យើងមិនបានដឹងពីប្រវត្តិច្បាស់លាស់ទេ តាមរយៈអ្នកភូមិបានដឹងតែមួយផ្នែកតូចនៃស្ថានភាពខាងក្រៅតែប៉ុណ្ណោះ ជាពិសេសគ្រាន់តែដឹងថា បើអ្នកណាម្នាក់មានបំណងអាក្រក់ចង់បានអ្វីៗនៅក្នុងធាតុនោះ ឬចង់ទៅជីកគាស់កកាយ មានអ្នកតា ឬអ្នកសច្ចំបំបាំងមិនអោយរកឃើញធាតុនោះទេ ។ ប៉ុន្តែប្រសិនបើអ្នកដែលមិនធ្លាប់ដឹងពីប្រវត្តិ ឬមិនដឹងថាទីនោះមានធាតុទេ នៅពេលដែលគេដើរទៅដល់ទីនោះ គឺគេអោយយើងមើលឃើញតែម្តង ហើយនៅពេលដែលឃើញ គេហាក់ដូចជាមានអារម្មណ៍ប្លែក និងបង្កប់ទៅដោយចម្ងល់ជាច្រើន ។

ទាក់ទងនឹងរឿងរ៉ាវនៃភ្នំក្រឡាពុះខាងលើនេះ គឺមិនបានក្បោះក្បាយឡើយ ដោយអ្នកដែលដឹងច្បាស់ពីប្រវត្តិទាំងនេះ គាត់បានស្លាប់បាត់អស់ទៅហើយ ឯរឿងរ៉ាវបរិយាយនេះគ្រាន់តែជាផ្នែកតិចតួចដែលមនុស្សជំនាន់ក្រោយបានជួបប្រទះតរៀងមក ។ តែចាស់ទុំជំនាន់ដើមបានបន្សល់នូវពាក្យសំដីខ្លះៗថា ប្រសិនបើយើងចង់បានអ្វីៗ ដែលនៅក្នុងភ្នំក្រឡាពុះនេះបានដូចបំណង ដូចជា ផ្លែឈើ ត្រី ថ្មស៊ីដែក មាស ។ល។ ទៅប្រើប្រាស់លុះត្រាតែយកសត្វជើងពីរ (សំដៅលើមនុស្ស) ទៅប្តូរទើបគេព្រមអោយរបស់ទាំងនោះមកប្រើប្រាស់បាន ហើយក៏ត្រូវធ្វើពិធីបែរបន់សែន

ព្រៃនផងដែរ ឯមនុស្សដែលយកទៅជំនួសនេះ ក្រោយពីពិធីសែនព្រៃនចប់ មនុស្សក៏បាត់ស្រមោលភ្លាមតែម្តង។ តាំងពីមុនរហូតមកដល់បច្ចុប្បន្ននេះ ពុំដែលមាននរណាម្នាក់ធ្វើដូច្នេះទេ ព្រោះថានេះជាសំដីត១គ្នាពីបុរាណកាលមក ។

សព្វថ្ងៃនៅភ្នំក្រឡាពុះអ្វី១ដែលមានពីមុនមក គឺនៅសេសសល់ទាំងអស់ ដោយគ្មាននរណាម្នាក់យកអ្វីបាននោះទេ ព្រោះថាអ្វី១ទាំងនេះសុទ្ធសឹងតែមានម្ចាស់ថែរក្សា ដោយយើងមើលមិនឃើញ ហើយអ្វី១ដែលធ្លាប់មើលឃើញសព្វថ្ងៃគឺ កម្រនឹងបានឃើញណាស់ ។[១]

---

[១] ប្រវត្តិ និងនិទាននានាទាក់ទងនឹងភ្នំក្រឡាពុះ វាគ្រាន់តែជារឿងនិទានប៉ុណ្ណោះ ដែលប្រជាជននៅក្នុងតំបន់នោះ ចេះចាំ និងនិទានតគ្នាពីមាត់មួយទៅមាត់មួយ ពីភូមិមួយទៅភូមិមួយ និងពីតំបន់មួយទៅតំបន់មួយ ដើម្បីចែករំលែកព័ត៌មាន និងសំរាប់កែកំសាន្តបំបាត់ការអផ្សុក ក្រោយពីការបង្កបង្កើនផលរួច។



ចងក្រងដោយ : លោក ពាក្យ សារឿន
មន្ត្រីគំរោងសហគមន៍គ្រប់គ្រងធនធានទឹក
នៃសមាគមថែរក្សាបរិស្ថាន និងវប្បធម៌
ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៨



ប្រភពព័ត៌មាន : លោក ចាន់ ថុន លោក ប៉ៃ ថងញ៉ិត ប្រធានភូមិស្រែគរ១ និងលោក ស៊ឹម ដាន សហគមន៍គ្រប់គ្រងធនធានទឹក ភូមិស្វាយរៀង

## ២. មហិទ្ធិឫទ្ធិភ្នំបាយឆៅ

កាលពីដើមឡើយមានតំណាលថា មានអ្នកសច្ចំមួយក្រុម បានមកកាន់សីល នៅលើភ្នំមួយនៅក្នុងខេត្តមណ្ឌលគិរី ។ ក្នុងកំឡុងពេលកាន់សីលនោះ អ្នកសច្ចំទាំងអស់បានយករូងភ្នំធ្វើជាទីជម្រក និងជំរាលភ្នំ ជាកន្លែងសំរាប់ដាំដុះដំណាំកសិកម្ម ក្នុងការផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃ។ ពីមួយថ្ងៃទៅមួយថ្ងៃ បុណ្យបារមីរបស់ក្រុមអ្នកសច្ចំកាន់តែមានមហិទ្ធិឫទ្ធិខ្លាំងអស្ចារ្យ ដោយចេះជប់ជាបាយ ជាសម្ល និងអាហារផ្សេងៗដ៏មានឱជារស។ ដើម្បីសម្តែងមហិទ្ធិឫទ្ធិរបស់ខ្លួន ក្រុមអ្នកសច្ចំបានសំរេចថា ចាប់ពីនេះតទៅ យើងនឹងផ្តល់ជាផ្លែឈើគ្រប់ប្រភេទដល់មនុស្ស និងសត្វទាំងឡាយ ដែលធ្វើដំណើរឆ្លងកាត់ និងមកពឹងអាស្រ័យនៅភ្នំនេះ ដោយមិនចាំបាច់ឱ្យពួកគេដាំបាយ និងចំអិនអាហារនៅទីនេះទេ ព្រោះថា ការចំអិនអាហារ មានដូចជាបាយសម្ល និងម្ហូបផ្សេងៗនាំឱ្យមានបាបកម្ម និងដាច់សីលរបស់ពួកយើង ព្រោះមនុស្ស ឬអ្នកធ្វើដំណើរនឹងបាញ់សម្លាប់សត្វនៅភ្នំនេះ សំរាប់ធ្វើជាអាហារ ជាពិសេសការដាំបាយ និងធ្វើឱ្យឆេះព្រៃ និងស្មៅ ដែលទង្វើទាំងនេះ បណ្តាលឱ្យមានបាបកម្មដល់ការតាំងសីលរបស់ពួកយើង។ ដើម្បីកុំឱ្យមានបាបកម្ម អ្នកសច្ចំទាំងនោះ បានដាក់វិន័យថា បើមនុស្សទាំងឡាយណា ដែលធ្វើដំណើរឆ្លងកាត់ភ្នំនេះ ឬអ្នកមកស្នាក់នៅភ្នំនេះ មានបំណងដាំបាយ ឬដាំបាយសំរាប់ហូបជាអាហារ សូមឱ្យបាយរបស់គេដាំនោះក្លាយទៅជាបាយឆៅទាំងអស់។ ទន្ទឹមនឹងនេះ យើងនឹងឱ្យពួកគេ ឃើញចំការម្នាស់ ចំការល្ហុង ចំការក្រូច និងចំការបឺរ ដើម្បីឱ្យពួកគេហូបផ្លែឈើទាំងនេះជំនួសបាយវិញ ដើម្បីកុំឱ្យមនុស្សទាំងនោះប្រព្រឹត្តអំពើបាបដើម្បីចំអែតក្រពះ។

ចាប់តាំងពីការដាក់វិន័យរបស់អ្នកសច្ចំពីពេលនោះមក អ្នកដំណើរឆ្លងកាត់ និងស្នាក់នៅលើភ្នំនោះ ពុំដែលបានដាំបាយឆ្អិនសំរាប់បរិភោគទេ។ ពួកគេត្រូវចូលទៅរកចំការម្ចាស់ ខ្ទរ ក្រូច និងបឺរ ដើម្បីបេះផ្លែឈើទាំងនោះ យកមកបរិភោគជំនួសបាយវិញ។ អ្នកដំណើរណា ដែលនិយាយច្រើន និងប្រព្រឹត្តអំពើមិនល្អនៅលើភ្នំបាយឆៅ គឺពួកគេមិនអាចមើលឃើញចំការផ្លែឈើទាំងនោះ។ ដូច្នេះរាល់អ្នកដំណើរ ដែលធ្វើដំណើរឆ្លងកាត់ និងស្នាក់នៅបណ្តោះអាសន្ននៅលើភ្នំបាយឆៅ តែងតែតមពាក្យសំដី និងប្រព្រឹត្តអំពើល្អ ដោយមិនបៀតបៀនជីវិតសត្វព្រៃ មិនជេរគ្នាផ្តេសផ្តាស ក្នុងកំឡុងពេលពួកគេឆ្លងកាត់ និងស្នាក់នៅលើភ្នំបាយឆៅ។

ទន្ទឹមនឹងនេះ ក៏មានអ្នកដំណើរមិនតិចដែរ ចង់សាកមើលមហិទ្ធិឫទ្ធិរបស់អ្នកសច្ចំនៅលើភ្នំនេះ ដោយពួកគេតែងតែនាំគ្នាធ្វើការបង្កាត់ភ្លើងដាំបាយ និងស្ល នៅពេលដែលគេស្នាក់នៅលើភ្នំ ប៉ុន្តែការសាកល្បងរបស់គេពុំបានទទួលជោគជ័យទេ គឺបាយដែលគេដាំជាច្រើនដងនោះនៅតែឆៅ និងសម្លមិនឆ្អិន ហើយអាហារដែលចំអិនទាំងនោះមិនអាចយកមកបរិភោគបានទេ។

កត្តាស័ក្តិសិទ្ធិទាំងនេះ បានជំរុញឱ្យអ្នកខេត្តមណ្ឌលគិរី ដែលភាគច្រើនជាបងប្អូនជនជាតិដើមភាគតិចនោះ មានជំនឿខ្លាំង និងមានការគោរពយ៉ាងខ្ជាប់ខ្ជួនចំពោះភ្នំបាយឆៅដោយគេអះអាងថា ព្រលឹងរបស់អ្នកសច្ចំ និងដូនតារបស់គេ កំពុងសណ្ឋិតនៅលើភ្នំបាយឆៅនៅឡើយ ។

ភ្នំបាយឆៅ មានទីតាំងនៅជាប់ផ្លូវទៅកាន់ទីរួមស្រុក កោះញែក ។ ប្រសិនបើយើងធ្វើដំណើរតាមរថយន្តឈ្នួលពីខេត្តមណ្ឌលគិរី ទៅកាន់ភ្នំបាយឆៅ គឺចំណាយពេលប្រមាណ៤៥នាទី។

បច្ចុប្បន្ន មហិទ្ធិឫទ្ធិទាំងនោះ ពុំសូវមានភាពស័ក្តិសិទ្ធិដូចពីដើមទេ ដោយ

សារការវិវត្តនៃសង្គម ការបំផ្លាញព្រៃឈើ និងកត្តាបច្ចេកវិទ្យាខ្ពស់ៗ បានហូរចូលទៅកាន់ខេត្តមណ្ឌលគិរី និងភ្នំបាយឆៅយ៉ាងគគ្រឹកគគ្រេង ដែលនាំឱ្យជំនឿតាំងពីជំនាន់ដើមនោះ សាបរលាបបន្តិចម្តងៗ។ ទោះជាយ៉ាងណាក៏ដោយ ក៏បងប្អូនជនជាតិដើមភាគតិចនៅតែគោរពចំពោះតំណមនេះដដែលរហូតមកដល់ពេលបច្ចុប្បន្ននេះ។



ទិដ្ឋភាពភ្នំបាយឆៅ មើលពីចំងាយ

ស្រាវជ្រាវ និងសរសេរដោយ : លោក តឹក វណ្ណារ៉ា
មន្ត្រីគ្រប់គ្រងកម្មវិធីទំនាក់ទំនង និងស្រាវជ្រាវ
នៃសមាគមថែរក្សាបរិស្ថាន និងវប្បធម៌
មណ្ឌលគិរី, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៨



អម្តកស្រែស្រូវ និងផ្ទះស្រែរបស់អ្នកស្រុកលើ (ភូមិលុន ឃុំ សេកុង ស្រុកសៀមប៉ាង)



ចំការស្រូវ និងដំណាំពហុចំរុះរបស់អ្នកស្រុកលើ (ភូមិលុន ឃុំសេកុង)



ចំការពនេចរ និងដើមឈើច្បោះរបស់បងប្អូនជនជាតិដើមភាគតិច



## ៣. ស្រែស្រូវអ្នកស្រុកលើ

អ្នកស្រុកលើសំដៅទៅលើអ្នកស្រុកទាំងឡាយណាដែលរស់នៅខ្សែទឹកខាងលើ (សំរាប់ប្រជាជនដែលរស់នៅតាមដងទន្លេ) និងអ្នកដែលរស់នៅតំបន់ភ្នំ និងខ្ពង់រាបនៃប្រទេសកម្ពុជាយើង។ ស្រែ និងស្រូវរបស់អ្នកស្រុកលើ មានលក្ខណៈប្លែកពីស្រែ និងស្រូវរបស់អ្នកស្រុកក្រោម (តំបន់ទំនាបកណ្ដាល វាលទំនាប និងតំបន់ដីសើម) ទាំងពូជ និងលក្ខណៈរបស់វាលស្រែ និងការធ្វើស្រែជាដើម។

ស្រែរបស់អ្នកស្រុកលើភាគច្រើនជាស្រែ និងចំការដែលស្ថិតនៅចន្លោះតំបន់ព្រៃឈើ និងព្រៃរិចរិល។ ស្រែពុំមានលក្ខណៈរាបស្មើមានផ្ទៃដីជាច្រើនហិកតាតជាប់គ្នាដូចវាលស្រែនៅតំបន់ទំនាបកណ្ដាលនោះទេ គឺស្រែមានទំហំតូចៗ តជាប់គ្នារដឹកដោយមានដើមឈើ និងដំបូកជាច្រើនដុះនៅតាមភ្លឺស្រែ និងជាយស្រែ បង្កើតបានជាប្រព័ន្ធជីវចំរុះវាលស្រែបែបធម្មជាតិយ៉ាងល្អប្រណីត ហើយប្រព័ន្ធជីវៈចំរុះបានផ្ដល់អត្ថប្រយោជន៍ជាច្រើនសំរាប់ជួយបង្កើនជីជាតិដីស្រែឱ្យកាន់តែល្អ និងទទួលបានទិន្នផលច្រើនទៀតផង។ ស្រែនីមួយៗមានទទឹងប្រមាណពី៥-១០ម៉ែត្រ និងបណ្ដោយពី១៥-២០ម៉ែត្រ ហើយមានស្ថានភាពដីខ្ពស់ទាបខុសៗគ្នា ។ ដោយសារស្ថានភាពនេះធ្វើឱ្យម្ចាស់ស្រែលើកជាភ្លឺសំរាប់ទប់ទឹកឱ្យដក់ជាប់នៅក្នុងស្រែសំរាប់ផ្គត់ផ្គង់ដំណាំស្រូវរបស់ពួកគាត់។ តាមភ្លឺស្រែនីមួយៗមានស្មៅជាច្រើនប្រភេទដុះតជាប់គ្នា អមដោយអាចម៍ជន្លេនជាច្រើន ដែលបញ្ជាក់ថា ដីស្រែទាំងនោះ ជាដីប្រភេទដីមានគុណភាពល្អ និងជីជាតិខ្ពស់។ នៅក្នុងកូនស្រែនីមួយៗ មានដើមស្រូវលាយឡំជាមួយនឹងទងស្មៅមួយៗ ដែលបង្ហាញថា ស្រែស្រូវទាំងនោះ គឺធ្វើឡើងដោយការប្រើប្រាស់



ស្ថានភាពផ្ទះស្រែ
និងអម្ពកស្រែស្រូវ
របស់អ្នកស្រុកលើ
នៃភូមិលុន
ឃុំ សេកុង
ស្រុកសៀមប៉ាង
ខេត្តស្ទឹងត្រែង

កម្លាំងពលកម្មរបស់មនុស្ស ដើម្បីដាំស្រូវ និងថែទាំស្រូវ។

គ្រួសារនីមួយៗនៅតាមដងទន្លេសេសាន សេកុង ស្រែពក និងមេគង្គ មានស្រែពី៣០ទៅ៦០អម្ពក អាស្រ័យទៅតាមគ្រួសារនោះ មានសមាជិកច្រើន ឬតិចក្នុងការរានដីព្រៃធ្វើជាស្រែ-ចំការ។ គ្រួសារដែលមានសមាជិកច្រើនរានដីបានច្រើន រីឯគ្រួសារដែលមានសមាជិកតិចរានដីបានតិចទៅតាមកម្លាំង និងសមត្ថភាព ទៅតាម-គ្រួសារនីមួយៗ។

ជាធម្មតា សំរាប់អ្នកស្រុកលើ ពួកគាត់មានផ្ទះពីរ គឺផ្ទះនៅក្នុងភូមិ និងផ្ទះស្រែ។ ជាទូទៅអ្នកភូមិបានចាកចេញពីភូមិ (ផ្ទះក្នុងភូមិ) នៅខែមិថុនា ជារៀងរាល់ឆ្នាំ ដើម្បីទៅរស់នៅផ្ទះស្រែ (ផ្ទះខាងក្រៅភូមិ : ផ្ទះស្រែ) ដោយចាប់ផ្តើមប្រកបមុខរបរធ្វើស្រែ-ចំការនៅលើដីអម្ពកស្រែរបស់ពួកគាត់។ ការចាកចេញទៅនៅផ្ទះស្រែនេះ ពួកគាត់បានយកទ្រព្យសម្បត្តិ និងរបស់របរដែលពួកគាត់មានទៅជាមួយដើម្បីយកទៅទុកនៅផ្ទះស្រែរបស់ពួកគាត់។ ទ្រព្យសម្បត្តិទាំងនោះមានដូចជា គោក្របី ជ្រូក មាន់ ទា និងរបស់របរសំរាប់ធ្វើកសិកម្មជាដើម។

យ៉ាងយូរខែកុម្ភៈជារៀងរាល់ឆ្នាំ   អ្នកស្រុកលើតែងតែត្រឡប់មកផ្ទះក្នុងភូមិវិញ ក្រោយពីប្រមូលផលស្រូវ និងដំណាំផ្សេងៗរួចរាល់។ ការផ្លាស់ប្តូរនេះ  អ្នកស្រុកលើ បានដឹកស្រូវ និងផលទទួលបានពីកសិកម្មដែលពួកគាត់ធ្វើអស់រយៈពេល៦ទៅ៨ខែក្នុង រដូវវស្សានាពេលកន្លងមក។

ស្រូវដែលអ្នកស្រុកលើធ្វើមានបីប្រភេទ គឺប្រភេទស្រូវស្រាល ស្រូវកណ្តាល និងស្រូវធ្ងន់។ ស្រូវស្រាលមានដូចជា ស្រូវដនឡាយ និងស្រូវកានកួយជាដើម ហើយ ស្រូវកណ្តាលមានដូចជា ស្រូវភូម៉ា និងស្រូវធ្ងន់មានដូចជា ស្រូវផ្កាចារជាដើម។

ស្រូវស្រាល  និងស្រូវកណ្តាល  ដែលអ្នកស្រុកលើធ្វើ  ភាគច្រើនជាពូជ ស្រូវដំណើប ដែលអាចទទួលបានផលក្នុងរយៈពេលពី៣ទៅ៤ខែ។ ការធ្វើស្រូវស្រាល និងស្រូវកណ្តាល គឺដើម្បីយកផលមកបរិភោគឱ្យទាន់ខែដែលអ្នកស្រុកអស់ស្រូវហូបគឺ ចាប់ពីចុងខែកញ្ញា  ដល់ខែធ្នូជារៀងរាល់ឆ្នាំ  រង់ចាំទំរាំដល់ពេលទទួលផលពី ប្រភេទស្រូវធ្ងន់  ដែលជាប្រភេទស្រូវដែលទទួលបានទិន្នផលខ្ពស់សំរាប់ការផ្គត់ផ្គង់ លើជីវភាពរស់នៅប្រចាំថ្ងៃ។

អ្នកស្រុកលើ  ដាំស្រូវស្រាល  និងស្រូវកណ្តាលប្រមាណពី៥ទៅ៨អម្តក ប៉ុណ្ណោះ ក្នុងមួយគ្រួសារ ក្រៅពីនេះ ពួកគាត់ដាំប្រភេទស្រូវធ្ងន់ទាំងអស់។

ប្រពៃណីការរស់នៅផ្ទះពីរនេះ នៅតែបន្តរហូតមកទល់សព្វថ្ងៃនេះ។



ស្រាវជ្រាវ និងសរសេរដោយ : លោក តឹក វណ្ណារ៉ា
មន្ត្រីគ្រប់គ្រងកម្មវិធីទំនាក់ទំនង និងស្រាវជ្រាវ
នៃសមាគមថែរក្សាបរិស្ថាន និងវប្បធម៌
ភូមិលុន ឃុំសេកុង ស្រុក សៀមប៉ាង ខេត្តស្ទឹងត្រែង
ថ្ងៃទី ២៧ ខែ សីហា  ឆ្នាំ ២០០៨

## ៤. ចរិតគ្រប់គ្រាន់និយម

**ចរិត**គ្រប់គ្រាន់និយម ឯករាជ្យនិយម សេរីភាពនិយម គឺជាចរិតមួយរបស់ជនជាតិដើមភាគតិច ដែលកំពុងរស់នៅភូមិឥសាន្ត និងភូមិភាគខាងជើងនៃប្រទេសកម្ពុជា ដែលយើងនិយមហៅថា ខ្មែរលើនោះ។[១]

ដោយសារការស្រលាញ់សេរីភាព ឯករាជ្យ និងការសប្បាយតាមលក្ខណៈដែលធម្មជាតិផ្តល់ឱ្យនោះ ជនជាតិដើមភាគតិច បានធ្វើបំលាស់ទីជាច្រើនសតវត្សមកហើយ ពីភូមិភាគកណ្តាលទៅកាន់តំបន់ភ្នំ និងខ្ពង់រាប ដែលជាតំបន់សំបូរដោយធនធានធម្មជាតិ និងមានដង់ស៊ីតេប្រជាជនតិច។ ការផ្លាស់ប្តូរទាំងនេះ គឺធ្វើឡើងក្នុងគោលបំណងគេចចេញពីការត្រួតត្រាតាមប្រព័ន្ធរដ្ឋបាលនៃរដ្ឋាភិបាលកណ្តាល ដែលគ្រប់គ្រងដោយអ្នកភូមិភាគកណ្តាល[២] ហើយពួកគាត់ចង់រស់នៅដោយពឹងផ្អែកលើធនធានធម្មជាតិ គោរពធម្មជាតិ និងសាសនាដើមរបស់ខ្លួន[៣] ដោយប្រកាន់ភ្ជាប់នូវប្រពៃណីទំនៀមទំលាប់ដើមរបស់ពួកគាត់រៀងៗខ្លួន ទៅតាមជនជាតិដើមនីមួយៗ ។

សង្គមវប្បធម៌របស់ជនជាតិដើមភាគតិច គឺរស់ពឹងអាស្រ័យលើធនធានធម្មជាតិទាំងស្រុង។ ធម្មជាតិ គឺជាអ្នកបង្កើតឱ្យមានឡើងនូវសង្គមវប្បធម៌ដ៏សម្បូរ

---

[១] យោងតាមការអង្កេតរយៈពេលជិតមួយទសវត្សរបស់លោក តឹក វណ្ណារ៉ា ទៅលើជនជាតិដើមភាគតិត ដែលមានវត្តមានតាមដងទន្លេមេគង្គ សេសាន សេកុង និងទន្លេស្រែពកនៃភូមិ-ភាគឥសាន្តប្រទេសកម្ពុជា។ ការអង្កេតធ្វើឡើងតាមរយៈការងាររបស់គាត់ ជាមួយនឹងសមាគម ថែរក្សាបរិស្ថាន និង វប្បធម៌)ក្នុងរយៈពេល ៩ ឆ្នាំ ២០០១-២០១០។

[២] អ្នកភូមិភាគកណ្តាល គឺជាអ្នកដែលទទួលបានការអប់រំខ្ពស់ មានធនធានច្រើន និងគ្រប់គ្រងលើអំណាចរដ្ឋបាលកណ្តាល។ យោងតាមការសំភាសន៍ជាមួយចាស់ទុំជនជាតិដើមចំនួន៨១នាក់ និងអ្នកពាក់ព័ន្ធនានានៅក្នុងខេត្តក្រចេះ ស្ទឹងត្រែង រតនគីរី មណ្ឌលគីរី និងព្រះវិហារ។

[៣] ជនជាតិដើមភាគតិច ប្រតិបត្តិ និងមានជំនឿលើព្រលឹងរបស់ដូនតា និងអារក្សអ្នកតា ដែលពួកគាត់គោរពតាំងពីពេលនៅរស់រហូតដល់ពេលស្លាប់។

បែប ហើយមានលក្ខណៈខុសប្លែកៗពីគ្នាអាស្រ័យទៅលើទីតាំងភូមិសាស្ត្រនៃជនជាតិដើមភាគតិចនីមួយៗរស់នៅ។ ជនជាតិដើមភាគតិច មិនសូវខ្វល់ខ្វាយការផ្សារភ្ជាប់រវាងវប្បធម៌ដើមរបស់ពួកគេជាមួយវប្បធម៌ទំនើបទេ ជាពិសេសផ្សារភ្ជាប់ជាមួយនឹងប្រព័ន្ធបច្ចេកទេសទំនើប។ ពួកគេបានគិតជាស្រេចថា ទោះបីជាគ្មានជំនួយពីខាងក្រៅ (ធនធានពីខាងក្រៅ) ក៏ពួកគេនៅតែមានធនធានគ្រប់គ្រាន់សំរាប់ចិញ្ចឹមជីវិត និងការរស់នៅរបស់ពួកគេជាធម្មតា។ ដោយសារការគិតបែបនេះ ទើបធ្វើឱ្យជនជាតិដើមភាគតិចបង្កើតបាននូវវប្បធម៌មួយ ដែលយើងអាចឱ្យឈ្មោះថា វប្បធម៌មិនប្រណាំងប្រជែងគ្នាក្នុងផ្នែកសេដ្ឋកិច្ច ការរស់នៅ និងរបររកស៊ី មានន័យថា ពួកគេរស់នៅតាមបែបសេរីនិយម ឯករាជ្យនិយម និងសន្តិភាពនិយម។

ប៉ុន្តែនៅពេលបច្ចុប្បន្ន វប្បធម៌ទាំងនេះ ត្រូវបានផ្លាស់ប្តូរ និងធ្វើសមាហរណកម្មបញ្ចូលគ្នាបន្តិចម្តងៗ ជាមួយនឹងវប្បធម៌ទំនើបដែលនាំចូលដោយអ្នកចំណូលថ្មីដែលបំលាស់ទីមកពីខេត្តតាកែវ ព្រៃវែង ស្វាយរៀង កណ្តាល កំពង់ចាម ក្រចេះ និងកំពត។ មូលហេតុនៃការផ្លាស់ប្តូរចម្បងរបស់ជនជាតិដើមភាគតិច គឺដោយសារការប្រែប្រួលធនធានធម្មជាតិ ដែលការប្រែប្រួលនេះវាជះឥទ្ធិពលផ្ទាល់ និងប្រយោលដល់ការរស់នៅ និងប្រកបរបរចិញ្ចឹមជីវិត ដូច្នេះពួកគាត់ត្រូវធ្វើការបន្សាំ និងសម្របខ្លួនបញ្ចូលរវាងសង្គមវប្បធម៌ចាស់ បញ្ចូលជាមួយនឹងសង្គមវប្បធម៌ថ្មី ដែលនាំចូលដោយអ្នកចំណូលស្រុក។ ការធ្វើបែបនេះ គឺជាជម្រើសថ្មីមួយ សំរាប់អភិវឌ្ឍន៍សង្គមវប្បធម៌ និងចាប់យកទំនើបនីយកម្មថ្មី សំរាប់អភិវឌ្ឍន៍សេដ្ឋកិច្ច និងគ្រួសាររបស់បងប្អូនជនជាតិដើមនីមួយៗ ដើម្បីដើរឱ្យទាន់យុគសម័យភាវូបនីយកម្មថ្មី។

ស្រាវជ្រាវ និងសរសេរដោយលោក តឹក វណ្ណារ៉ា
មន្ត្រីគ្រប់គ្រងកម្មវិធីទំនាក់ទំនង និងស្រាវជ្រាវ
នៃសមាគមថែរក្សាបរិស្ថាន និងវប្បធម៌
ស្ទឹងត្រែង, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨

# ៥. សមុទ្រឈើ

សមុទ្រឈើ ជាទីកន្លែងកំសាន្តមួយនៃខេត្តមណ្ឌលគិរី ដែលភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិទៅទស្សនាកំសាន្តមើលថ្ងៃរះ និងថ្ងៃលិច ហើយវាក៏ជាកន្លែងសំរាប់គូសង្សារក្មេង-ចាស់ទៅសាសងគ្នាលេងផងដែរ។ មូលហេតុដែលនាំឱ្យអ្នកទាំងពួងតែងតែទៅទស្សនានាទីកន្លែងនោះ ដោយសារទីកន្លែងសមុទ្រឈើមានទេសភាពស្រស់ត្រកាល ដែលអាចមើលឃើញទេសភាពព្រៃឈើយ៉ាងក្រាស់ឃ្មឹក ហើយឃើញភ្នំលើភ្នំ ហាក់បីដូចជាទេវតា ឬព្រះឥន្ទ្រាធិរាជបានរៀបចំតាក់តែងឡើងសំរាប់ជាទីកំសាន្តរបស់មនុស្សលោក។ អ្នកដែលបានទៅទស្សនាកន្លែងសមុទ្រឈើ មាន-អារម្មណ៍ជិតដាមជាប់ជានិច្ចជាមួយធម្មជាតិព្រៃឈើ វាលស្មៅដ៏ល្វឹងល្វើយ និងពន្លឺរស្មីព្រះអាទិត្យរះ និងលិច ដែលញ៉ាំងឱ្យអ្នកទស្សនានឹកឃើញរឿងអតីតកាល បច្ចុប្បន្នកាល និងស្រមៃទៅអនាគតកាលរបស់ខ្លួនយ៉ាងស្លុងអារម្មណ៍។

ពីទីកន្លែងមើលទេសភាពសមុទ្រឈើ គេអាចមើលឃើញជ្រោះជ្រៅ ជ្រលងដងអូរ វាលស្មៅ ព្រៃឈើ ចំការ និងភូមិរបស់ប ងប្អូនជនជាតិដើមភាគតិច និងឃើញកំពូលភ្នំជាច្រើនជាន់ដែលនៅតំរៀបបន្តគ្នាមិនដាច់។ ទេសភាពទាំងនេះ បានធ្វើឱ្យទុក្ខកង្វល់ភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ រសាយបានមួយគ្រា១ ហាក់បីដូចជាថ្នាំទិព្វធម្មជាតិមកប្រោះព្រំដួងវិញ្ញាណ និងដកទុក្ខកង្វល់ទាំងឡាយឱ្យរសាយបាត់អស់ពីដួងហឫទ័យ។

សមុទ្រឈើជាទីកន្លែងមើលទេសភាពព្រៃឈើនៅភូមិភាគឥសាន្ត ក្នុងខេត្តមណ្ឌលគិរី ហើយជាកន្លែងតែមួយគ្មានពីរនៅកម្ពុជា។

អ្វីៗ ដែលមាននៅកន្លែងនោះ គឺតាក់តែងឡើងដោយធម្មជាតិពិតៗ មានតំលៃដែលមិនអាចកាត់ថ្លៃបាន។ ធម្មជាតិទាំងនេះ មិនត្រឹមតែលំអសំរាប់ភ្ញៀវទេសចរណ៍ទាំងនោះទេ ប៉ុន្តែវាជាឱសថទិព្វសំរាប់ព្យាបាលជំងឺអ្នកមានវិបត្តផ្លូវចិត្តយ៉ាងស័ក្តិសិទ្ធទៀតផង ។

ស្ថានភាពសមុទ្រឈើនៅខេត្តមណ្ឌលគីរី នាពេលបច្ចុប្បន្ន



ស្រាវជ្រាវ និងសរសេរដោយ : លោក តឹក វណ្ណារ៉ា

មន្ត្រីគ្រប់គ្រងកម្មវិធីទំនាក់ទំនង និងស្រាវជ្រាវ

នៃសមាគមថែរក្សាបរិស្ថាន និងវប្បធម៌

ខេត្តមណ្ឌលគីរី. ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៨

# ៦. កោះនៅក្នុងភូមិអូររុន

នៅភូមិអូររុន មានកោះសំខាន់ៗដូចជា កោះភ្នំ កោះស្រឡៅ កោះស្វាយ កោះថ្នាំ កោះរវែង កោះវ៉ើនសូត្រ កោះគគីរ និងកោះប៉េតា។ កោះទាំងនេះ គឺជាកន្លែងសំរាប់ប្រកបរបរកសិកម្មចិញ្ចឹមជីវិតរបស់អ្នកស្រុកភូមិអូររុន។ មុខរបរកសិកម្មដែលប្រជាជនកំពុងធ្វើមានដូចជា ដំណាំពោត សណ្តែក ល្ង ចេក ថ្នាំជក់ ស្រូវ ដំឡូង និងដំណាំបន្ទាប់បន្សំផ្សេងៗទៀត។ តទៅនេះ គឺរៀបរាប់អំពីលក្ខណៈនៃកោះនីមួយៗ។

**កោះភ្នំ** ជាកោះមូលដែលមានរាងដូចជាភ្នំ ហើយមានផ្ទុះដុះលាយឡំជាមួយនឹងដើមឈើធំៗ ជាពិសេសនៅជុំវិញកោះនេះសំបូរទៅដោយព្រៃលិចទឹក។ នៅជាប់ខាងលិចនៃកោះនេះ មានអន្លង់ដ៏ធំមួយគឺអន្លង់ឃីខែ ដែលអ្នកភូមិបានចាត់ថា ជាអន្លង់អភិរក្សសំរាប់ត្រីមេពូជ។ កោះភ្នំមានបណ្តោយប្រមាណ៤០០ម៉ែត្រ និងទទឹងប្រមាណ១៥០ម៉ែត្រ។ នៅលើកោះភ្នំ ប្រជាជនប្រកបរបរដាំដំណាំពោត និងថ្នាំជក់។

**កោះស្រឡៅ** ជាកោះមួយ សំបូរទៅដោយដើមស្រឡៅដុះលាយឡំជាមួយនឹងដើមឈើជាច្រើនទៀត។ ដោយសារភាពសំបូរបែបនៃដើមស្រឡៅដុះនៅទីនោះ អ្នកស្រុកនាំគ្នាដាក់ឈ្មោះឱ្យថា កោះស្រឡៅ តរៀងមក។ កោះ ស្រឡៅមាន-បណ្តោយប្រមាណ១៥០០ម៉ែត្រ និងទទឹងប្រមាណ៦០០ម៉ែត្រ។ កោះនេះមានប្រជាជនរស់នៅចំនួន៣០គ្រួសារ ដោយប្រកបមុខរបរធ្វើស្រែ ចំការស្រូវ ចំការ ថ្នាំជក់ ចំការពោត និងសណ្តែក។ ជាពិសេសនៅលើផ្ទៃកោះនេះមានត្រពាំងមួយធំ មានទំហំ៥០ម៉ែត្របួនជ្រុង ហើយមានជម្រៅ២ម៉ែត្រនៅរដូវវស្សា និង០.៨ម៉ែត្រនៅ រដូវប្រាំង។

**កោះស្វាយ** : មូលហេតុដែលអ្នកភូមិហៅកោះនេះថា ជាកោះស្វាយ ដោយសារកាលពីសម័យឆ្នាំ ១៩៩៨ មានដើមស្វាយចេកធំមួយ ដែលមានម្លប់ដ៏ត្រឈឹងត្រឈៃ ដុះនៅចំណុចកណ្ដាលនៃក្បាលកោះ។ ប៉ុន្តែបច្ចុប្បន្នដើមស្វាយចេកនោះបាន-បាក់ធ្លាក់ចូលទៅក្នុងទឹកទន្លេមេគង្គហើយ។ កោះស្វាយមានបណ្ដោយ១៥០ម៉ែត្រ និងទទឹង៦០ម៉ែត្រ។ កោះនេះពុំមានប្រជាជនរស់នៅទេ។ នៅលើកោះ មានចំការថ្នាំជក់របស់អ្នកភូមិអូររុន។

**កោះថ្នាំ** : កោះនេះ កាលពីមុនពុំមានឈ្មោះទេ ទើបតែមានឈ្មោះនៅក្នុងរបបប៉ុល ពត ដោយសារនៅសម័យនោះ ប្រធានសហករណ៍សម័យប៉ុល ពត បានបញ្ជាឱ្យប្រជាជនចំនួន៤គ្រួសារទៅដាំថ្នាំជក់នៅលើកោះនោះ ដើម្បីយកមកប្រើប្រាស់នៅក្នុងសហករណ៍របស់ខ្លួន។ ដូច្នេះចាប់ពីពេលនោះមក ប្រជាជនបានឱ្យឈ្មោះ កោះនេះជាកោះថ្នាំចាប់តាំងពីពេលនោះមក។ កោះថ្នាំ មានបណ្ដោយ៣០០ម៉ែត្រ និងទទឹង១០០ម៉ែត្រ ។ នៅលើកោះពុំមានប្រជាជនរស់នៅទេរហូតមកដល់ពេលបច្ចុប្បន្ននេះ។ នាពេលបច្ចុប្បន្ននេះ ប្រជាជនភូមិអូររុន បានកំពុងដាំថ្នាំជក់នៅលើកោះនេះដដែល។

**កោះវែង** : កោះវែង ជាកោះមួយមានរាងតូច ហើយវែងជាងកោះដទៃទៀតនៅក្នុងភូមិអូររុន ដូច្នោះទើបប្រជាជនឱ្យឈ្មោះថា កោះវែង។ កោះវែង កាលពីមុនមានបណ្ដោយ ១៣០០ម៉ែត្រ និងទទឹង ២០០ម៉ែត្រ។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះកោះវែងបានក្លាយជាកោះខ្លីវិញហើយ ដោយសារបាក់ដីចូលទន្លេ ហើយមានបណ្ដោយប្រមាណ៧០០ម៉ែត្រ និងទទឹង១៥០ម៉ែត្រ។ នៅលើកោះអ្នកភូមិអូររុនបានដាំជា

ចំការចេក ចំការស្រូវ និងថ្នាំជក់។

**កោះរើនសូត្រ** : មានអន្លង់មួយដែលមានបណ្ដោយ៤០០ម៉ែត្រ និងទទឹង ៥០ម៉ែត្រ ដែលអ្នកភូមិអូររុនឱ្យឈ្មោះថា ជាអន្លង់រើនសូត្រ។ ដូច្នេះ ឈ្មោះកោះរើនសូត្រ ក៏ត្រូវបានអ្នកភូមិហៅតាមឈ្មោះអន្លង់រើនសូត្រតរៀងមក។ នៅលើកោះរើនសូត្រ ប្រជាជនដាំដំណាំថ្នាំជក់ ។ ពុំមានប្រជាជនរស់នៅលើកោះនេះទេរហូតមកដល់ពេលបច្ចុប្បន្ននេះ។

**កោះគគីរ** : កោះនេះមានដើមគគីរមួយដ៏ធំដុះនៅលើក្បាលកោះ ហើយដើមគគីរនេះមានម្លប់ដ៏ត្រឈៃ ដែលធ្វើឱ្យអ្នកធ្វើស្រែចំការ តែងតែទៅជ្រកនៅក្រោម ពេលដែលមានថ្ងៃក្ដៅ។ ដោយសារវត្តមាននៃដើមគគីរនេះទើបអ្នកស្រុកបានដាក់ឈ្មោះឱ្យកោះនេះថា កោះគគីរ តរៀងមក។ កោះគគីរមានទទឹង ២០០ម៉ែត្រ និងបណ្ដោយ១០០០ម៉ែត្រ។ នៅលើកោះ ប្រជាជនបានដាំដំណាំកសិកម្ម ដូចជាស្រូវ ពោត សណ្ដែក ល្ង ថ្នាំជក់ និងអំពៅជាដើម។

**កោះប៉េតា** : កោះប៉េតាជាកោះមួយដែលមានរាងដូចសត្វផ្សោត ដោយនៅក្បាលកោះមានថ្មបាយក្រៀមដុះលាយជាមួយខ្សាច់ស។ ឈ្មោះកោះប៉េតានេះ ពុំមាននរណាដឹងពីមូលហេតុអ្វី ដែលនាំឱ្យមនុស្សជំនាន់ដើមហៅកោះនេះ ថាជាកោះប៉េតាទេ។ កោះប៉េតាមានទទឹង២០០ម៉ែត្រ និងបណ្ដោយ៦០០ម៉ែត្រ។ នៅលើកោះមានចំការក្រូច ចេក ថ្នាំជក់ ដំឡូង និងពោតរបស់អ្នកស្រុកអូររុន។

ភូមិអូររុនជាភូមិមួយដែលមានទីតាំងនៅប្របទន្លេមេគង្គ ខាងក្រោមនៃភូមិអូរស្វាយ ហើយមានចម្ងាយ៦៥គីឡូម៉ែត្រពីខេត្តស្ទឹងត្រែង បើយើងធ្វើដំណើរតាមផ្លូវ

ថ្មល់ និងចំងាយ៤៥គីឡូម៉ែត្រ បើយើងធ្វើដំណើរតាមផ្លូវទឹក ដោយយកទន្លេមេគង្គ ធ្វើជាមធ្យោបាយ។[១]

---

[១]សំគាល់ : ចំពោះទំហំ បណ្តោយ ទទឹង និងជំរៅនៃកោះ និងអន្លង់នីមួយៗ គឺអ្នកស្រាវជ្រាវយើង ប្រើប្រាស់ឧបករណ៍សាមញ្ញសំរាប់ធ្វើការវាស់តែប៉ុណ្ណោះ ដូចជាខ្សែសន្ទូច និងខ្សែគោ ធ្វើជាម៉ែត្រ សំរាប់វាស់ ដូច្នេះវាមិនអាចមានភាពសុក្រិត១០០%នោះទេ។ ដើម្បីឱ្យមានភាពកាន់តែច្បាស់លាស់ និងសុក្រិត ការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រស្តីពីកោះ និងអន្លង់ក្នុងទន្លេមេគង្គ គួរតែធ្វើឡើង ដើម្បីកត់ត្រានូវធនធានទាំងឡាយនៅក្នុងអាងទន្លេមេគង្គ និងដៃរបស់វា សំរាប់យកលទ្ធផលមកដាក់ បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ និងប្រើប្រាស់អាងទន្លេប្រកបដោយនិរន្តរភាព។ ហើយការសិក្សាគួរ តែគ្របដណ្តប់ទៅលើទិដ្ឋភាពអាងទន្លេមេគង្គទាំងមូល។





ចងក្រងដោយ : លោក គង់ ចាន់ធី អាយុ ៤២ឆ្នាំ

ប្រធានគណៈកម្មការសហគមន៍នៃសាទ

ភូមិអូររុន ឃុំអូរស្វាយ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង

ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៨

## ៧. អន្លង់អាចម៍ក្រពើពាន់ (យីខែសាមផាន់)

អាចម៍ក្រពើពាន់ ជាឈ្មោះអន្លង់ត្រីមួយ ដែលមានទីតាំងជាប់នឹងចុងភូមិអូររុន ហើយខាងកើតជាប់នឹងអន្លង់ស៊ុនឡៃ និងខាងលិចជាប់នឹងកោះភ្នំ។ នៅសម័យដើមអ្នកស្រុកអូររុន និងអ្នកនេសាទមកពីតំបន់ដទៃទៀត ហៅអន្លង់អាចម៍ក្រពើពាន់ថា ជាអន្លង់ព្រះខែ ដោយសារអន្លង់នោះ មានទឹកថ្លាឈ្វេង ដែលធ្វើឱ្យអ្នកនេសាទអាចមើលឃើញពន្លឺព្រះខែច្បាស់ឆ្លុះពីផ្ទៃទឹកមកវិញ ជាពិសេស នាថ្ងៃពេញបូរមីជារៀងរាល់ខែ ដូច្នេះទើបពួកគាត់សន្មត់ហៅអន្លង់នោះថា ជាអន្លង់ព្រះខែតរៀងមក។ អន្លង់ព្រះខែនៅសម័យមុនសំបូរដោយត្រីមេពូជគ្រប់ប្រភេទរស់នៅ ដូចជាត្រីរាជ ត្រីគល់រាំង និងត្រីខ្យាជាដើម ជាពិសេសមានក្រពើរាប់ពាន់ក្បាលរស់នៅក្នុងអន្លង់ព្រះខែផងដែរ។ ប៉ុន្តែនៅសម័យដែលលាវ-សៀមគ្រប់គ្រងលើខេត្តស្ទឹងត្រែង ឈ្មោះអន្លង់ព្រះខែ ត្រូវបានប្តូរឈ្មោះថា យីខែសាមពាន់វិញ ដែលបកប្រែមកជា ភាសាខ្មែរមានន័យថា អន្លង់អាចម៍ក្រពើបីពាន់។ មូលហេតុដែលលាវដាក់ឈ្មោះដូច្នេះ ដោយ-សារពួកគេបានឃើញសត្វក្រពើជាច្រើនក្បាលរស់នៅក្នុងអន្លង់នោះ ជាពិសេសពួកគេ-បានឃើញអាចម៍ក្រពើនៅតាមមាត់អន្លង់ និងនៅលើកោះភ្នំជាច្រើនពាន់ដុំ ទើបពួកគេសន្មត់ដាក់ឈ្មោះអន្លង់នោះថា យីខែសាមផាន់ ដែលមានន័យជាភាសាខ្មែរថា អន្លង់អាចម៍ក្រពើបីពាន់រហូតមកដល់បច្ចុប្បន្ននេះ។

បច្ចុប្បន្ននេះ អន្លង់អាចម៍ក្រពើបីពាន់ ពុំមានក្រពើរស់នៅទេ ដោយសារក្រពើទាំងនោះត្រូវបានជនល្មើសចាប់លក់ឱ្យបរទេសនាឆ្នាំ១៩៩៤អស់ហើយ។ ប្រជាជន និងអ្នកនេសាទលែងបារម្ភ និងខ្លាចសត្វក្រពើទៀតហើយ នៅពេលដែលពួក

គាត់ចុះទៅនេសាទ ឬប្រើប្រាស់ធនធានទឹកអន្លង់អាចម៍ក្រពើបីពាន់នេះ។ ទោះជាយ៉ាងណាក៏ដោយ អន្លង់អាចម៍ក្រពើបីពាន់នៅសម្បូរត្រីមេពូជជាច្រើនប្រភេទ ដូចជា ត្រីប្រា ត្រីព្រួល និង ត្រីបបែលជាដើម ដែលអ្នកស្រុកអូររុន និងអ្នកនេសាទនៅទាញយកផលប្រយោជន៏ បានជាច្រើនពីអន្លង់អាចម៍ក្រពើបីពាន់ សំរាប់ជួយសម្រួលដល់ជីវភាពរស់នៅជាប្រចាំថ្ងៃរបស់ពួកគាត់។

អន្លង់អាចម៍ក្រពើបីពាន់មានបណ្តោយ ៥០០ម និងទទឹង១០០ម៉ែត្រ ជម្រៅនារដូវប្រាំង២០ម៉ែត្រ និងរដូវវស្សា៤០ម៉ែត្រ (ការវាស់ដោយអ្នកនេសាទ នៅភូមិ-អូររុនដោយប្រើខ្សែរសន្ទូចចងនឹងដុំថ្ម ដើម្បធ្វើការវាស់ជំរៅ បណ្តោយ និង ទទឹងរបស់អន្លង់អាចម៍ក្រពើបីពាន់នាពេលកន្លងមក)។



ការនេសាទត្រីនៅក្បែរអន្លង់អាចម៍ក្រពើបីពាន់
នៅក្នុងទន្លេមេគង្គភាគខាងលើ ខេត្តស្ទឹងត្រែង



ចងក្រងដោយ : លោកតា នុត ប៊ុន
អាយុ ៨០ឆ្នាំ
ចាស់ទុំនៅក្នុងភូមិអូររុន ឃុំអូរស្វាយ
ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង

## ៨. ប្រវត្តិភូមិអូរស្វាយ និងព្រឹត្តិការណ៍សំខាន់ៗ

ភូមិអូរស្វាយបានកើតឡើងនៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៦៤ ដោយសារមាន-ទាហាន ១៩នាក់ ដែលរៀបចំឡើងដោយសម្តេចនរោត្តម សីហនុ ដើម្បីឱ្យទាហានចាស់ៗ ដែលចូលនិវត្តន៍មករស់នៅ និងដើម្បីការពារព្រំដែនផង ។ ៦ខែក្រោយមក សម្តេច នរោត្តម សីហនុ បានបញ្ជូនប្រជារាស្ត្រមកពីបណ្តាខេត្តនានាដូចជា ខេត្តតាកែវ ស្វាយរៀង កណ្តាល ព្រៃវែង និងកំពង់ចាម និងទាហានចូលនិវត្តន៍ប្រហែលជា៣០០ គ្រួសាររួមទាំងទាហានកងអនុសេនាធំលេខ ២ កាលជំនាន់នោះ។

ការបញ្ជូនប្រជាជន មន្ត្រីរាជការ និងទាហានឱ្យមករស់នៅក្នុងតំបន់នេះ គឺក្នុងបំណងថែរក្សា និងការពារទឹកដីកុំឱ្យបរទេសឈ្លានពាន។ ដើម្បីសម្រួលដល់ការរស់នៅរបស់ប្រជាជន និងមន្ត្រីរាជការដែលសម្រេចចិត្តទៅរស់នៅតំបន់នេះ សម្តេច នរោត្តម សីហនុ បានបង្កើតឱ្យមានទីក្រុងរណបសំរាប់ខេត្តស្ទឹងត្រែងមួយ ដោយរៀបចំទីផ្សារ សាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ ព្រលានយន្តហោះ ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ និង-ភូមិដ្ឋានសំរាប់កងទ័ព និងប្រជាជនរស់នៅយ៉ាងសមរម្យ។ ទីក្រុងរណបនោះ ត្រូវបានប្រជាជន និយមហៅថា បូរីអូរស្វាយរហូតមកទល់ពេលបច្ចុប្បន្ននេះ។

បច្ចុប្បន្ននេះ យើងអាចឃើញសំណង់ចាស់ៗ និងហេដ្ឋារចនាសម្ព័ន្ធបាក់បែកមួយចំនួនដែលបន្សល់ទុកពីជំនាន់ សម្តេច នរោត្តម សីហនុ ដូចជា ផ្លាកសញ្ញាផែនការ៥ឆ្នាំរបស់សង្គមរាស្ត្រនិយម ស្តូបរូបសម្តេចនរោត្តម សីហនុ និងរបងសាលារៀនជាដើម។

មូលហេតុដែលអ្នកភូមិឱ្យឈ្មោះ ភូមិនេះថា ជាភូមិអូរស្វាយ ដោយសារមានដើមស្វាយចេកធំ៧៤ដើម នៅតាមបណ្តោយមាត់ទន្លេក្បែរអូរនៃភូមិ ទើបពួកគាត់ ដាក់ឈ្មោះភូមិថា ភូមិអូរស្វាយរហូតមក តែមកដល់ជំនាន់សម្តេចសីហនុ អ្នកភូមិបាន

ហៅភូមិនេះថាជា **បុរីអូរស្វាយ** វិញ ។

នៅឆ្នាំ ១៩៦៦ ភូមិអូរស្វាយមានកើតជំងឺគ្រុនចាញ់រាតត្បាតជាខ្លាំង បណ្តាលឱ្យមនុស្សស្លាប់ប្រហែលជា៣០០នាក់ ។ ជំងឺគ្រុនចាញ់នេះរាតត្បាតរយៈពេល២ឆ្នាំ ពេលនោះមានពេទ្យព្យាបាលជាប្រចាំថ្ងៃដែរ តែមិនអាចទប់ទល់នឹងជំងឺបានឡើយ ។ មូលហេតុដែលនាំឱ្យមានជំងឺគ្រុនចាញ់ដោយសារតំបន់នោះ សំបូរទៅដោយព្រៃឈើធំៗ និងជាតំបន់ទើបតែរានព្រៃធ្វើភូមិដ្ឋានថ្មី ដែលធ្វើឱ្យប្រជាជនទើបមករស់នៅថ្មីមិនអាចបន្សាំខ្លួន និងសុខភាពទាន់ពេលវេលាជាមួយនឹងអាកាសធាតុ និងមូស ជាពិសេសស្ថានភាពទឹកដីថ្មី។ នៅសម័យនោះ បើនិយាយពីធនធានធម្មជាតិវិញ មានភាពសំបូរឥតខ្ចោះ ដូចជាព្រៃឈើធំៗ ដុះយ៉ាងក្រាស់ មានសត្វព្រៃគ្រប់ប្រភេទរស់នៅ និង សំបូរត្រីដែលអាចរកធ្វើជាម្ហូបអាហារគ្រប់ពេលវេលាបាន ។

ឆ្នាំ ១៩៦៨ សម្តេច នរោត្តម សីហនុ បានយាងមកសម្ពោធសមិទ្ធិផលដែលទើបបានកសាងរួចនៅក្នុងបុរីអូរស្វាយ ។ បន្ទាប់មកជំងឺគ្រុនចាញ់ដែលបានរាតត្បាតក៏មានសភាពស្ងប់ស្ងាត់ទៅវិញ រីឯប្រជាជនមានជីវភាពរស់នៅសំបូរសប្បាយឡើងវិញ ព្រោះដោយសារធនធានធម្មជាតិមានអំណោយផលដល់ប្រជាជន ។

ឆ្នាំ ១៩៧០ លោក លន់ ណុល ធ្វើរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ស្រុកក៏កើតសង្គ្រាម ។ នៅពេលនោះ ប្រជាជនធ្វើស្រែចំការ និងរកស៊ីមិនបានដោយសារយន្តហោះទម្លាក់គ្រាប់បែក ។ ពេលនោះប្រជាជនជួបគ្រោះរាំងស្ងួត និងគ្រោះអត់ឃ្លាន ហើយក៏នាំគ្នារកជីកក្តួច ដំឡូង និងនេសាទត្រីធ្វើជាម្ហូបសំរាប់រស់មួយគ្រាៗ ។

ឆ្នាំ ១៩៧១- ៧៨ ក្នុងរបបប៉ុលពត ប្រជាជនធ្វើស្រែរួម ហូបរួម នៅឆ្នាំ ១៩៧៧ ប្រជាជនត្រូវបានជំលៀសចេញពីភូមិទៅនៅក្នុងភូមិអូរនេនាង សាមខួយ និង

ភូមិគោកចំបក់ ។ ហើយក្នុងសម័យនោះ ពួក ប៉ុល ពត បានធ្វើបាបប្រជាជន និងមិនឱ្យប្រជាជន ឬក៏មនុស្សបំផ្លាញធនធានធម្មជាតិ គឺគិតតែពីធ្វើការងារសមូហភាព ។

ឆ្នាំ ១៩៧៩ ប្រជាជនបានចូលមករស់នៅក្នុងភូមិវិញ (អូរស្វាយ) ក្រោមការដឹកនាំរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា។ ប្រជាជនបានសាងសង់សាលារៀនមួយខ្នងប្រវែង១៥ម៉ែត្រ ដោយមាន៣បន្ទប់ដំបូលប្រក់ស្បូវ ជញ្ជាំងបាំងបន្ទះឫស្សី តុ និងកៅអីដែលធ្វើពីដើមឫស្សីដែរ មានគ្រូស្ម័គ្រចិត្ត៣នាក់ដែលបានឧបត្ថម្ភដោយអ្នកភូមិផ្ទាល់។ ចំពោះធនធានធម្មជាតិក្រោយពីទុកចោលអស់រយៈពេលជាង៣ឆ្នាំក្នុងរបប ប៉ុល ពត មក ធនធានទាំងនោះមានភាពសំបូរឡើងវិញ ដូចជាព្រៃឈើ សត្វព្រៃ និងមច្ឆជាតិជាដើម ។

ឆ្នាំ ១៩៨៣-៨៥ នៅក្នុងភូមិបានសាងសង់គិលានុដ្ឋានសង្គ្រោះមួយខ្នងប្រវែង ១០ម ដោយប្រក់ស្បូវ មានតុ កៅអី គ្រែ ធ្វើពីដើមឫស្សី និងបន្ទះឫស្សី មានពេទ្យឃុំ ១នាក់ (អ្នកភូមិ) ដែលរៀបចំ ដោយមន្ទីរសុខាភិបាលខេត្ត ក្រោយមកគិលានុដ្ឋាននោះក៏បានបាក់បែកអស់ទៅ ។ នៅក្នុងកំឡុងឆ្នាំនោះដែរ អ្នកភូមិអូរស្វាយបានសាងសង់សាលាឆទានមួយខ្នងប្រវែង៨ម ជញ្ជាំងបន្ទះឫស្សី ក្រាលក្តារ ជាមួយគ្នានេះដែរ នៅឆ្នាំ ១៩៨៥ អ្នកភូមិអូរស្វាយក៏បាននាំគ្នាកសាងជាវត្តអារាមឡើងវិញដែរ ។

នៅឆ្នាំ ១៩៨៥ ដែរ ទឹកជំនន់បានជន់លិចភូមិ ធ្វើឱ្យខូចខាតផលដំណាំស្រែចំការជាដំណាំ។ ប្រជាជនជួបប្រទះនឹងភាពអត់ឃ្លាន ព្រមទាំងមានជំងឺរាតត្បាតលើសត្វគោ ក្របី ជ្រូក មាន់ និងទា ។ ក្របីងាប់ប្រហែលជា៣០ក្បាល ពេលនោះប្រជាជនទទួលបានការឧបត្ថម្ភពីសាលាស្រុកថាឡាបរិវ៉ាត់ចំនួនពីរឆ្នាំជាប់ៗគ្នា ។ ជំនួយទាំងនោះរួមមាន អង្ករ ឆ្នាំង ចប កាំបិត ពូថៅ ផាល នង្គ័ល ដឹង ត្រីខ និងម្សៅទឹកដោះគោជាដើម ។

នៅឆ្នាំ ១៩៨៦-៩០ អ្នកភូមិបានកសាងសាលារៀនពីរខ្នងទៀតដោយសារតែសាលារៀនចាស់ត្រូវបានបាក់ទ្រុឌទ្រោមអស់ ។ នៅចន្លោះឆ្នាំនេះ មានការលួចលាក់នេសាទខុសច្បាប់ខ្លះៗដូចជា លួចបោកគ្រាប់បែកពីទាហាន ឬនគរបាល ។ ទោះជា-មានបទល្មើសនេសាទកើតឡើងយ៉ាងនេះក៏ដោយ ក៏ត្រីនៅតែសំបូរអាចឱ្យយើងរកមកធ្វើជាម្ហូបបានគ្រប់ពេល ហើយសត្វព្រៃក៏អាចរកមកបរិភោគបានគ្រប់ពេលវេលាដែរ ។ បទល្មើសនេសាទ និងសត្វព្រៃនាពេលនោះ ជនល្មើសប្រព្រឹត្ត ដើម្បីយកមកធ្វើជាម្ហូបប៉ុណ្ណោះ មិនបានយកទៅលក់ដូរអ្វីទេ ។

នៅចន្លោះឆ្នាំ ១៩៩១-៩៥ មានទឹកជំនន់កើតឡើង ដែលបណ្តាលឱ្យផលស្រូវ និងដំណាំផ្សេងៗត្រូវខូចខាត ធ្វើឱ្យប្រជាជនជួបគ្រោះអត់ឃ្លាន ។

នៅក្នុងឆ្នាំ ១៩៩៣ ប្រជាពលរដ្ឋបានចូលរួមបោះឆ្នោតជ្រើសរើសតំណាងសភាជាតិអណត្តិទីមួយដែលរៀបចំដោយអ៊ុនតាក់ ( UNTAC ) ។

ចាប់ពីឆ្នាំ ១៩៩០មក បទល្មើសលើធនធានធម្មជាតិបានកើតឡើងយ៉ាងអនាធិបតេយ្យ ហើយមានការកើនឡើងឥតឈប់ឈរ ។ ការប្រព្រឹត្តបទល្មើសដ៏គគ្រឹកគគ្រេងបែបនេះដោយសារច្បាប់គ្រប់គ្រងធនធានធម្មជាតិនៅមានការខ្វះចន្លោះ ធ្វើឱ្យជនខិលខូចនាំគ្នាបំផ្លាញដូចជាការប្រើឧបករណ៍ខ្សែភ្លើងឆក់ បោកគ្រាប់បែក បិទអួរ អូសអួន និងការនាំត្រីចេញទៅប្រទេសឡាវ ។

នៅឆ្នាំ១៩៩៨ អ្នកភូមិបានចូលរួមបោះឆ្នោតជ្រើសរើសតំណាងសភាជាតិអណត្តិទី២ ហើយនៅក្នុងពេលនោះ អ្នកភូមិក៏បានចូលរួមបោះឆ្នោតជ្រើសរើស គណៈកម្មការអភិវឌ្ឍន៍ភូមិ ដែលរៀបចំដោយមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងឧបត្ថម្ភពីអង្គការដៃគូសំរាប់អភិវឌ្ឍន៍ខេត្តស្ទឹងត្រែង(PFD) ។ ជាមួយគ្នានេះដែរ អ្នកភូមិបានកសាង និង-

ជួសជុលផ្លូវលំក្នុងភូមិមួយខ្សែមានប្រវែង៦០០ម៉ែត្រគុណនឹង៧ម៉ែត្រ ។

នៅឆ្នាំ ១៩៩៨ដដែល អ្នកភូមិបានទទួលការជ្រលក់ថ្នាំមុងចំនួន៣លើក និងទទួលបានការលក់មុងក្នុងតំលៃថោក ហើយចំពោះអ្នកដែលក្រីក្រចែកជូនដោយមិនគិតថ្លៃ។ ក្នុងពេលជាមួយគ្នានេះដែរ អ្នកភូមិបានទទួលថ្នាំការពារជំងឺធំពោះចំនួន២ លើក និងបានទទួលថ្នាំការពារជំងឺ៦មុខ ចំពោះកុមារ ។

ចាប់ពីឆ្នាំ១៩៩៩ ដោយមានសេចក្តីប្រកាសពីរដ្ឋាភិបាលឱ្យឈប់ធ្វើអាជីវកម្មលើធនធានធម្មជាតិមក ការបំផ្លាញធនធានធម្មជាតិមានការស្ងប់ស្ងាត់។ ប៉ុន្តែនៅមានការឆក់ត្រីលួចលាក់នៅពេលយប់ ហើយនៅក្នុងឆ្នាំ២០០០ ធនធានត្រីបានធ្លាក់ចុះ កុំថាឡើយរកដើម្បីធ្វើអាជីវកម្ម សូម្បីតែដើម្បីធ្វើម្ហូបរបស់អ្នកភូមិក៏ស្ទើរតែមិនបានផង។

នៅឆ្នាំ ១៩៩៦-២០០០ មានអង្គការមូលនិធិបានឧបត្ថម្ភសាលារៀនមួយខ្នងប្រវែង៣០ម ដោយមាន៤បន្ទប់ ដំបូលប្រក់ក្បឿង ជញ្ជាំងថ្ម តុ កៅអី ធ្វើពីឈើ អណ្តូងជីកដៃមួយ និងបង្គន់អនាម័យមួយបន្ទប់ ។ ឆ្នាំ ២០០០ មានអង្គការដៃគូសំរាប់អភិវឌ្ឍន៍ប្រចាំខេត្តស្ទឹងត្រែង ( PFD) ដោយមានការសហការចំរុះស្ថាប័នក្នុងខេត្ត ចុះមកសំរង់ព័ត៌មានដើម្បីធ្វើការអភិវឌ្ឍ( PRA ) និងវាស់ថ្លឹងធ្វើការប៉ាន់ស្មានប្រមាណលើស្ថានភាពសុខភាពស្ត្រី និងកុមារ ( MCA) ហើយបានចាក់ថ្នាំបង្ការ និងអប់រំ អាហាររូបត្ថម្ភ ។

ថ្ងៃ ០៧-០៨ ខែ ១០ ឆ្នាំ ២០០០ មានសមាគមថែរក្សា បរិស្ថាន និង វប្បធម៌ (សេប៉ា ) ចូលមកធ្វើសំរង់ព័ត៌មានលើធនធានធម្មជាតិ ដោយមានការចូលរួម លើកផែនការអភិវឌ្ឍន៍ដោយអ្នកភូមិ (PNRA) ដើម្បីការពារថែរក្សា និងប្រើប្រាស់

ធនធានធម្មជាតិ ជាពិសេសមច្ឆាជាតិដោយសហគមន៍ផ្ទាល់ ។ ព័ត៌មានមួយចំនួនត្រូវ-បានដកស្រង់ចេញពីសៀវភៅ " ប៉ាន់ប្រមាណធនធានធម្មជាតិ" រៀបចំដោយសមាគមថែរក្សាបរិស្ថាន និងវប្បធម៌ ដែលមានលោក ទូច វណ្ណារិទ្ធិ ជាអ្នកសិក្សាស្រាវជ្រាវ និងចងក្រង ហើយបានមកពីការប្រមូលព័ត៌មាន និងវិភាគបន្ថែមដោយលោក តឹក វណ្ណារ៉ា ។



រូបសំណាកផែនការ៥ឆ្នាំ
របស់សង្គមរាស្ត្រនិយម






រូបស្តូបសម្តេចឪ ដែល
បន្សល់ទុកនៅបុរីអូរស្វាយ

ចងក្រងដោយ : លោក ស៊ិន យឿន
អាយុ ៤៨ឆ្នាំ
ជាចាស់ទុំ ភូមិអូរស្វាយ ឃុំអូរស្វាយ
ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង
ថ្ងៃទី១១ តុលា ឆ្នាំ ២០០៨

# ៨. អន្លង់កន្ទុយកោះ ឬអន្លង់ដើមស្វាយ

អន្លង់ដើមស្វាយ ជាអន្លង់មួយ ដែលមានទីតាំងស្ថិតនៅភាគខាងក្រោមនៃកន្ទុយកោះព្នៅ ស្ថិតនៅក្នុងភូមិសាស្ត្រភូមិអូរស្វាយ។ អន្លង់នេះ មានបណ្តោយ និងទទឹងប្រមាណ១០០ម៉ែត្រ ហើយមានជម្រៅ២៥ម៉ែត្រ នៅរដូវប្រាំង និងជម្រៅ១០០ម៉ែត្រនៅរដូវវស្សា។ អន្លង់ដើមស្វាយសំបូរទៅដោយត្រីមេពូជជាច្រើនប្រភេទ ដែលសំគាល់ឃើញថា ប្រភេទត្រីដែលអ្នកនេសាទចាប់បានភាគច្រើនគឺ ត្រីប្រាត្រីកេស និងត្រីពោធិ៍ ។ ភាពសំបូរបែបនៃត្រីនៅក្នុងអន្លង់នេះ ដោយសារស្ថានភាពនៃអន្លង់ដើមស្វាយ មានទីតាំងចំកណ្តាលនៃទន្លេមេគង្គ ដែលធម្មជាតិបង្កើតឱ្យមានច្រកពីរសំរាប់ត្រីឆ្លងកាត់ និងរស់នៅ ដូច្នេះបើត្រីចុះមកពីទន្លេមេគង្គភាគខាងលើក៏ត្រូវឆ្លងកាត់អន្លង់នេះ ហើយត្រីដែលឡើងពីទន្លេមេគង្គភាគខាងក្រោមមកពងកូនក៏ត្រូវឆ្លងកាត់អន្លង់នេះដែរ។

អ្នកភូមិអូរស្វាយបានរំលឹកថា អន្លង់ដើមស្វាយមិនត្រឹមតែសម្បូរត្រីទេកាលពីអតីតកាល[១] ប៉ុន្តែពួកគាត់ក៏បានឃើញសត្វព្រៃជាច្រើនប្រភេទតែងតែចុះមកផឹកទឹកនៅក្នុងអន្លង់នេះជារៀងរាល់ថ្ងៃ ដូចជា ដំរី ឈ្លូស ខ្លា ពស់ និងជ្រូកព្រៃជាដើម។ អន្លង់នេះ គឺជាកន្លែងមួយដែលផ្តល់ជាប្រភពជីវភាពដ៏សំខាន់មិនចេះរីងស្ងួតចំពោះអ្នកភូមិអូរស្វាយ ក៏ដូចជាអ្នកនេសាទដែលមកពីតំបន់ផ្សេងៗ សំរាប់ធ្វើការនេសាទផងដែរ ជាពិសេសគឺវាបានផ្តល់នូវប្រភពជីវចំរុះ និងប្រព័ន្ធធម្មជាតិមួយសំរាប់ផ្តល់

---

១. អ្នកភូមិអូរស្វាយបានកំនត់យកពេលមុនឆ្នាំ ១៩៩៤ ធ្វើជាសម័យអតីតកាល ពោលគឺជាសម័យដែលមិនទាន់មានការកាប់បំផ្លាញព្រៃឈើបែបអនាធិបតេយ្យយ៉ាងគគ្រឹកគគ្រេង។ ដូច្នោះមុនឆ្នាំ ១៩៩៤ ជាឆ្នាំដែលធនធានធម្មជាតិនៅក្នុងភូមិអូរស្វាយនៅមានសម្បូរបែប។

ឱ្យទៅតំបន់ផ្សេងៗទៀត។

មូលហេតុដែលអ្នកភូមិបានដាក់ឈ្មោះឱ្យអន្លង់នេះថា ជាអន្លង់ដើមស្វាយ ឬអន្លង់កន្ទុយកោះ ដោយសារនៅសម័យដើម អ្នកភូមិអូរស្វាយបានឃើញនៅមាត់អន្លង់តាមបណ្ដោយច្រាំងទន្លេមេគង្គ មានដើមស្វាយចេក[១] ដុះជាច្រើនដើម ហើយដើមស្វាយ-ទាំងនោះមានផ្លែទុំពេញដើម ហើយផ្លែរបស់វា តែងតែទុំជ្រុះធ្លាក់ចូលទៅក្នុងអន្លង់ក្លាយជាចំណីត្រី និងសត្វទឹកដែលរស់នៅក្នុងអន្លង់នោះ ដោយឃើញស្ថានភាពបែបនេះ ទើបអ្នកភូមិបានឱ្យឈ្មោះ ឬហៅអន្លង់នោះថា អន្លង់ដើមស្វាយតាំងពីពេលនោះមក។ ដោយឡែកអ្នកស្រុកកោះព្នៅ បាននាំគ្នាហៅអន្លង់នេះថា ជាអន្លង់កន្ទុយកោះទៅវិញ ដោយយោងថា អន្លង់នេះមានទីតាំងស្ថិតនៅកន្ទុយកោះព្នៅ។ ការនិយមហៅរបស់អ្នកភូមិអូរស្វាយ និងអ្នកភូមិកោះព្នៅបែបនេះ ទើបអន្លង់នេះមានឈ្មោះពីរ តាំងពីពេលនោះមក គឺគេអាចហៅថា អន្លង់ដើមស្វាយ ឬអន្លង់កន្ទុយកោះអាស្រ័យទៅលើការនិយមហៅរៀងៗខ្លួន។



ចងក្រងដោយ : លោក ភេ ឈុំ អាយុ៥៦ឆ្នាំ

ភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង

ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៨

---

១. ស្វាយចេក ជាប្រភេទស្វាយមួយប្រភេទ មានគ្រាប់ធំ សាច់ស្ដើង មានរសជាតិផ្អែម យើងអាចហូបវាបាន។ ស្វាយនេះ ប្រសិនបើយើងយកវាទៅធ្វើជាដំណាប់ វានឹងអាចមានរសជាតិឆ្ងាញ់ជាងស្វាយខ្ចីទៅទៀត នេះបើតាមការបញ្ជាក់ពីអ្នកភូមិអូរស្វាយ។

# ១០. ត្រពាំងក្បាលដំរី

ត្រពាំងក្បាលដំរីមានទីតាំងនៅភាគខាងកើតនៃតំបន់ដុំក្រឡប្រមាណ៨គីឡូម៉ែត្រ បើយើងធ្វើដំណើរតាមបណ្ដោយថ្នល់ជាតិពីព្រំដែនឡាវ សំដៅមកកាន់ទីរួមខេត្ត ស្ទឹងត្រែង។ ត្រពាំងក្បាលដំរីមានបណ្ដោយ និងទទឹងប្រមាណ៥០ម៉ែត្រ ហើយទឹកនៅក្នុងត្រពាំងមានជម្រៅជាធម្មតាត្រឹមកមនុស្សចាស់ទាំងរដូវប្រាំង និងរដូវវស្សា។ ត្រពាំងនេះកាលពីដើម សំបូរទៅដោយត្រីជាច្រើនប្រភេទរស់នៅ និងមានសត្វព្រៃ និងល្មូនគ្រប់ប្រភេទតែងតែមកផឹកទឹកនៅក្នុងត្រពាំងនេះ។ សត្វព្រៃដែលចុះមកផឹកទឹកត្រពាំងច្រើនជាងគេ គឺសត្វដំរី ព្រោះជុំវិញត្រពាំងក្បាលដំរីសំបូរទៅដោយល្បាក់ព្រិច និងវាលស្មៅ ដែលបង្កលក្ខណៈងាយស្រួលដល់សត្វដំរីរកស៊ី រស់នៅ បន្តពូជនៅក្នុងតំបន់នោះ។

អ្នកស្រុកបានដាក់ឈ្មោះត្រពាំងថា ជាត្រពាំងក្បាលដំរី ដោយសារពួកគាត់យោងទៅលើព្រឹត្តិការណ៍ដែលកើតនៅសម័យពាក់កណ្ដាលទសវត្សទី៨០ ដែលកាលនោះទាហានបានបាញ់សម្លាប់ដំរីប្រមាណ៣០ក្បាល នៅក្បែរត្រពាំងក្បាលដំរី ដើម្បីយកថែ និងភ្លុកដំរីលក់ទៅឱ្យបរទេស។ ក្រោយពេលដែលបាញ់សម្លាប់សត្វដំរីរួចហើយ ក្រុម-ទាហានដែលល្មើសច្បាប់បានប្រមូលយកភ្លុក និងថែដំរីតែប៉ុណ្ណោះ ដោយទុកសាច់ និងរាងកាយរបស់ដំរីនីមួយៗ ជាពិសេសក្បាលដំរី គេពុំបានយកទៅធ្វើពាណិជ្ជកម្ម ឬហូបទេ។ បន្ទាប់ពីសម្លាប់សត្វដំរីប្រមាណ៣០រួច ក្រុមទាហានបានប្រមូលយកភ្លុក និងថែរួចហើយ ពួកគេក៏នាំគ្នាចាកចេញពីកន្លែងដែលសម្លាប់ដំរីនោះទៅ។ ក្រោយការចាកចេញរបស់ទាហានល្មើសច្បាប់ អ្នកភូមិ និងអ្នកប្រមាញ់បានធ្វើដំណើរមកដល់កន្លែងសម្លាប់ដំរី ហើយឃើញក្បាលដំរីប្រមាណ៣០ ដែលគេសម្លាប់។ ឃើញដូច្នេះ

ទាំងអ្នកប្រមាញ់ និងអ្នកភូមិមានការអាណិតអាសូរសត្វដឺរីជាពន់ពេក ទើបពួកគាត់ដាក់ឈ្មោះឱ្យត្រពាំងដែលមានទីតាំងនៅក្បែរដឺរីស្លាប់នោះថា ជាត្រពាំងក្បាលដឺរីតាំងពីពេលនោះមក ដើម្បីជាការចងចាំសម្រាប់កូនចៅជំនាន់ក្រោយ កុំឱ្យសម្លាប់សត្វដឺរីដូចក្រុមទាហានល្មើសច្បាប់ទាំងនោះទៀត។ ថ្លែងពីក្រុមទាហានវិញ ក្រោយពីដឹកឆ្អឹងដឺរី និងចែចេញពីកន្លែងសម្លាប់ដឺរីរួច ក៏ត្រូវសមត្ថកិច្ចចាប់បាន និងដាក់ទោសទៅតាមច្បាប់ និងក្រុមដែលរត់រួចនោះ ក្រោយមកក៏មានជំងឺជាបន្តបន្ទាប់ អ្នកខ្លះក៏ស្លាប់ ហើយអ្នកខ្លះទៀតក៏ធ្លាក់ខ្លួនក្ររហេមរហាមតាំងពីពេលនោះមកដែរ។

នៅក្បែរត្រពាំងក្បាលដឺរី មានរឿងអាថ៌កំបាំងមួយទៀតដែលអ្នកភូមិបានប្រាប់ថា មានហិបថ្មមួយមានទទឹង១ម៉ែត្រ និងបណ្តោយ២ម៉ែត្រ។ អ្នកភូមិមិនបានដឹងថា នៅក្នុងហិបថ្មនោះមានរបស់អ្វីទេ ហើយហិបនេះបានក្លាយទៅថ្មនៅពេលបច្ចុប្បន្ន ដែលធ្វើឱ្យអ្នកភូមិ និងប្រជាជនមកពីតំបន់ដទៃទៀតនៅតែមិនអាចដឹងបានថា មានរបស់អ្វីនៅក្នុងហិបនោះដដែល។



ចងក្រងដោយ : អ្នកមីង មុត សុភា អាយុ៥២ឆ្នាំ
ភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង
ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៨

# ១១. ប្រវត្តិភូមិកោះព្នៅ

ភូមិកោះព្នៅ គឺជាភូមិមួយដែលស្ថិតនៅលើកោះនៃទន្លេមេគង្គភាគខាងលើនៃខេត្ត ស្ទឹងត្រែង មានព្រំប្រទល់ខាងកើតជាប់ភូមិអូរស្វាយ ខាងលិចទល់នឹងទន្លេ ជាប់ភូមិ កោះឈើទាលតូច ខាងជើងជាប់ទន្លេ ហើយជាប់ជាមួយភូមិកោះឈើទាលធំ ខាង ត្បូងទល់ទន្លេ ដែលមានទឹកហូរព័ទ្ធជុំវិញ។

អ្នកមកតាំងទីលំនៅលើកោះនេះមុនគេ គឺគ្រួសារលោកយាយផង និងលោកតាអ៊ុក ដោយរស់នៅត្រង់ក្បាលកោះ ប្រកបមុខរបរធ្វើស្រែ ចំការ និងធ្វើការនេសាទត្រី ។

ពីឆ្នាំ ១៩៦០-៧០ ប្រជាពលរដ្ឋមានសេរីភាព ក្នុងនោះដែរមានប្រជាពលរដ្ឋមកពី ភូមិអូរស្វាយចំនួន១០គ្រួសារ (៦១នាក់) បានមករស់នៅលើកោះនេះ ដោយនាំគ្នា ប្រកបមុខរបរធ្វើស្រែចំការលើផ្ទៃដីប្រហែល៧ហិកតា និងធ្វើការនេសាទសំរាប់ គ្រួសារ និងយកផលត្រីធ្វើការកែច្នៃជាត្រីងៀត.ត្រីឆ្អើរ.ផ្អក និងប្រហុកជាដើម សំរាប់ ទុកហូប ពេលរដូវទឹកឡើង ឬពេលរដូវធ្វើស្រែ ។

រហូតមកដល់ពេលបច្ចុប្បន្ន អ្នកភូមិកោះព្នៅនៅតែពឹងផ្អែកលើធនធានធម្មជាតិ សំរាប់ផ្គត់ផ្គង់ជីវភាពរស់នៅ ដូចជាធនធានទន្លេ មានការនេសាទត្រី ធនធានទឹកមាន មធ្យោបាយធ្វើដំណើរ ហើយធនធានព្រៃឈើមានដូចជាអនុផលព្រៃឈើ សំរាប់យក មកផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារដូចជា (ឈើសំណង់ . វល្លិ៍ . ផ្តៅ . ថ្នាំបូរាណ) ជា ពិសេស គឺអាហារប្រចាំថ្ងៃដែលជួយដល់សុខភាព ។

កាលពីដើមឡើយ ចាស់ៗនៅក្នុងភូមិនេះតែងតែងនាំគ្នាហៅភូមិនេះថា គឺជាកោះ ព្រះនៅ ក្រោយមកក៏អ្នកភូមិបាននាំគ្នាហៅភូមិនេះជាភូមិកោះព្នៅរហូតមកដល់សព្វ ថ្ងៃនេះ ។ ឈ្មោះកោះព្រះនៅមានតំណាលថា កាលពីជំនាន់ដើម មានព្រះពុទ្ធរូបមួយ

អង្គមានទម្រង់ព្រះភ្អែន ហើយមានសំបុរខ្មៅ មានកម្ពស់ប្រហែល២ម៉ែត្រ បានរំកិលព្រះកាយពីភូមិព្រះរំកិលមកគង់នៅក្រោមដើមជ្រៃមួយ ដែលមានទីតាំងនៅចំកន្លែងអន្លង់ជ្រៃ។ អន្លង់ជ្រៃ មានទីតាំងនៅខាងលិចភូមិកោះព្នៅ (អន្លង់ជ្រៃកាលពីមុនមានទទឹង និងបណ្ដោយប្រមាណ១០០ម៉ែត្រ ហើយមានដើមជ្រៃមួយដើមធំដុះនៅចំកន្លែងអន្លង់ ប៉ុន្តែបច្ចុប្បន្ននេះ អន្លង់ជ្រៃបានបាត់សភាពដើមអស់ហើយ ដោយសារដីខ្សាច់ដុះលប់) ។ ៥ឆ្នាំក្រោយនៃការគង់ព្រះកាយក្រោមដើមជ្រៃនៃអន្លង់ជ្រៃមកព្រះពុទ្ធរូប ក៏បានរំកិលព្រះកាយ ឬបំបាំងព្រះកាយបាត់ទៅ ដោយពុំឱ្យប្រជាជនអាចមើលឃើញព្រះកាយព្រះពុទ្ធរូបបន្តទៀត។ ការបាត់ព្រះកាយរបស់ព្រះពុទ្ធរូបបានធ្វើឱ្យប្រជាជននៅក្នុងភូមិកោះព្នៅទាំងមូលមានការសោកសង្រេងជាពន់ពេក។ ដើម្បីរំលឹកគុណដល់ព្រះពុទ្ធរូបដែលធ្លាប់តែថែរក្សា និងផ្ដល់សេចក្ដីសុខដល់ប្រជាជនកន្លងមក អ្នកភូមិ និងចាស់ទុំបានពិភាក្សាគ្នា រួចក៏ព្រមព្រៀងគ្នាដាក់ឈ្មោះភូមិថា ភូមិកោះព្រះនៅ ប៉ុន្តែលុះសម័យក្រោយមកទៀត ដោយការវិវត្តនៃការហៅឈ្មោះនេះ និងដើម្បីងាយស្រួលក្នុងការហៅ អ្នកភូមិក៏បានប្ដូរការហៅឈ្មោះភូមិមកជាទំរង់ខ្លីវិញ ថា ភូមិកោះព្នៅ ដោយពុំដឹងថា បាននាំគ្នាហៅតាំងពីពេលណាមក។

នៅសម័យសង្គមចាស់ (សម័យសង្គមរាស្ត្រនិយម) មានអ្នកនេសាទជនជាតិចាមម្នាក់ឈ្មោះតាឡាច បានមកនេសាទនៅក្នុងអន្លង់ជ្រៃដោយប្រើឧបករណ៍សំណាញ់ ។ ក្នុងពេលកំពុងបង់សំណាញ់ គាត់បានបង់ជាប់នឹងវត្ថុមួយនៅក្នុងទឹក ដោយគាត់ពុំដឹងថា ជារបស់អ្វីទេ។ ពេលដែលសំណាញ់ជាប់នៅក្នុងទឹក គាត់បានចុះមុជទឹក ដើម្បីដោះដើងសំណាញ់របស់គាត់ ក៏ប្រទះឃើញព្រះមួយអង្គមានពណ៌ក្រហម មិនដឹងធ្វើពីមាស ឬលង្ហិន មានព្រះកាយពែនភ្អែន និងមានកម្ពស់មួយជំហរមនុស្ស បើគិតជាម៉ែត្រប្រមាណ២ម៉ែត្រ។ ពេលដែលគាត់បានឃើញ គាត់មានការភ័យខ្លាចជាខ្លាំង

ដោយគាត់មាន ជំនឿថា គាត់កំពុងធ្វើការនេសាទ នៅកន្លែងដែលព្រះនៅ ដែលទង្វើនេះមិនគួរគប្បីទាល់តែសោះ។ ក្រោយពីដោះសំណាញ់រួច តាឡាច បានធ្វើការសុំខមាទោសចំពោះព្រះពុទ្ធរូបដែលខ្លួនបានបង់ជាប់ ហើយសំសេចក្ដីសុខគ្រប់បែបយ៉ាងពីព្រះអង្គឱ្យជួយថែរក្សាគាត់ និងក្រុមគ្រួសារ ជាពិសេស គាត់បានយករឿងនេះទៅប្រាប់ដល់អ្នកនេសាទដទៃទៀត កុំឱ្យមកនេសាទនៅក្នុងអន្លង់ជ្រៃ ដែលជាអន្លង់ព្រះពុទ្ធគង់នៅឱ្យដឹងគ្រប់ៗគ្នា។ ក្រោយពីដឹងព្ធ័ត៌មានបែបនេះហើយ គ្រប់អ្នកនេសាទ ក្នុងទន្លេមេគង្គភាគខាងលើតែងតែគោរពចំពោះអន្លង់ជ្រៃ និងមិនដែលហ៊ានបំពាន ដោយចុះទៅនេសាទក្នុងអន្លង់នោះទេ ជាពិសេសអ្នកនេសាទក្នុងភូមិកោះព្នៅ។ មានតែអ្នកនេសាទដែលមកពីតំបន់ផ្សេង ដែលពុំបានដឹងរឿង ទើបពួកគេចុះទៅនេសាទនៅក្នុងអន្លង់ជ្រៃ។

ក្នុងឆ្នាំ២០០៥ អ្នកនេសាទឈ្មោះ ជុច នាង និងប្រពន្ធឈ្មោះ ទៀង សុខដា បានទៅនេសាទនៅក្នុងអន្លង់ជ្រៃ ឬហៅថា អន្លង់ព្រះនៅ ដោយប្រើឧបករណ៍សន្ទូច។ នៅពេលដែលលោក ជុច នាង សំរាន្តលក់ ព្រះរំកិល បានមកពន្យល់សប្ដិដល់គាត់ឱ្យគាត់ឈប់វាយសន្ទូចនៅក្នុងអន្លង់នោះ ព្រោះរំខានដល់ការគង់របស់ព្រះអង្គ។ ប៉ុន្តែអ្នកនេសាទឈ្មោះ ជុច នាង ពុំបានស្ដាប់ដំបូន្មានពីការពន្យល់សប្ដិទេ ដោយគិតថា នេះគឺជារឿងយល់សប្ដិ វាមិនជារឿងពិតប្រាកដទេ។ ដោយមានគំនិតគិតដូច្នេះ គាត់ក៏ចុះទៅវាយសន្ទូចនៅក្នុងអន្លង់ជ្រៃជាលើកទី២ ។ ការចុះទៅនេសាទនៅលើកទី២ ដោយវាយសន្ទូចនោះនៅក្នុងអន្លង់ដដែល ស្រាប់តែព្រឹកឡើងម្ចាស់សន្ទូចបានឃើញសន្ទូចរបស់ខ្លួនត្រូវបានសារឡើង និងរៀបចំទុកដាក់ឱ្យយ៉ាងស្អាតនៅលើច្រាំង ក្បែរអន្លង់នោះ ហាក់បីដូចជាមានមនុស្សសារទុកឱ្យជាមុនអញ្ចឹង។ ទោះបីជាជួប ព្រឹត្តិការណ៍បែបនេះក៏ដោយ ក៏អ្នកនេសាទពុំមានជំនឿលើរឿងយល់សប្ដិរបស់ខ្លួនដែរ

គាត់នៅតែបន្តចុះទៅនេសាទនៅក្នុងអន្លង់ជ្រៃដដែល។ លើកទីបី ពេលដែលគាត់ចុះទៅនេសាទនៅក្នុងអន្លង់នោះ ស្រាប់តែមានទឹកកួចធ្វើឱ្យទូក និងម៉ាស៊ីនរបស់គាត់លិចចូលទៅក្នុងអន្លង់តែម្តង ប៉ុន្តែពុំមានការគ្រោះថ្នាក់ដល់អាយុជីវិតទេ គ្រាន់តែបាត់បង់ឧបករណ៍ ទូក និងម៉ាស៊ីន ដោយពុំអាចស្រង់យកមកវិញបានទេ។ ក្រោយពីបានជួបនូវព្រឹត្តិការណ៍៣លើកជាប់ៗគ្នាមក ទើបធ្វើឱ្យលោក ជុច នាង និងប្រពន្ធដែលជាអ្នកនេសាទនឹកឃើញការយល់សប្តិរបស់ខ្លួន និងចាប់ផ្តើមមានជំនឿលើអន្លង់នោះតាំងពីពេលនោះមក។

រហូតមកដល់ពេលបច្ចុប្បន្ន អ្នកភូមិនៅតែមានជំនឿថា មានព្រះពុទ្ធរូបមួយព្រះអង្គតែងតែធ្វើការផ្លាស់ប្តូរទីតាំងរបស់ខ្លួនពីអន្លង់ជ្រៃ ទៅអន្លង់យាយតែង ហើយផ្លាស់ពីអន្លង់យាយតែងទៅអន្លង់តាហេង និងអន្លង់ឃុំ។ ការផ្លាស់ប្តូរទីតាំងបែបនេះទើបអ្នកភូមិឱ្យឈ្មោះព្រះពុទ្ធរូបអង្គនោះថា ព្រះរំកិលតរៀងមករហូតដល់ពេលបច្ចុប្បន្ននេះ។



ចងក្រងដោយ : លោក យេន មុំ អាយុ៤២ឆ្នាំ
ភូមិកោះព្នៅ ឃុំអូរស្វាយ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង
ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៨

# ១២. ប្រពៃណីនេសាទត្រីរបស់អ្នកភូមិកោះព្នៅ

ការនេសាទត្រីគឺជាមុខរបរទីពីររបស់អ្នកភូមិកោះព្នៅ បន្ទាប់ពីស្រែចំការ និងការប្រមូលផល និងអនុផលព្រៃឈើ។ មុនពេលចុះទៅនេសាទត្រី អ្នកភូមិកោះព្នៅ មានទម្លាប់ធ្វើការសែនព្រេន និងធ្វើត្រាប់តាមធម្មជាតិដូចជាចាំមើលមេត្រីត្រសក់ឡើងជាដើម។ ប្រពៃណីទាំងនេះ អ្នកភូមិនៅតែអនុវត្តជាប្រចាំ ហើយវាបានដក់ជាប់ក្នុងអារម្មណ៍របស់អ្នកភូមិគ្រប់ៗគ្នា។ ក្នុង១ឆ្នាំ អ្នកភូមិកោះព្នៅប្រារព្ធពិធីសែនព្រេនចំនួន២ដង មុនចុះទៅនេសាទ គឺធ្វើឡើងនៅខែពិសាខ និងខែមាឃ។ ការសែនព្រេនក្នុងគោលបំណងសុំសេចក្ដីសុខគ្រប់បែបយ៉ាងក្នុងការចុះទៅនេសាទ និងឱ្យលោកតាម្ចាស់ទឹក ម្ចាស់ដី តាមថែរក្សា និងជួយឱ្យនេសាទត្រីបានច្រើន ហើយជាពិសេសពួក-គាត់សុំកុំឱ្យព្រាយ បិសាចមកធ្វើបាបដល់ពួកគាត់។ អ្នកភូមិមានជំនឿថា ប្រសិនបើអ្នកនេសាទ មិនបានចូលរួមនៅក្នុងពិធីសែនទេ នោះពួកគេប្រាកដជាមិនអាចយកត្រី-បានហូប ទោះបីជាសម័យនោះធនធានត្រីមានភាពសម្បូរបែបយ៉ាងណាក៏ដោយ។

នៅសម័យដើម មានអ្នកនេសាទដ៏ចំណាស់ម្នាក់ ជាអ្នកដឹកនាំក្នុងការចុះទៅនេសាទ គាត់មានឈ្មោះថា តាសាលី។ តាសាលី តែងតែចុះទៅឈរនៅក្រោមដើមអំពិលទឹកបារាំង (ច័ន្ទគីរី) ចំកណ្ដាលភូមិក្បែរច្រាំងទន្លេចាំសង្កេតមើលត្រីត្រសក់ឡើងមក។ តាសាលី បានកត់សម្គាល់ថា ល្ងីកណាឃើញមេត្រីត្រសក់យ៉ាងធំ (អាចមានទម្ងន់១៥០គ.កឡើង) ឡើងមកលោតចុះ លោតឡើងនៅអន្លង់ក្បែរដើមអំពិលទឹកបារាំង នោះបញ្ជាក់ថា អ្នកភូមិអាចចុះទៅនេសាទត្រីបានហើយ ព្រោះដល់រដូវត្រីសម្បូរ និងអាចចាប់យកមកបរិភោគ។ ពេលដែលតាសាលី ឃើញសញ្ញាត្រីត្រសក់ប្រាប់ដូច្នេះ គាត់ក៏ចាប់ផ្ដើមវាយអាគាំង ដើម្បីជូនដំណឹងដល់អ្នកនេសាទដទៃទៀត

ឱ្យប្រុងប្រៀបខ្លួនក្នុងការចុះទៅនេសាទក្នុងទន្លេ។ បន្ទាប់ពីឮសំលេងអាគាំងរបស់តាសាលីហើយ អ្នកនេសាទនៅក្នុងភូមិបានមកជួបជុំគ្នានៅក្រោមដើមអំពិលទឹកបារាំង ដើម្បីត្រៀមខ្លួនចុះទៅនេសាទត្រី។ ក្រោយពីអ្នកនេសាទបានមកជួបជុំគ្នាអស់ហើយ តាសាលី បានផ្តល់សញ្ញាដល់អ្នកនេសាទឱ្យចុះទៅនេសាទម្តងពីរទូក១បន្តបន្ទាប់គ្នា ដែលមើលទៅឃើញថា មានវិន័យ និងច្បាប់យ៉ាងត្រឹមត្រូវក្នុងការដកហូត ឬចាប់ត្រីយកមកបរិភោគ។ ការធ្វើបែបនេះ ត្រូវបានតាសាលីបកស្រាយថា ដើម្បីកុំឱ្យត្រីផ្អើល និងភ័យចំពោះសកម្មភាពរបស់អ្នកនេសាទ។ ដូច្នេះពេលដែលអ្នកភូមិចុះទៅនេសាទម្តង១ យើងអាចមើលឃើញទិដ្ឋភាពដូចជាគេធ្វើការប្រណាំងទូក ដែលមានទូកជាបន្តបន្ទាប់ អុំពីក្រោយគ្នាជាប់។

នៅសម័យនោះ តាសាលីបានអនុញ្ញាតឱ្យស្ត្រីចុះទៅនេសាទជាមួយបុរសបាន ប៉ុន្តែស្ត្រីទាំងនោះត្រូវចូលរួមសែនព្រេនជាមួយបុរសដែរ មុនចុះទៅនេសាទ ទើបអនុញ្ញាត ប្រសិនបើមិនបានចូលរួមក្នុងពិធីសែន គឺគេពុំអនុញ្ញាតឱ្យស្ត្រីនោះចុះទៅនេសាទទេ។



ចងក្រងដោយ : លោក ភួយ ខាំផែង អាយុ៥៥ឆ្នាំ
អនុប្រធានភូមិកោះព្នៅ ឃុំអូរស្វាយ
ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង
ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៨

# ១៣. ប្រវត្តិភូមិកោះឈើទាលធំ និងព្រឹត្តិការណ៍សំខាន់ៗ

ភូមិកោះឈើទាលធំកកើតឡើងជាង២០០ឆ្នាំកន្លងមក ហើយអ្នកមកតាំងទីលំនៅលើកោះនេះដំបូងបង្អស់ គឺមានឈ្មោះ តាឪ យាយម៉ាន់ តាមូន យាយតែង តាប៊ុន យាយដា បន្ទាប់មកមានតាទិត មកពីខេត្តកំពង់ធំឡើងមករកស៊ីទីនេះ ហើយបានយកប្រពន្ធជនជាតិឡាវនៅតំបន់ព្រំដែនខ្មែរ-ឡាវ ក៏មកតាំងទីលំនៅនៅភូមិនេះដែរ ។ តមកក៏បានកកើតជាភូមិតូចមួយ ដោយដាក់ឈ្មោះថា ភូមិកោះឈើ-ទាលធំ ព្រោះនៅលើកោះនេះមានដើមឈើទាលធំៗដុះជាច្រើន ដើមឈើទាលទាំងនោះនៅមានវត្តមានរហូតមកដល់ពេលបច្ចុប្បន្ននេះ (១១ ខែ តុលា ឆ្នាំ ២០០៨) ។

ឆ្នាំ១៩៣០ សម័យបារាំងកាន់កាប់អ្នកភូមិមានការលំបាកដោយសារការបង់ពន្ធដារច្រើនពេក ពន្ធក្របី ពន្ធស្រែ ពន្ធមនុស្ស និងមានកំណែនឱ្យទៅធ្វើផ្លូវជាតិលេខ១៣ ពីស្ទឹងត្រែងទៅឡាវ ។ នៅពេលនោះមានជំងឺឈឺគ្រុនច្រើន គ្មានពេទ្យព្យាបាល អ្នកភូមិព្យាបាលដោយប្រើថ្នាំបុរាណ និងទៅទិញដូរសំភារៈនៅឡាវ ។

ឆ្នាំ១៩៣៨ សៀមចូលមកកាន់កាប់អស់រយៈពេល៥-៦ឆ្នាំ ជីវភាពអ្នកភូមិនៅតែលំបាកដដែល ពេលនោះមានកើតជំងឺកញ្ជ្រិល ផ្កាឈើ អុចធំ បណ្តាលអោយមនុស្សស្លាប់ទាំងចាស់ទាំងក្មេងជាង២០នាក់ ។

ឆ្នាំ១៩៤៥ សៀមដកទ័ពចេញ តែបារាំងចូលមកកាន់កាប់សារជាថ្មីម្តងទៀត ជីវភាពអ្នកភូមិកាន់តែលំបាកខ្លាំង ដោយសារមានកើតចោរលួច និងចោរប្លន់យកទ្រព្យសម្បត្តិ និងគោក្របីទៅលក់នៅប្រទេសសៀម ។

ឆ្នាំ១៩៥៤ បារាំងដកទ័ពចេញ ខ្មែរបានទទួលឯករាជ្យបរិបូរណ៍ អ្នកភូមិមាន-ជីវភាពធូរធារបន្តិច ព្រោះអាចដើររកស៊ីជិតឆ្ងាយបានដោយសេរី អំពើចោរលួចប្លន់ត្រូវបានស្ងប់ស្ងាត់ ។

ឆ្នាំ១៩៦២ អ្នកភូមិបាននាំគ្នាសាងសង់សាលារៀនបានមួយខ្នងពីរបន្ទប់ មានព្រះសង្ឃផ្លាស់ប្តូរវេនគ្នាធ្វើជាគ្រូបង្រៀន ។ ដំបូងមានព្រះសង្ឃព្រះនាម ហួន និង នឿ ជាគ្រូបង្រៀនដំបូងបង្អស់នៅលើកោះនេះ ហើយកូនចៅបានចេះអក្សរ និងនិយាយភាសាខ្មែរបានមួយចំនួនតាំងពីសម័យនោះមក ។ អ្នកភូមិពេលនោះមាន-ជីវភាពធូរធារ ធ្វើស្រែ ចំការបានផលច្រើន និងអាចយកផលទាំងនោះទៅលក់នៅផ្សារស្ទឹងត្រែង តែសម័យនោះពួកគាត់ធ្វើដំណើរតាមទូកចែវ ដោយដេកផ្លូវ ៣-៤ យប់ពេលទៅមកម្តង១ ។

ឆ្នាំ ១៩៦៩ កូនចៅអ្នកភូមិមិនបានរៀនសូត្រ ព្រោះពុំមានគ្រូបង្រៀន ។

ឆ្នាំ ១៩៧០ ស្រុកកើតសង្គ្រាម មានយន្តហោះអាមេរិច ( ជួយលន់ណុល ) បានបាញ់រះទម្លាក់គ្រាប់បែក អ្នកភូមិភ័យខ្លាចមិនហ៊ាននៅលើកោះ មួយចំនួនរត់ទៅនៅប៊ុងកក ( ព្រះរំកិល ) និងមួយចំនួនទៀតរត់គេចទៅនៅឡាវ ដោយមានជីវភាពក្រលំបាក ចេញដើររកស៊ី ធ្វើស្រែចំការមិនបាន ខ្វះអំបិលហូប ខ្វះសំលៀកបំពាក់ ខ្វះថ្នាំព្យាបាលជំងឺ ។

ឆ្នាំ ១៩៧៣ ដោយភូមិនេះស្ថិតនៅតាមព្រំដែន អង្គការខ្មែរក្រហមបានជំលៀសអ្នកភូមិចេញអស់ពីភូមិ ពួកវាយកភូមិធ្វើជាទីតាំងទ័ព អ្នកភូមិដែលពួកវាអោយ-ជំលៀសចេញខ្លះទៅនៅភូមិព្រះរំកិល ភូមិអូរារុន និងអូរវៃ មានជីវភាពក្រលំបាក ហូបរួម ធ្វើការងាររួម ហូបមិនឆ្អែត ធ្វើការធ្ងន់ អត់បាយ ឈឺស្លាប់អស់មួយចំនួន ។

ឆ្នាំ ១៩៧៩ ក្រោយថ្ងៃរំដោះ អ្នកភូមិបានវិលត្រឡប់មកភូមិកោះឈើទាលធំវិញ ពួកគាត់ជួបនូវបញ្ហាខ្វះជម្រក ក្រោយមកក៏នាំគ្នាសាងសង់ផ្ទះសាជាថ្មី ដោយធនធានព្រៃឈើនៅសំបូរនៅឡើយលើភូមិនេះ ។ រដ្ឋាភិបាលថ្មី បានជួយឧបត្ថម្ភ ចាន ឆ្នាំងក្រណាត់ ចប ប៉ែល ពូថៅ និងកាំ បិត ។ ទោះបីជីវភាពនៅមានការលំបាកយ៉ាងណាក៏ដោយ ក៏អ្នកភូមិអាចនេសាទត្រីយកមកធ្វើជាម្ហូបប្រចាំថ្ងៃបានគ្រប់គ្រាន់ ។

ឆ្នាំ ១៩៨២ អ្នកភូមិមានជីវភាពធូរធារជាងមុនបន្តិច ព្រោះមានសេរីភាពដើររកស៊ីខ្លះ ចេញចូលទៅឡាវ ដោះដូរយកទំនិញ និងសំភារៈបានមួយចំនួន ។

ឆ្នាំ ១៩៨៥-៨៦ អ្នកភូមិបានសហការគ្នាសាងសង់បានសាលារៀន១ខ្នង មាន២បន្ទប់ ស្រុកបញ្ជូនគ្រូមកពីឃុំអូរស្វាយ ជួយបង្រៀនអក្សរ និងភាសាខ្មែរដល់កូនចៅអ្នកភូមិ ប្រជាជនមានជីវភាពធូរធារ ដោយពួកគាត់បានដាំដំណាំរួមផ្សំ ធ្វើការនេសាទសំរាប់កែច្នៃជាប្រហុក ផ្អក ត្រីឆ្អើរ ទុកសំរាប់ហូបនៅរដូវបង្កបង្កើនផល ។

ឆ្នាំ ១៩៩០ មានពេទ្យចុះមកដល់ភូមិចាក់ថ្នាំការពារជងឺ៦មុខដល់កុមារ និងស្ត្រី ។

ឆ្នាំ១៩៩៣ អ្នកភូមិបានចូលរួមបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រលើកដំបូង ដែលរៀបចំឡើងដោយអ៊ុនតាក់ ។ ពួកគាត់មានមុខរបរថ្មីមួយទៀត គឺលក់ទិន្នផលត្រីដែលនេសាទបានទៅផ្សារវ៉ឺនខាម (ផ្សារព្រំដែនឡាវ-ខ្មែរ) អ្នកភូមិបានរៀបចំសង់ផ្ទះប្រក់ស័ង្កសី ខ្នងផ្ទះមានចំនួនកើនឡើង ដីស្រែបានពង្រីកបន្ថែម និងដីចំការមួយចំនួនទៀតត្រូវបានគាស់គល់លើកភ្លឺធ្វើជាស្រែ ។

ឆ្នាំ១៩៩៦ ជីវភាពត្រូវថយមួយកំរិតវិញដោយសារគោ ក្របី កើតជំងឺងាប់អស់ជាង៣០ក្បាល អ្នកភូមិខ្វះក្របីធ្វើស្រែ ជួលក្របីពីក្រៅភូមិយ៉ាងលំបាក ឯទិន្នផលត្រី-កាន់តែថយចុះ ។

ឆ្នាំ១៩៩៨ សម្តេចហ៊ុន សែន បានផ្តល់ជូននូវអំណោយសាលារៀន ១ ខ្នង មាន ៣ បន្ទប់ មន្ទីរអប់រំខេត្តបានបញ្ជូនគ្រូបង្រៀនចំនួន២នាក់ទៅបង្រៀនកូនចៅអ្នកភូមិ។ នៅឆ្នាំនោះដែរ មានទឹកជំនន់ជន់ជួន៧២ឆ្នាំ ធ្វើឱ្យលិចលង់ដំណាំ អ្នកភូមិត្រូវខ្វះស្រូវហូប ។ អ្នកភូមិក៏បានចូលរួមបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអណត្តិទី២ ។

ឆ្នាំ២000 មានទឹកជំនន់លិចលង់ខូចផលដំណាំម្តងទៀត ដែលបណ្តាលឱ្យអ្នកភូមិខ្វះស្រូវហូប ក្មេងកើតជំងឺជាច្រើនមានស្លាប់ខ្លះ ។

ឆ្នាំ២00១ អ្នកភូមិបានបោះឆ្នោតជ្រើសរើសគណៈកម្មការអភិវឌ្ឍន៏ភូមិ បាន៧រូប ស្ត្រី៣រូប និងបុរស៤រូប សំរាប់ដឹកនាំការងារអភិវឌ្ឍន៍ ការបោះឆ្នោតបានរៀបចំឡើងដោយមន្ទីរអភិវឌ្ឍន៏ជនបទខេត្ត ឧបត្ថម្ភដោយអង្គការដៃគូសំរាប់អភិវឌ្ឍន៏ PFD ។

ថ្ងៃទី ២៥ -២៨ ខែ មេសា ឆ្នាំ ២00១ មានក្រុមការងារចំរុះដែលឧបត្ថម្ភដោយ PFD បានចុះមកធ្វើសំរង់ព័ត៌មានដោយមានការចូលរួមពីអ្នកភូមិ ដើម្បីរៀបចំគំរោងអភិវឌ្ឍន៏ភូមិ ដែលហៅកាត់ថា ភី .អរ .អេ (PRA) ។

នៅថ្ងៃទី ១0-១១ ខែ សីហា ឆ្នាំ ២00២ មានក្រុមការងាររបស់សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ ហៅ កាត់ថា សេប៉ា ( CEPA ) សហការជាមួយការិយាល័យជលផលខេត្តបានចុះមកធ្វើសំរង់ព័ត៌មានអំពីធនធានធម្មជាតិ ជាពិសេសមច្ឆាជាតិដែលមានការចូលរួមពីសហគមន៍ ដើម្បីជួយសម្របសម្រួលបង្កើតជាសហគមន៏នេសាទក្នុងគោលបំណងអោយសហគមន៏ចេះលើកផែនការភូមិ និងធ្វើការអភិរក្សធនធានជលផល ។

(ដកស្រង់ចេញពីភីអ៊ិនអរអេ រៀបចំដោយសមាគមថែរក្សាបរិស្ថាន និងវប្បធម៌ ដែលចងក្រងឡើងដោយលោក ទូច វណ្ណារិទ្ធ និងត្រួតពិនិត្យបន្ថែមព័ត៌មានដោយ លោក តឹក វណ្ណារ៉ា មន្ត្រីគ្រប់គ្រងកម្មវិធីទំនាក់ទំនង និងស្រាវជ្រាវ)



ស្ថានភាពផ្ទះរបស់អ្នកស្រុកកោះឈើទាលធំ ខេត្តស្ទឹងត្រែង



ចងក្រងដោយ : លោក គិ វ៉ាន់សៃ អាយុ ៦០ឆ្នាំ

ប្រធានភូមិកោះឈើទាលធំ

ភូមិកោះឈើទាលធំ ឃុំព្រះរំកិល ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង

ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៨

ស្រូវ និងដំណាំចំរុះនៅក្នុងចំការស្រែរបស់អ្នកស្រុកសេកុង ក្នុងស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង





ស្ថានភាពព្រៃលិចទឹកក្នុងអាងទន្លេមេគង្គភាគខាងលើនៃខេត្តស្ទឹងត្រែង

# ១៤. ប្រវត្តិអន្លង់ក្នុងភូមិកោះឈើទាលធំ

នៅក្នុងភូមិសាស្ត្រភូមិកោះឈើទាលធំ ក្នុងទន្លេមេគង្គមានអន្លង់ត្រីចំនួន៥ ដែលអន្លង់ទាំងនេះ បានផ្តល់ជាប្រភពត្រីដ៏សំខាន់សំរាប់ផ្គត់ផ្គង់ជីវភាពរស់នៅរបស់អ្នកភូមិ និងដៃរបស់វា ព្រមទាំងទន្លេសាបផងដែរ ។ អន្លង់សំខាន់៧ទាំងនោះ គឺ:

**១. អន្លង់ថ្ម (ទាំងហ៊ីន):** អន្លង់នេះមានទទឹង៥០ម៉ែត្រ បណ្តោយ៨០ម៉ែត្រ និងជម្រៅ៣៥ម៉ែត្រនៅរដូវវស្សា និង២៥ម៉ែត្រនៅរដូវប្រាំង ហើយអន្លង់នេះមានចម្ងាយប្រមាណ៣០ម៉ែត្រពីច្រាំងទន្លេ ។ អន្លង់ថ្មសំបូរទៅដោយត្រីគ្រប់ប្រភេទ ប៉ុន្តែត្រីច្រើនជាងគេ គឺត្រីប្រា និងត្រីក្អែក ។

មូលហេតុដែលគេហៅអន្លង់នេះថា អន្លង់ថ្ម ដោយសារមានថ្មជាច្រើនដុំដុះនៅជុំវិញអន្លង់ ។

**២. អន្លង់ស្អាត់ស្វា (ឡាត់លីង):** អន្លង់ស្អាត់ស្វាមានបណ្តោយ១០០ម៉ែត្រ និង ទទឹង៥០ម៉ែត្រ ។ អន្លង់នេះមានជម្រៅ៣០ម៉ែត្រនៅរដូវវស្សា និង២៥ម៉ែត្រនៅរដូវប្រាំង ហើយមានទីតាំងនៅខាងកើតភូមិកោះឈើទាលធំ ។ អន្លង់នេះសំបូរត្រីមេពូជគ្រប់ប្រភេទ ប៉ុន្តែប្រភេទត្រីដែលអ្នកនេសាទឧស្សាហ៍ចាប់បានច្រើនជាងគេគឺត្រីឆ្អិន ត្រីកេស និងត្រីជ្វៀត ។

កាលពីជំនាន់ដើមមានសត្វស្វាជាច្រើនក្បាលតែងតែចុះមកស៊ីស្រូវ និងដំណាំរបស់ប្រជាជន ជាពិសេសសត្វស្វាទាំងនោះបានចុះផឹកទឹកក្នុងអន្លង់ជារៀងរាល់ថ្ងៃបន្ទាប់ពីចូលលួចស៊ីដំណាំ និងស្រូវរបស់ប្រជាជន ។ អ្នកភូមិភាគច្រើនបាននាំគ្នាទៅស្កាត់ដេញស្វាកុំឱ្យចូលមកស៊ីស្រូវ និងដំណាំរបស់ខ្លួននៅត្រង់ចំនុចអន្លង់ដែលស្វាចុះផឹកទឹក ដូច្នេះទើបតំណក្រោយមក អ្នកភូមិនាំគ្នាឱ្យឈ្មោះអន្លង់នោះថា ជា

អន្លង់ស្អាត់ស្វាតរៀងមក។

**៣. អន្លង់ស្ដៅផ្អែម (ទើនផាកាដៅវ៉ាន):** អន្លង់ស្ដៅផ្អែមមានទទឹង៨០ម៉ែត្រ និងបណ្ដោយ១៥០ម៉ែត្រ ហើយមានជម្រៅនៅរដូវវស្សា៤០ម៉ែត្រ និងនៅរដូវប្រាំង៣០ម៉ែត្រ។ អន្លង់នេះមានទីតាំងនៅខាងកើតភូមិកោះឈើទាលធំ ហើយសំបូរត្រីជ្រូត។

មានតំណាលមួយថា កាលពីសម័យដើម នៅមាត់អន្លង់ស្ដៅផ្អែម មានដើមស្ដៅធំមួយដើមដុះនៅក្បែរមាត់អន្លង់។ អ្នកភូមិកោះឈើទាលធំ តែងតែទៅបេះផ្កាស្ដៅមកបរិភោគជារៀងរាល់ឆ្នាំ នារដូវស្ដៅផ្កា។ ផ្កាស្ដៅនោះមានរសជាតិខុសពីផ្កាស្ដៅដទៃ ដោយវាពុំមានរសជាតិល្វីងទេ តែផ្ទុយមកវិញ វាមានរសជាតិផ្អែម ដែលនេះជាហេតុផលធ្វើឱ្យអ្នកភូមិគ្រប់ៗគ្នាចូលចិត្តបរិភោគផ្កាស្ដៅនេះជាពន់ពេក។ ពួក-គាត់តែងតែនាំគ្នាទៅបេះយកមកបរិភោគមិនដែលខានឡើយ។ ដោយការបេះយក-ហួសហេតុ បានធ្វើឱ្យដើមស្ដៅផ្អែមនោះងាប់ បន្ទាប់ពីការប្រមូលផលបានរយៈពេល៥ឆ្នាំ។ អ្នកភូមិមានការសោកស្ដាយជាខ្លាំង ដោយសារការងាប់របស់ស្ដៅផ្អែម ហើយផ្ដើមរំលឹកអនុស្សាវរីយ៍ និងដឹងគុណ ចំពោះដើមស្ដៅផ្អែម ដែលធ្លាប់តែផ្ដល់ជាអាហារដ៏ឆ្ងាញ់ចំពោះអ្នកភូមិ ពួកគាត់ក៏នាំគ្នាដាក់ឈ្មោះឱ្យអន្លង់នៅជាប់ដើមស្ដៅផ្អែមនោះថា អន្លង់ស្ដៅផ្អែមរៀងមក។

**៤. អន្លង់តាអួន :** អន្លង់តាអួនមានទទឹង៦០ម៉ែត្រ បណ្ដោយ១០០ម៉ែត្រ ហើយមានជម្រៅនៅរដូវវស្សា៣៥ម៉ែត្រ និងរដូវប្រាំង២៥ម៉ែត្រ។ អន្លង់នេះមានទីតាំងនៅខាងកើតជាប់ភូមិកោះឈើទាលធំ។ អន្លង់តាអួនសំបូរទៅដោយត្រីគ្រប់ប្រភេទ ប៉ុន្តែត្រីដែលមានវត្តមានច្រើនជាងគេ គឺត្រីប្រា និងត្រីកេស។

មូលហេតុដែលអ្នកភូមិដាក់ឈ្មោះអន្លង់នេះថា អន្លង់តាអួន ដោយសារតាអួន គឺជាមនុស្សមុនដំបូងគេ ដែលបានមករៀបចំផ្ទះសំបែងស្នាក់នៅជាប់នឹងមាត់អន្លង់។ ដូច្នេះក្រោយពេលដែលតាអួនស្លាប់ទៅ អ្នកភូមិបានហៅអន្លង់នេះ ថាអន្លង់តាអួនដរាបមក ដោយយោងលើហេតុផលថា តាអួនគាត់ធ្លាប់រស់នៅជាប់អន្លង់ទឹកនេះ ហើយបានបង្កើតឈ្មោះកំពង់ទឹកមួយឈ្មោះថា កំពង់ទឹកតាអួនផងដែរ។

**៥. អន្លង់គោលបាក់ (វើនម៉មហាំក) :** អន្លង់គោលបាក់មានបណ្ដោយ និងទទឹងប្រវែង៥០ម៉ែត្រ ហើយមានជម្រៅ៤០ម៉ែត្រនៅរដូវវស្សា និង៣០ម៉ែត្រនៅរដូវប្រាំង។ អន្លង់នេះមានទីតាំងខាងកើតជាប់នឹងកោះឈើទាលធំ និងនៅខាងលើក្បាលកោះព្នៅ។ ប្រភេទត្រីដែលសំបូរជាងគេ នៅក្នុង អន្លង់នេះ គឺត្រីផ្ទាកក្ដា និងត្រីកែ។

អ្នកភូមិហៅ អន្លង់នេះ ថាអន្លង់គោលបាក់ ដោយពួកគាត់យោង និងសំអាងថា មានបង្គោលបារាំង[១] បាក់ធ្លាក់ចូលទៅក្នុងអន្លង់នេះ ដូច្នេះទើបអ្នកភូមិឱ្យឈ្មោះអន្លង់នេះ ថាអន្លង់គោលបាក់ជារៀងមក។



ចងក្រងដោយ : លោក ចុង កែវ
ប្រធានសហគមន៍នេសាទ ភូមិកោះឈើ
ទាលធំ ខេត្តស្ទឹងត្រែង

---

១. បង្គោលបារាំង : ជាបង្គោលដែលកសាងឡើងក្នុងសម័យបារាំងធ្វើអាណានិគមនិយមមកលើស្រុកខ្មែរ។ ការកសាងបង្គោលនេះក្នុងគោលបំណងចង្អុលបង្ហាញសំរាប់ការបើកនាវាចរណ៍(កប៉ាល់) នៅរដូវប្រាំងរបស់បារាំងនៅក្នុងទន្លេមេគង្គ)។ ប្រសិនបើគ្មានបង្គោលបារាំងនេះទេ ការបើកបរកប៉ាល់របស់បារាំង នារដូវប្រាំងពិតជាជួបនូវការលំបាកជាក់ជាមិនខាន ព្រោះតំបន់ទន្លេមេគង្គលើប្រទេសកម្ពុជា សម្បូរទៅដោយថ្មប៉ប្រះទឹក ទឹកជ្រូរ ទឹកកួច និងជ្រូរថ្មជាច្រើនកន្លែងចាប់ពីខេត្តក្រចេះរហូតដល់ព្រំដែនខ្មែរ-ឡាវ។

# ១៥. បង្គោលបារាំង

បង្គោលបារាំងត្រូវបានអ្នកធ្វើដំណើរតាមទូក កាណូត ឬកប៉ាល់ បណ្តោយទន្លេមេគង្គពីភ្នំពេញទៅកាន់ព្រំដែនខ្មែរ-ឡាវ អាចមើលឃើញចាប់ពីខេត្តក្រចេះឡើងរហូតដល់ព្រំដែនខ្មែរ-ឡាវ។ បង្គោលនេះ ត្រូវបានបារាំងកសាងឡើងក្នុងសម័យដែលប្រទេសបារាំងធ្វើអាណានិគមនិយមមកលើប្រទេសខ្មែរពីចន្លោះឆ្នាំ ១៨៦៣-១៩៥៣។ ការកសាងបង្គោលនេះឡើងក្នុងបំណងដើម្បីធ្វើការចង្អុលបង្ហាញផ្លូវថា ផ្លូវណាមួយនៅក្នុងអាងទន្លេមេគង្គភាគខាងលើពីខេត្តក្រចេះរហូតដល់ព្រំដែនខ្មែរ-ឡាវ អាចបើកបរកប៉ាល់ ឬកាណូតធំៗបាននារដូវរាំងរដូវប្រាំង។

ត្រង់ចំនុចចាប់ពីខេត្តក្រចេះរហូតដល់ព្រំប្រទល់ខ្មែរ-ឡាវនៅក្នុងខេត្តស្ទឹងត្រែងត្រូវបានអ្នកភូមិវិទ្យាឱ្យឈ្មោះថា ទន្លេមេគង្គលើនៃប្រទេសកម្ពុជា។ ភូមិសាស្ត្រទន្លេមេគង្គលើមានសភាពលំបាកស្មុគ្រស្មាញក្នុងការធ្វើដំណើរតាមទឹកណាស់ពីព្រោះវាសំបូរទៅដោយថ្មប៉ប្រះទឹក អន្លង់ត្រីជ្រៅ ទឹកកួច ទឹកជួរ និងជួរថ្មជាច្រើន ដែលអាចបង្កជាគ្រោះថ្នាក់គ្រប់បែបយ៉ាងដល់អ្នកធ្វើដំណើរ ប្រសិនបើអ្នកបើកកប៉ាល់ ឬអ្នកធ្វើដំណើរនោះមិនបានស្គាល់ច្បាស់លាស់នូវភូមិសាស្ត្រនៃទន្លេមេគង្គភាគខាងលើជាមុននោះទេ។ មូលហេតុទាំងនេះ ហើយទើបបង្ខំឱ្យបារាំងចាក់បង្គោលថ្មឡើងឱ្យផុតពីទឹកប្រមាណពី៣ ទៅ៥ម៉ែត្រ បើធៀបនឹងកម្ពស់ទឹកនៅរដូវប្រាំង។

បារាំងបានគិតជាស្រេចថា បារាំងធ្វើអាណានិគមមកលើតំបន់ឥណ្ឌូចិន ក្នុងបំណងមហិច្ឆតាមួយទៀត ដើម្បីយកទន្លេមេគង្គធ្វើជាផ្លូវដើម្បីបន្តពង្រីកអណានិគមរបស់ខ្លួនរហូតដល់ប្រទេសចិន ប៉ុន្តែបំណងរបស់បារាំងមិនបានទទួលជោគជ័យទេ ដោយទីតាំងភូមិសាស្ត្រទន្លេមេគង្គភាគខាងលើមានស្ថានភាពលំបាកក្នុងការដឹកគ្រឿងសព្វាវុធ និង

កម្លាំងដើម្បីពង្រីកអំណាចរបស់ខ្លួន ជាពិសេសត្រង់ចំនុចល្បាក់ខោន គឺមិនអាចអនុញ្ញាតឱ្យកប៉ាល់ ឬកាណូតធ្វើដំណើរឆ្លងកាត់បានទេ។ ទាំងនេះហើយដែលជាឧបសគ្គសំខាន់ៗដែលរារាំងដល់បារាំងក្នុងការពង្រីកអាណានិគមរបស់ខ្លួននៅក្នុងតំបន់ទន្លេមេគង្គ។

ដូច្នេះនៅពេលដែលលោក លោកស្រីធ្វើដំណើរតាមដងទន្លេមេគង្គភាគខាងលើនោះ លោក លោកស្រី នាងកញ្ញា នឹងមើលឃើញបង្គោលទាំងនោះជាក់ជាមិនខាន។ សំរាប់ពេលបច្ចុប្បន្ន បង្គោលបារាំងបានសម្រួលដល់ការប្រាប់ផ្លូវក្នុងការធ្វើដំណើរ និងនាវាចរណ៍កម្ពុជាយ៉ាងល្អប្រសើរនារដូវប្រាំង។ សំរាប់ខែវស្សា យើងមិនអាចមើលឃើញបង្គោលបារាំងទេ ព្រោះទឹកឡើងលិច។ ហើយបច្ចុប្បន្ននេះ បង្គោលបារាំងក៏ត្រូវបានអ្នកនេសាទប្រើប្រាស់វាធ្វើជាបង្គោលសំរាប់ដាក់មងបណ្តែត ដើម្បីចាប់ត្រីធំៗផងដែរ នៅតាមបណ្តោយដងទន្លេមេគង្គភាគខាងលើ។

បង្គោលបារាំងនាពេលបច្ចុប្បន្នបានក្លាយទៅជាសម្បត្តិវប្បធម៌មួយរបស់អ្នកស្រុកមេគង្គលើដែលរស់នៅក្នុងខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ដែលអ្នកភូមិតែងតែនិយាយតគ្នាថា បង្គោលបារាំងគឺជាអនុស្សាវរីយ៍ដ៏ផ្អែមល្ហែម និងជូរចត់ផងដែររវាងអ្នកស្រុកមេគង្គលើ និងបារាំងដែលជាអាណាព្យាបាលនាក្នុងសម័យនោះ ព្រោះថាទំរាំកើតបានជាបង្គោលនេះ បារាំងបានកេណ្ឌប្រជាជននៅក្នុងខេត្តស្ទឹងត្រែង និងក្រចេះឱ្យធ្វើការចាក់បង្គោលនៅក្នុងទឹក ដែលបញ្ហានេះបានបង្កឱ្យមានគ្រោះថ្នាក់ជាច្រើនដល់ប្រជាពលរដ្ឋខ្មែរនៅក្នុងខេត្តទាំងនោះ។

ជាមួយគ្នានេះដែរ បង្គោលបារាំង តែងតែបង្ហាញប្រាប់ដល់អ្នកនេសាទយ៉ាងច្បាស់ថាដល់រដូវដែលអ្នកនេសាទអាចនេសាទត្រីហើយ ព្រោះត្រីប៉ាស៊ីអ៊ី និងត្រីផ្សេងៗបានឡើងពីទន្លេសេកុង សេសាន និងស្រែពកចូលមកក្នុងទន្លេមេគង្គ ហើយវាក៏ប្រាប់

ដល់រដូវត្រីចុះផងដែរ  តាមរយៈស្នាមត្រីរៃ៍ត្រាលើបង្គោលបារាំង  ដែលស្នាមខ្លះមានពណ៌ក្រហម និងស្នាមខ្លះទៀតមានពណ៌ក្រមៅ។ អ្នកនេសាទទាំងឡាយ ដែលនេសាទត្រីតាមដងទន្លេមេគង្គ  កាលបើឃើញស្នាមត្រីរៃ៍ត្រានៅតាមបង្គោលបារាំងហើយ ពួកគេសប្បាយរីករាយណាស់ ហើយសង្ឃឹមថា ការចុះទៅនេសាទរបស់គេ នឹងទទួល-បានទិន្នផលត្រីជាច្រើនជាក់ជាមិនខានឡើយ។ ដូច្នេះ អ្នកនេសាទតែងតែរូតរះចុះទៅនេសាទកាលបើឃើញសញ្ញាទាំងនោះហើយ។

ចំណុចពិសេសមួយទៀត  ដែលសល់ពីសម័យអាណានិគមបារាំង  នោះគឺកំពង់ផែសំរាប់ដោះដូរទំនិញ ។ ប្រសិនបើយើងធ្វើដំណើរទៅដល់ព្រំដែនខ្មែរ-ឡាវ តាមទន្លេមេគង្គ នោះយើងនឹងឃើញកំពង់ផែចាស់មួយ  ដែលបច្ចុប្បន្នស្ថិតនៅក្នុងទឹកដីឡាវ។ កំពង់ផែនេះហើយ  គឺជាចំណតសំរាប់ផ្លាស់ប្តូរទំនិញរបស់កប៉ាល់បារាំងរវាងប្រទេសឡាវ និងខ្មែរ ក៏ដូចជា រវាងទន្លេមេគង្គភាគខាងលើ និងទន្លេមេគង្គភាគខាងក្រោមផងដែរ។ មូលហេតុ ដែលបារាំងបង្កើតឱ្យមានកំពង់ផែនេះ គឺដោយសារភូមិសាស្ត្រតំបន់ល្បាក់ខោនក្នុងអាងទន្លេមេគង្គមិនបង្កលក្ខណៈឱ្យកប៉ាល់ដឹកទំនិញរបស់បារាំងឆ្លងកាត់រួច។ ដូច្នេះ ចង់ ឬមិនចង់ បារាំងត្រូវបង្កើតកំពង់ផែមួយដើម្បីដោះដូរទំនិញ ឬផ្ទេរទំនិញរវាងប្រទេសដែលស្ថិតនៅខ្សែទឹកខាងក្រោម  និងខ្សែទឹកខាងលើនៃទន្លេមេគង្គ។



ស្រាវជ្រាវ និងសរសេរដោយ : លោក  តឹក  វណ្ណារ៉ា
មន្ត្រីគ្រប់គ្រងកម្មវិធីទំនាក់ទំនង និងស្រាវជ្រាវ
នៃសមាគមថែរក្សាបរិស្ថាន និងវប្បធម៌, ភូមិកោះល្វេ
ឃុំព្រះរំកិល ស្រុក ថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង
ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៨

# ១៦. ប្រវត្តិភូមិវ៉ីនសៀន

ភូមិ វ៉ីន សៀន ជាភូមិមួយតូចនៅលើកោះ ខនហាង។ នៅខាងលិចភូមិមាន អន្លង់មួយជ្រៅ ទឹកហូរវិលចុះវិលឡើង ដែលប្រជាជនបានហៅអន្លង់នោះជាភាសាឡាវ ថា វ៉ីនសៀន មានន័យជាភាសាខ្មែរថា អន្លង់ទឹកសង ឬទឹកវិល។

ក្នុងភូមិសាស្ត្រនៃភូមិវ៉ីនសៀនមានព្រៃលិចទឹក អន្លង់ជ្រៅៗ ថ្មធំៗ កោះធំ តូចៗ រដិបរដុប ជាអំណោយផលល្អសំរាប់ការរស់នៅ និងពងកូនរបស់មច្ឆាជាតិ ។ ព្រៃលើកោះ ព្រៃត្រើយខាងកើតកោះសំបូរសត្វព្រៃណាស់ដូចជា : ដំរី ខ្លា រមាស ខ្ទីង គោ ព្រៃ។ល។

នៅឆ្នាំ១៩៥២ ប្រជាជនមកពីកោះក្រឡាយ កោះហិប និងភូមិផ្សេងៗទៀត ចំនួន៤-៥គ្រួសារ បានមកតាំងទីលំនៅលើដីភូមិម្តុំមាត់អន្លង់នោះក៏នាំគ្នាហៅភូមិនេះថា **ភូមិវ៉ីនសៀន** រហូតមកដល់សព្វថ្ងៃ។ តាំងពីដើមមក ភូមិនេះ មិនសូវមានអ្នកចំណូលថ្មីទេ ដោយសារជាកូនភូមិតូចស្ថិតនៅក្នុងព្រៃឆ្ងាយពីគេ។ នៅក្នុងឆ្នាំដដែលនេះ ប្រទេសកម្ពុជា ទាំងមូលស្ថិតនៅក្រោមនឹមអាណានិគមបារាំង ឯអ្នកភូមិវ៉ីន សៀនបានត្រូវគេកែនយកទៅ ធ្វើផ្លូវជាតិលេខ១៣ ពីស្ទឹងត្រែងទៅកាន់ព្រំដែនឡាវ ខណៈនោះអ្នកភូមិមានជីវភាពក្រ លំបាកណាស់ ព្រោះគាត់ត្រូវបង់ពន្ធជូនរដ្ឋ។

ឆ្នាំ១៩៥៤-១៩៦០ ខ្មែរបានទទួលឯករាជ្យពីបារាំង អ្នកភូមិមានជីវភាពធូរធារ បន្តិចព្រោះមិនបាច់បង់ពន្ធដារ។ ប៉ុន្តែមានការលំបាកនៅពេលមានជម្ងឺម្តងៗ គ្មានថ្នាំ សង្កូវ គ្មានពេទ្យព្យាបាល។

ឆ្នាំ១៩៦៣-១៩៦៩ មានថៅកែម្នាក់ឈ្មោះ **ឆោម** ជាថៅកែឈើហ៊ុបមកកាប់ឈើ ធ្វើដេប៉ូដាក់នៅក្នុងភូមិនេះ។ អ្នកភូមិមានជីវភាពធូរធារបន្តិចដោយសារប្រកបរបរធ្វើ ស្រែចំការបានផលបង្គួរ។

ឆ្នាំ១៩៧០-១៩៧៤ លន់ណុលធ្វើរដ្ឋប្រហារទំលាក់សម្តេចឪ អ្នកភូមិភ័យខ្លាច យ៉ាងខ្លាំង ហើយបានរត់ទៅជ្រកពួននៅកោះក្រឡាយ ដោយសារយន្តហោះទំលាក់ គ្រាប់បែកដែលធ្វើឱ្យជីវភាពគាត់កាន់តែក្រលំបាក អត់បាយ អត់អំបិល គ្មានថ្នាំសង្កូវ គ្មានពេទ្យព្យាបាលរស់នៅដោយគ្មាន សេរីភាព។

ឆ្នាំ១៩៧៥-១៩៧៨ របបខ្មែរក្រហមកាន់កាប់ បានបញ្ជូនអ្នករ៉ុនសៀនឱ្យត្រឡប់មករស់នៅក្នុងភូមិវិញ មិនត្រឹមតែប៉ុណ្ណោះបានបញ្ជូនប្រជាជនផ្សេងៗមករស់នៅបន្ថែមទៀត។ អ្នកភូមិមានជីវភាពរស់នៅលំបាកវេទនាបំផុត ដោយធ្វើស្រែចំការរួម ហូបរួម រស់នៅជាសហករណ៍រួមគ្នា ហើយនាពេលនោះក៏មានទឹកជំនន់លិចលង់ស្រែចំការច្បារដំណាំ ដែលជាហេតុធ្វើឱ្យខ្វះស្បៀងអាហារ ទើបគាត់នាំគ្នាទៅជាហូបក្ដួច ដំឡូងព្រៃជាអាហារជំនួសវិញ។ ក្នុងសម័យកាលនោះស្ត្រី ក៏ត្រូវធ្វើការធ្ងន់ ដូចបុរសដែរ ទាំងក្នុងពេលមានផ្ទៃពោះក៏មិនបានសំរាក ហើយសំរាលកូនក៏មិនបានសំរាកយូរ គ្មានចំណីអាហារហូបបំប៉នគ្រប់គ្រាន់។ ក្រុមគ្រួសារត្រូវរស់នៅបែកឆ្ងាយពីគ្នា អ្នកភូមិមួយចំនួនបានជំលៀសចេញពីភូមិទៅធ្វើស្រែនៅភូមិគីឡូប្រាំបី អូរនរោង ញ៉ើន អូរពូក និងគុជចំបក់។

ឆ្នាំ១៩៧៩-១៩៨០ ក្រោយថ្ងៃរំដោះ ៧ មករា អ្នកភូមិបានបែកគ្នា ដោយសារខ្មែរក្រហមបញ្ជូនយកទៅព្រំដែនខ្មែរ-សៀម តែដោយសារកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិ ២ ធ្នូ បានសហការជាមួយកងទ័ពវៀតណាម បានរំដោះឱ្យអ្នកភូមិត្រឡប់មករស់នៅក្នុងភូមិវិញ។ ប្រជាជនរស់នៅក្នុងជីវភាពប្រសើរជាងមុន ប៉ុន្តែក្នុងការធ្វើស្រែចំការ គាត់នៅមានការលំបាកដោយសារខ្វះកំលាំងអូសទាញ និងសំភារៈធ្វើស្រែចំការ។

ឆ្នាំ១៩៨០-១៩៨២ អ្នកភូមិធ្វើស្រែរួម បានផលចែកគ្នាតាមកំលាំងពលកម្ម ក្នុងនោះគ្រួសារខ្លះចាប់ផ្ដើមចិញ្ចឹមសត្វជ្រូក មាន់ ទា ក្របី ។

ឆ្នាំ១៩៨២-១៩៩០ អ្នកភូមិបានឯកភាពសាងសង់សាលារៀនចំនួន២កន្លែង ដោយសាលាទី១ បាំងជញ្ជាំងសំបកឈើ មានបណ្ដោយ៦ម៉ែត្រ ទទឹង៥ម៉ែត្រ ដំបូលប្រក់ស្បូវ។ ឯសាលាទី២ បាំងជញ្ជាំងឫស្សី មានបណ្ដោយ៨ម៉ែត្រ ទទឹង៦ម៉ែត្រ ដំបូលប្រក់ស្បូវ។ នៅឆ្នាំ១៩៨៤ សាលាទី១ បានខូចខាតអស់ដោយសារដីទាប ទឹកលិចពុកជញ្ជាំងឫស្សី ពុកសរសរ មិនអាចបង្រៀន រីឯសាលាទី២ ខូចខាតនៅឆ្នាំ១៩៩០ ដោយ-សារគ្រូចូលនិវត្តន៍ គ្មានអ្នកគ្រប់គ្រងថែរក្សា។ នៅក្នុងឆ្នាំដដែលនេះ មានគ្រោះទឹកជំនន់ដែលបណ្ដាលឱ្យខូចខាតផលស្រូវ ជម្ងឺរាគត្បាតបណ្ដាលឱ្យស្លាប់មនុស្សអស់១៥នាក់ ចាប់ពីអាយុ៦ឆ្នាំ ដល់ ១០ឆ្នាំ ដោយសារជម្ងឺកញ្ជ្រិល និងរាគមូល។ ចំពោះសត្វក្របីជាច្រើនក្បាលងាប់ដោយ ជម្ងឺអុតក្ដាម ដែលជាហេតុធ្វើឱ្យខ្វះកំលាំងអូសទាញក្នុងការធ្វើកសិកម្ម។ យ៉ាងណាមិញ ជំនឿទៅលើការសែនព្រេនអ្នកតាព្រៃភ្នំ នៅពេលមាន

មនុស្សឈឺ ឬសត្វឈឺគឺ ធ្វើមិនដែលខានទេដោយសារគាត់គិតថាមកពីខុសអ្នកតា ប៉ុន្តែការសែនព្រេននេះជួនកាលជា ជួនកាលក៏មិនជា។ ទន្ទឹមនឹងការសែនព្រេន ថ្នាំបុរាណ ដូច-ជាសំបកឈើ ស្លឹកឈើ គាត់ក៏បានយកមកប្រើប្រាស់សំរាប់ព្យាបាលដែរ។

ឆ្នាំ១៩៩០-១៩៩៩ លទ្ធិប្រជាធិតេយ្យសេរីពហុបក្ស រីឯនៅក្នុងភូមិបានកើនផ្ទះចំនួន៣ខ្នងទៀត។ ឯការប្រកបរបរធ្វើស្រែចំការ ប្រជាជននៅខ្វះកំលាំងអូសទាញ ដូច្នេះ-គាត់ក៏នៅតែជួលក្របីពីអ្នកក្នុង និងក្រៅភូមិ ដោយក្របី១ក្បាល ត្រូវសងវិញជាស្រូវ ១៧០គីឡូក្រាម ក្រោយពេលប្រមូលផលរួច។ ក្នុងឆ្នាំនេះដែរ អ្នកភូមិបានសាងសង់សាលាឆទានមួយខ្នងមានបណ្តោយ៧ម៉ែត្រ ទទឹង៦ម៉ែត្រ ជញ្ជាំងបាំងឫស្សី ដំបូលប្រក់ស្បូវទុកសំរាប់បង្រៀនសិស្ស និងធ្វើបុណ្យទានផ្សេងៗ ក្នុងភូមិ។ បន្ទាប់ មកមានអង្គការ-ជាច្រើនដូចជា **YWAM; PFD** បានចុះផ្តល់ថ្នាំការពារជម្ងឺ៦មុខ ដល់កុមារ និងផ្តល់ថ្នាំ ការ-ពារជម្ងឺដល់ស្ត្រី និងការចុះធ្វើផែនការអភិវឌ្ឍសហគមន៍។

ឆ្នាំ២០០២ សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ (សេប៉ា) បានចុះសំរង់ព័ត៌មានលើធនធានធម្មជាតិដោយមានការចូលរួម ពីមន្ត្រីការិយាល័យជលផលខេត្ត និងស្ថាប័នពាក់ព័ន្ធជាច្រើនទៀតដើម្បីលើកផែនការការពារ និងអភិរក្សធនធានធមជាតិដោយមានការចូលរួម។ បន្ទាប់មកទៀតបានបង្កើតសហគមន៍នេសាទ និងសហគមន៍ព្រៃឈើដែលសំរបសំរួលដោយអង្គការសេប៉ា។ រហូតដល់ពេលបច្ចុប្បន្ននេះ ប្រជាជននៅភូមិរ៉ុនសៀនកើនបានចំនួន៣៦គ្រួសារ ក្នុងនោះការធ្វើស្រែចំការ ការរកអនុផលព្រៃឈើ ការរកត្រីគឺនៅតែជាអាទិភាពសំរាប់ពួកគាត់រកទទួលទាន និងបង្កើនប្រាក់ចំណូលក្នុងគ្រួសារនីមួយៗ។

គំរោងសាលាភូមិរបស់អង្គការសេប៉ា CEPA សហការជាមួយកម្មវិធីអភិរក្សជីវៈចម្រុះ តំបន់ដីសើមទន្លេមេគង្គ **MWBP** គឺជាគំរោងថ្មីមួយដែលចូលរួមដោយអ្នកស្រាវជ្រាវនៅក្នុងភូមិ។ គំរោងនោះចាប់ផ្តើមអនុវត្តនៅក្នុងខែឧសភាឆ្នាំ២០០៥ ដោយធ្វើការសិក្សាស្រាវជ្រាវទៅលើ ប្រភេទត្រី និងជីវភាពរស់នៅ ។



ចងក្រងដោយ : អ្នកមីង ចាន់ ជន
មេភូមិរ៉ុនសៀន ឃុំ អូរស្វាយ ស្រុក ថាឡាបរិវ៉ាត់
ខេត្តស្ទឹងត្រែង, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨

# ១៧. អន្លង់ក្នុងភូមិវ៉ឺនសៀន

នៅភូមិវ៉ឺនសៀន មានអន្លង់ត្រី ចំនួន១២ ដែលកំពុងផ្ដល់ជាប្រភពធនធានសំរាប់ផ្គត់ផ្គង់ជីវភាពដល់អ្នកភូមិ ប្រជាជនតាមដងទន្លេមេគង្គ និងជាជម្រកត្រីមេពូជសំរាប់ចែកចាយដល់ដៃទន្លេមេគង្គ ទន្លេសាប និងទន្លេ ស៊ឹង និងព្រែកផ្សេងៗទៀតផងដែរនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ជាពិសេសជាងនេះទៅទៀត អន្លង់ទាំងនោះជាជម្រកពងកូនរបស់ត្រី និងសត្វទឹកជាច្រើនប្រភេទនៃទន្លេមេគង្គ។

**១.អន្លង់វ៉ឺនសៀន** : អន្លង់វ៉ឺនសៀន មានទទឹង៥០ម៉ែត្រ និងបណ្ដោយ១៥០ម៉ែត្រ ហើយមានជម្រៅ១២ម៉ែត្រនៅរដូវប្រាំង និង២០ម៉ែត្រនៅរដូវវស្សា។ អន្លង់នេះសំបូរដោយត្រីគ្រប់ប្រភេទ ប៉ុន្តែត្រីដែលអ្នកនេសាទក្នុងភូមិនេសាទបានភាគច្រើនគឺ ត្រីអំបូង ត្រីត្រសក់ ត្រីរស់ និងត្រីឆ្លាំង។

**២.អន្លង់វ៉ឺនផូង (ចាំផូង)** : អន្លង់វ៉ឺនផូង មានទទឹង១៥០ម៉ែត្រ និងបណ្ដោយ១០០ម៉ែត្រ[១] ហើយអន្លង់នេះមានជម្រៅ២៤ម៉ែត្រនារដូវវស្សា និង១២ម៉ែត្រនៅរដូវប្រាំង។ អន្លង់នេះសំបូរទៅដោយត្រីកេស និងត្រីក្រាយ។

**៣.អន្លង់ក្រាក់ (ចុំនហ្វា)**: អន្លង់ក្រាក់មានទទឹង១៥០ម៉ែត្រ និងបណ្ដោយ

---

១. មូលហេតុដែលអ្នកភូមិកំនត់ឱ្យទទឹងអន្លង់វែងជាងបណ្ដោយអន្លង់ ដោយសារពួកគាត់គិតតាមទិសនៃលំហូរទន្លេមេគង្គពីលើចុះមកក្រោម ហើយទទឹងគិតពីប្រវែងអន្លង់ទទឹងទន្លេ ដូច្នេះអន្លង់ខ្លះមានទទឹងវែងជាងបណ្ដោយ គឺអាស្រ័យទៅតាមភូមិសាស្ត្រជាក់ស្ដែងនៃអន្លង់នីមួយៗ

៣០០ម៉ែត្រ ហើយអន្លង់នេះមានជម្រៅ២៣ម៉ែត្រនៅរដូវប្រាំង និង៣៥ម៉ែត្រនៅរដូវវស្សា។ អន្លង់ក្រាក់សំបូរទៅដោយត្រីខ្យា ត្រីឆ្លាំង និងត្រីកញ្ចុះ។

មូលហេតុដែលអ្នកភូមិហៅអន្លង់នៅថា អន្លង់ក្រាក់ ដោយសារកាលពីសម័យដើមមានដើមរំចែងយ៉ាងធំ មួយដើមបានងាប់ហើយដួលធ្លាក់ក្នុងអន្លង់នេះ រួចក្លាយជាឈើក្រាក់ ។ ឃើញដូច្នេះ ទើបអ្នកភូមិរ៉ុនសៀន ហៅអន្លង់នេះថាអន្លង់ក្រាក់ចាប់តាំងពីពេលនោះមក។

**៤.អន្លង់ក្រាក់តូច (ម៉ុនហ្វាណក):** អន្លង់ក្រាក់តូច មានទទឹង៨០ម៉ែត្រ និងបណ្តោយ១០០ម៉ែត្រ ហើយមានជម្រៅ៥ម៉ែត្រនៅរដូវប្រាំង និង១៥ម៉ែត្រនៅរដូវវស្សា។ អន្លង់នេះសំបូរទៅដោយត្រីប្រា និងត្រីឆ្ពិន។ អន្លង់ក្រាក់តូចមានទីតាំងជាប់នឹងអន្លង់ក្រាក់។

**៥.អន្លង់ក្បាលកោះចិក:** អន្លង់ក្បាលកោះចិកមានទទឹង១៥ម៉ែត្រ និងបណ្តោយ៦០ម៉ែត្រ ហើយមានជម្រៅ៦ម៉ែត្រនៅរដូវប្រាំង និង១៥ម៉ែត្រនៅរដូវវស្សា។ អន្លង់ក្បាលកោះចិកសំបូរត្រីគ្រប់ប្រភេទ ប៉ុន្តែត្រីដែលអ្នកភូមិនេសាទបានច្រើនគឺ ត្រីកេសត្រីឆ្តោ ត្រីពោធិ៍ និងត្រីផ្ទក់។

មូលហេតុដែលអ្នកភូមិរ៉ុនសៀនហៅអន្លង់នេះថា អន្លង់ក្បាលកោះចិក ដោយសារកាលពីសម័យដើម មានអ្នកជំនួញចិន ចេញចូលធ្វើជំនួញ ទៅមករវាងស្រុកឡាវកម្ពុជា និងវៀតណាមដោយធ្វើដំណើរតាមទូកក្នុងទន្លេមេគង្គ។ សម័យថ្ងៃមួយទូកជំនួញចិនបានលិចនៅត្រង់ចំនុចអន្លង់មួយ លុះក្រោយពីព្រឹត្តិការណ៍នោះមក អ្នកភូមិរ៉ុនសៀនបាននាំគ្នាហៅអន្លង់នោះថា ជាអន្លង់ក្បាលកោះចិករហូតតរៀងមក។

ពាក្យថា ចិក គឺអ្នកភូមិគាត់ហៅសំដៅទៅលើជនជាតិចិន ដែលជាម្ចាស់ទូកដែលមានវ័យចាស់ជាង ដែលភាសាខ្មែរមានន័យថា ពូ។

**៦.អន្លង់ទឹកក្រហម (ម៉ុងណាមដែង) :** អន្លង់ទឹកក្រហមមានទទឹង១៣ម៉ែត្រ និងបណ្ដោយ៦០ម៉ែត្រ។ អន្លង់នេះមានជម្រៅ៥ម៉ែត្រនារដូវប្រាំង និង១៥ម៉ែត្រនៅរដូវវស្សា។ អន្លង់ទឹកក្រហមសំបូរទៅដោយត្រីជាច្រើនប្រភេទ ប៉ុន្ដែប្រភេទត្រីដែលអ្នកភូមិនេសាទបានភាគច្រើន គឺត្រីប្រា ត្រីពោធិ៍ និងត្រីក្អែក។

មូលហេតុដែលអ្នកភូមិហៅអន្លង់នេះថា ជាអន្លង់ទឹកក្រហម ដោយសារនៅសម័យដើម អន្លង់នេះមានខ្មោចទឹករស់នៅ ហើយជារៀងរាល់ព្រឹកម៉ោង ១០ និងម៉ោង៤ល្ងាច អ្នកនេសាទតែងតែឃើញទឹកក្នុងអន្លង់នេះឡើងពណ៌ក្រហមដូចជាឈាមមនុស្សអញ្ចឹង ហេតុដូច្នេះហើយទើបអ្នកនេសាទឱ្យឈ្មោះអន្លង់នេះថាជាអន្លង់ទឹកក្រហមតាំងពីពេលនោះតរៀងមក។

**៧.អន្លង់វែង (ម៉ុងវែង) :** អន្លង់វែងមានទទឹង៥០ម៉ែត្រ និងបណ្ដោយ៣០០ម៉ែត្រ ហើយមានជម្រៅ៦ម៉ែត្រនៅរដូវប្រាំង និង១៥ម៉ែត្រនារដូវវស្សា។ អន្លង់នេះសំបូរទៅដោយត្រីគ្រប់ប្រភេទ ហើយប្រភេទត្រីដែលអ្នកនេសាទតែងតែនេសាទបានជាញឹកញាប់គឺត្រីប៉ាសេអ៊ី និងត្រីប៉ាវ៉ា។

មូលហេតុដែលអ្នកនេសាទ និងអ្នកភូមិឱ្យឈ្មោះអន្លង់នេះថា ជាអន្លង់វែង ដោយសារអន្លង់នេះមានប្រវែងវែងជាងអន្លង់ដទៃផ្សេងទៀតនៅក្នុងភូមិសាស្រ្តភូមិរ៉ឺនសៀន។

**៨.អន្លង់ស្រែយាយនូ (ប៊ុងណែនូ)** : អន្លង់ស្រែយាយនូ មានទទឹង២៥ម៉ែត្រ និងបណ្តោយ១០០ម៉ែត្រ ហើយមានជម្រៅ៦ម៉ែត្រនៅរដូវប្រាំង និង១៥ម៉ែត្រនារដូវវស្សា។ អន្លង់នេះសំបូរទៅដោយត្រីឆ្លាត និងត្រីគ្រុំ។

មូលហេតុដែល អ្នកភូមិឱ្យឈ្មោះអន្លង់ថា ជាអន្លង់យាយនូ ដោយសារតាំងពីដើមមក យាយនូ គាត់មកប្រកបរបរកសិកម្មមានស្រែ និងចំការនៅលើកោះខនកែវ ដែលមានទីតាំងនៅជាប់នឹងអន្លង់ ហើយជាពិសេសយាយនូ គាត់បានប្រើប្រាស់ទឹកអន្លង់នេះសំរាប់ការផ្គត់ផ្គង់ទឹកប្រចាំថ្ងៃក្នុងការរស់នៅរបស់គាត់ ដូច្នេះទើបនៅពេលដែលយាយនូស្លាប់ទៅ អ្នកភូមិបានឱ្យឈ្មោះអន្លង់នោះថា ជាអន្លង់យាយនូតាំងពីពេលនោះមក ដោយយកឈ្មោះយាយនូ មកដាក់ជាឈ្មោះអន្លង់។

**៩.អន្លង់ពោធិ៍ព្រុយ (ប៊ុងប៉ាឡើម)** : អន្លង់ពោធិ៍ព្រុយមានទទឹង២០ម៉ែត្រ និងបណ្តោយ១០០ម៉ែត្រ ហើយអន្លង់នេះមានជម្រៅ៤ម៉ែត្រ នៅរដូវប្រាំង និងជម្រៅ១៥ម៉ែត្រ នៅរដូវវស្សា។ អន្លង់នេះសំបូរទៅដោយប្រភេទត្រីប្រាពោធិ៍។

មូលហេតុ ដែលអ្នកនេសាទហៅអន្លង់នេះថា ជាអន្លង់ពោធិ៍ព្រុយ ដោយសារអន្លង់នេះសំបូរទៅដោយត្រីពោធិ៍ព្រុយ។

**១០.អន្លង់ក្បាលកោះក្រឡាយ (ប៊ុងហ៊ីជនខឡាយ)** : អន្លង់ក្បាលកោះស្រឡាយមានទទឹង២៥០ម៉ែត្រនិងបណ្តោយ១០០ម៉ែត្រ ហើយអន្លង់នេះមានជម្រៅ៥ម៉ែត្រនៅរដូវប្រាំង និង១៥ម៉ែត្រនៅរដូវវស្សា។ អន្លង់នេះសំបូរទៅដោយត្រីឆ្កិន និងត្រីក្រាយ។ មូលហេតុដែលអ្នកភូមិ និងអ្នកនេសាទហៅអន្លង់នេះថា ជាអន្លង់ កោះក្រឡាយដោយសារអន្លង់នេះមានទីតាំងស្ថិតនៅជាប់នឹងក្បាលកោះក្រឡាយ ដូច្នេះ

ហើយទើបអ្នកភូមិហៅឈ្មោះអន្លង់នេះតរៀងមក។

**១១.អន្លង់ត្រីព្រួល (ប៊ុងបាំផន)** : អន្លង់ត្រីព្រួលមានទទឹង១៥០ម៉ែត្រ និងបណ្តោយ៣០០ម៉ែត្រ ហើយអន្លង់នេះមានជម្រៅ៥ម៉ែត្រនៅខែប្រាំង និង១២ម៉ែត្រនៅរដូវវស្សា។ អន្លង់នេះសំបូរទៅដោយប្រភេទត្រីព្រួល ។

មូលហេតុដែលអ្នកភូមិ ហៅអន្លង់នេះថា អន្លង់ត្រីព្រួល ដោយសារតាំងពីដើមរហូតមកដល់ពេលបច្ចុប្បន្ន អន្លង់សំបូរទៅដោយត្រីព្រួល ទើបអ្នកភូមិនាំគ្នាហៅដូច្នេះជារៀងរហូតមក។

**១២.អន្លង់តាព្រហ្ម (ប៊ុងតាភុម)** : អន្លង់តាព្រហ្មមានទទឹង៧០ម៉ែត្រ និងបណ្តោយ១២០ម៉ែត្រ ហើយអន្លង់នេះមានជម្រៅ៥ម៉ែត្រនៅរដូវប្រាំង និង១២ម៉ែត្រនៅរដូវវស្សា។ អន្លង់តាព្រហ្មសំបូរទៅដោយប្រភេទត្រីឆ្តោ និងត្រីប៉ាសេអ៊ី។ មូលហេតុដែលអ្នកភូមិហៅអន្លង់នេះថា អន្លង់តាព្រហ្ម ដោយសារអន្លង់នេះ មានទីតាំងនៅជាប់ក្បាលកោះតាភឹម ហើយអ្នកភូមិឱ្យឈ្មោះទី២ឱ្យតាភឹមថា ជាព្រហ្មដូច្នេះនៅពេលដែលតាភឹម ឬតាព្រហ្មស្លាប់ទៅ អ្នកភូមិ និងអ្នកនេសាទដាក់ឈ្មោះអន្លង់នេះតាំងពីពេលនោះមក។



ចងក្រងដោយ : លោក ញឹម សៀន អាយុ ៤២ឆ្នាំ
ភូមិរ៉ុនសៀន ឃុំ អូរស្វាយ ស្រុក ថាឡាបរិវ៉ាត់
ខេត្តស្ទឹងត្រែង
ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨

# ១៨. ប្រវត្តិភូមិកោះហិប

ភូមិកោះហិបមានប្រជាជនរស់នៅលើកោះពីរ មួយកោះក្រឡាយ និងមួយទៀតកោះហិប ដែលចំណុះភូមិតែមួយ គឺភូមិកោះហិប ។ ភូមិកោះហិបមាន តំណាលដូចតទៅ :

កាលពីសម័យដើមមានព្រះមហាក្សត្រមួយអង្គមានឫទ្ធានុភាពយ៉ាងខ្លាំងពូកែប្រកបដោយទសពិធរាជធម៌ ដែលធ្វើឱ្យប្រទេសជាតិមានភាពសុខសាន្ត ប្រជារាស្ត្រមានជីវភាពធូរធារ។ ក្រោយពីព្រះអង្គសោយរាជ្យមួយរយៈកាលមក និងបានរៀបចំប្រទេសជាតិរឹងមាំមក ព្រះអង្គក៏បានផ្ទេររាជសម្បត្តិទៅឱ្យបុត្រច្បងជាអ្នកបន្តវេនក្នុងការដឹកនាំ និងសោយរាជ្យបន្ត។ ចំណែកព្រះអង្គវិញ ព្រះអង្គបានសំរេចព្រះទ័យ និងសព្វព្រះរាជហឫទ័យទៅបួសជាសង្ឃវិញ ក្នុងបំណងដើម្បីពង្រឹងវិស័យពុទ្ធចក្រ ដើម្បីឱ្យវិស័យនេះមានការរីកចំរើន និងបានចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍សង្គម និងចិត្តគំនិតខ្មែរនាសម័យនោះ។ បួសជាព្រះសង្ឃព្រះអង្គបានកសាងប្រាសាទមួយ ហៅថាប្រាសាទ ( ថាទូផាណុំ ) ពេលដែលកសាងរួចរាល់ហើយ ក៏ប្រារព្ធធ្វើពិធីបញ្ចុះសីមា ដោយបានប៉ាវគងហៅបណ្តាអ្នកខ្លាំង ពូកែអោយទៅចូលរួមក្នុងពិធីបុណ្យដោយយកសំភារៈបញ្ចុះសីមាទៅជាមួយផង ។ ពេលដល់វេលាដែលត្រូវបញ្ចុះសីមានោះ អ្នកនៅឆ្ងាយដែលទៅមិនទាន់ពេលដែលឮគេទូងស្គរហើយនោះ ក៏យកហិបនិងសំភារៈដែលមានដូចជា : កែវកង មាសប្រាក់ ទុកនៅលើកោះនេះតែម្តង ។ ក្រោយមកគេក៏អោយឈ្មោះកោះនេះថាជា កោះហិបតៗមក ។

ឆ្នាំ១៩១០ មានយាយតាពីរនាក់ឈ្មោះ ( តាព្រុំ យាយដែង ) បានមកតាំងទីលំនៅលើកោះនេះ បន្ទាប់មកកោះនេះបានក្លាយទៅជាភូមិមួយ ហើយគេក៏ដាក់ឈ្មោះភូមិនេះថា ភូមិកោះហិប រៀងរហូតមក ។

ឆ្នាំ១៩៦៤ ប្រជាពលរដ្ឋនៅភូមិកោះហិបនេះ កាលពីមុននៅត្រើយខាងកើត ក្រោយមកដោយសារច្រាំងទន្លេចេះតែបាក់ ក៏នាំគ្នាផ្លាស់ទីមកនៅត្រើយខាងលិចវិញ ដែលមានចំនួនតែ១០គ្រួសារ និងកម្លាំងអូសទាញ (ក្របី) តែ៣០ក្បាលប៉ុណ្ណោះ ហើយអ្នកភូមិប្រកបរបរធ្វើស្រែចំការ នេសាទត្រី និងរកអនុផលព្រៃឈើ ដោយមានជីវភាពរស់នៅគ្រប់គ្រាន់ ។

នៅក្នុងភូមិសាស្ត្រនៃភូមិកោះហិបមានអន្លង់ត្រីចំនួន៣កន្លែង គឺអន្លង់ទឹកវិល អន្លង់អូរជ្រៃ និងអន្លង់ស្វាយ ។

**អន្លង់ទឹកវិល (ប៊ុងកាតែតក)** : អន្លង់នេះមានបណ្តោយ៣គីឡូម៉ែត្រ និងទទឹង៦០០ម៉ែត្រ ហើយមានជម្រៅ៣០ម៉ែត្រនៅរដូវប្រាំង និង៤០ម៉ែត្រនៅរដូវវស្សា។ អន្លង់នេះសំបូរទៅដោយត្រីគ្រប់ប្រភេទដូចជា ត្រីឆ្លាំង ត្រីគ្រុំ ត្រីក្អែក និង ត្រីប្រាជាដើម។ មូលហេតុដែលអ្នកភូមិហៅអន្លង់នេះថាជាអន្លង់ទឹកវិល គឺដោយសារទឹកនៅក្នុងអន្លង់នេះវិលទាំងនៅក្នុងរដូវប្រាំង និងរដូវវស្សា។

**អន្លង់អូរជ្រៃ (ប៊ុងហ្លួយហៃ)**: អន្លង់នេះមានបណ្តោយ១៥០ម៉ែត្រ និងទទឹង៤០ម៉ែត្រ ហើយមានជម្រៅ៣០ម៉ែត្រនៅរដូវប្រាំង និង៤០ម៉ែត្រនៅរដូវវស្សា។ អន្លង់នេះសំបូរទៅដោយត្រីខ្យា និងត្រីកេស។ អ្នកភូមិហៅអន្លង់អូរជ្រៃ គឺពួកគាត់ហៅ តាមឈ្មោះអូរជ្រៃដែលមានទីតាំងនៅក្បាលនៃអន្លង់នេះ។

**អន្លង់ស្វាយ** : អន្លង់នេះ មានបណ្តោយ៥០ម៉ែត្រ និងទទឹង៧០ម៉ែត្រ ហើយមានជម្រៅ៧ម៉ែត្រនៅរដូវប្រាំង និង១៥ម៉ែត្រនៅរដូវវស្សា។ អន្លង់នេះសំបូរ

ទៅដោយត្រីឆ្លាត និងត្រីខ្ទឹង។ នៅមាត់អន្លង់មានដើមស្វាយចេកដ៏ធំមួយដើម យើញ ដូច្នេះទើបអ្នកភូមិកោះហិបនាំគ្នាហៅអន្លង់នេះថា អន្លង់ស្វាយតរៀងរហូតមក។

ជាមួយនឹងគ្នានេះដែរ នៅក្នុងភូមិកោះហិប មានកោះពីរដែរ គឺកោះក្រឡាយ និងកោះតាហៀង។ កោះក្រឡាយមានបណ្តោយប្រវែង២.៥គីឡូម៉ែត្រ និងទទឹងប្រវែងមួយគីឡូម៉ែត្រ។ នៅលើកោះនេះ ប្រជាជនបានប្រកបរបរធ្វើស្រែ និងចំការជាច្រើនហិកតា ជាពិសេសមានប្រជាជនប្រមាណ២០គ្រួសារ កំពុងរស់នៅជាប្រចាំ។ ចំណែកឯកោះតាហៀងវិញ មានបណ្តោយប្រវែង៣០០ម៉ែត្រ និងទទឹង៧០ម៉ែត្រ។ នៅលើកោះ ប្រជាជននៅភូមិកោះហិបបាននាំគ្នាទៅដាំពោត និងចេក ដោយឆ្នាំៗគឺដំណាំទាំងនេះ ដាំមិនទៀងទាត់ជារៀងរាល់ឆ្នាំនោះទេ ឆ្នាំខ្លះដាំ និងឆ្នាំខ្លះមិនបានដាំ អាស្រ័យលើរបបទឹកនៃទន្លេមេគង្គ។ ដូច្នេះអន្លង់៣ និងកោះទាំងពីរនេះ បានផ្តល់ជាប្រភពចំណីអាហារដ៏ច្រើនសន្ធឹកសន្ធប់សំរាប់ការរស់នៅប្រចាំថ្ងៃរបស់អ្នកភូមិកោះហិប។



ចងក្រងដោយ : លោក មី ភី អាយុ ៥៨ ឆ្នាំ
មេភូមិកោះហិប ឃុំ អូរស្វាយ ស្រុក ថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង
ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨

# ១៩. កំពង់ឆ្កែ

**កំពង់ឆ្កែ** ជាឈ្មោះកំពង់ទឹកមួយកន្លែង ដែលមានទីតាំងភូមិសាស្ត្រនៅភូមិកោះហិប និងភូមិកោះស្នែង ឃុំអូរស្វាយ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។ កំពង់ទឹកនេះមានតំណាលថា កាលពីសម័យដើម មានឆ្កែព្រៃញីឈ្មោល ១គូ រស់នៅជាមួយគ្នានៅក្នុងព្រៃខាងក្រោយនៃភូមិកោះស្នែង។ ឆ្កែមួយគូនេះ ពិតមែនវាជាឆ្កែព្រៃ ប៉ុន្តែវាមានលក្ខណៈស្លូតដូចជាសត្វឆ្កែស្រុក ដែលចិញ្ចឹមដោយអ្នកភូមិដែរ។ ឆ្កែទាំងពីរតែងតែយកអាសារដល់អ្នកស្រុកដែលចូលទៅប្រមូលអនុផលព្រៃឈើនៅតំបន់ជ្រៅៗ ហើយពួកគាត់វង្វេងផ្លូវ មិនអាចរកផ្លូវត្រឡប់មកផ្ទះវិញឃើញ ពួកគាត់តែងតែឃើញឆ្កែទាំងពីរនោះ មករត់នាំផ្លូវ ឬបង្ហាញផ្លូវពួកគាត់ ឱ្យរកឃើញផ្លូវត្រឡប់ទៅផ្ទះវិញជានិច្ច។ អ្នកភូមិតែងតែហៅឆ្កែឈ្មោលថាអាខ្មៅ ដោយយោងទៅលើសម្បុររបស់វាមានលក្ខណៈខ្មៅសុទ្ធ ហើយឆ្កែញីថា មីត្នោត ដោយសារឆ្កែញីមានសម្បុរត្នោត។ អ្នកភូមិដែលចូលប្រមូលអនុផលព្រៃឈើទាំងអស់តែងតែសរសើរ និងស្រលាញ់ចំពោះអាខ្មៅ និងមីត្នោតជានិច្ច ជាពិសេសពួកគាត់តែងតែចែករំលែកបាយ និងអាហារពីមាត់របស់ពួកគាត់ចំពោះឆ្កែឧស្សាហ៍ទាំងពីរជានិច្ច។

លុះក្រោយមក អាខ្មៅ និងមីត្នោត បង្កើតបានកូនមួយឈ្មោះអាតឿ។ អាតឿមានលក្ខណៈខុសពីមេ និងបារបស់វា ដោយមានជើង និងកខ្លី។ វាមានសម្បុរសលាយត្នោត។ អាតឿ ពិតតែមាឌតឿមែនពិត ប៉ុន្តែចិត្តរបស់វាល្អ ដូចជាមេ និងបាអញ្ចឹងដែរ គឺវាតែងតែរត់ទៅតាមមេបា ដើម្បីជួយបង្ហាញផ្លូវដល់អ្នកវង្វេងផ្លូវដើម្បីជួយប្រាប់ទិសនៃផ្លូវដែលត្រូវត្រឡប់ទៅផ្ទះវិញ។ អ្នកដើរព្រៃគ្រប់ៗគ្នាអាណិត និងស្រឡាញ់អាតឿ ដូចជាមេ និងបារបស់វាដែរ។

នៅសម័យនៃរដូវមួយ ទឹកទន្លេមេគង្គជន់លិចព្រៃ ដែលជាលំនៅដ្ឋានរបស់អាខ្មៅ និងមីត្នោត ជាពិសេសនៅក្នុងពេលជាមួយគ្នានោះ មានព្យុះ និងភ្លៀងជាច្រើនមេផ្ទួនៗគ្នា បន្ថែមជាមួយរន្ទះបាញ់ជាច្រើនរយគ្រាប់នៃតំបន់ព្រៃនោះទៀត បានធ្វើឱ្យអាខ្មៅ និងមីត្នោត ពិគ្រោះយោបល់គ្នា ដើម្បីគេចចេញពីគ្រោះធម្មជាតិចង្រៃនេះ។ ក្រោយគិតគ្នារួចរាល់ ឆ្កែឈ្មោល (អាខ្មៅ) និងឆ្កែញី (មីត្នោត) សំរេចចិត្តនាំអាតឿ ដែលជាកូនគេចចេញពីតំបន់គ្រោះថ្នាក់នោះ ដើម្បីឆ្លងទៅត្រើយម្ខាងនៃទន្លេមេគង្គ សំរាប់ស្វែងរកជម្រកថ្មី ដែលមានទីតាំងល្អសំរាប់ការរស់ជាថ្មី។ អាខ្មៅបានសំរេចចិត្តហែលទឹកទៅមុន មីត្នោត និងអាតឿជាកូន ដើម្បីពិនិត្យមើលស្ថានភាពនៃទឹកទន្លេ និងទីកន្លែងដែលហែលទៅអាចមានសុវត្ថិភាពល្អសំរាប់ឱ្យប្រពន្ធ និងកូនធ្វើដំណើរតាមក្រោយ។ ក្រោយពីហែលឆ្លងផុតទន្លេមេគង្គទៅត្រើយម្ខាងរួច អាខ្មៅបានបក់កន្ទុយធ្វើជាសញ្ញាឱ្យមីត្នោត និងអាតឿ ហែលតាមផ្លូវដែលខ្លួនគេបានហែលមកគឺមានសុវត្ថិភាពល្អណាស់។ ដោយឃើញសញ្ញាកន្ទុយរបស់អាខ្មៅភ្លាម មីត្នោត និង-អាតឿ ក៏ចាប់ផ្តើមចុះហែលទឹកសំដៅត្រើយម្ខាងតាមផ្លូវរបស់ប្តី និងឪពុកភ្លាម។ គ្រាន់តែចាប់ផ្តើមចុះហែលទឹកទន្លេមេគង្គបានបន្តិចពីត្រើយម្ខាង ស្រាប់តែមានខ្យល់ព្យុះមួយបោកបក់មកយ៉ាងខ្លាំង បង្កើតបានជាទឹករលកធំៗ និងទឹកទន្លេហូរកួចយ៉ាងខ្លាំង ដែលធ្វើឱ្យមីត្នោត និងអាតឿ មិនអាចជំនះទប់ទល់នឹងកម្លាំងធម្មជាតិបាន ក៏ដាច់ខ្យល់ស្លាប់នៅក្បែរច្រាំងទន្លេដែលពួកគេចាប់ផ្តើមហែលមក នៅទីនោះតែម្តងទៅ។ ចំណែកអាខ្មៅវិញ គ្រាន់តែឃើញមីត្នោត និងអាតឿ ដែលត្រូវជាប្រពន្ធ និងកូនស្លាប់នៅក្បែរមាត់ច្រាំងនៃត្រើយទន្លេម្ខាង គេក៏ចាប់ផ្តើមទ្រហោយំសោកបោកខ្លួនយ៉ាងខ្លាំង ហើយលូវែងៗ តាមភាសាឆ្កែ ប្រហែលជាមានន័យថា ទេវតាអើយ ហេតុអ្វីបានជាអយុត្តិធម៌អ្វីម្លេះ មកឆក់យកតែជីវិតឆ្កែល្អ ចំណែកឯឆ្កែចចកដែលជាឆ្កែ

អាក្រក់ ចាំតែស៊ីសាច់សត្វមានជីវិតដទៃ និងលួចឆក់ដណ្ដើមចំណីអាហារពីប្រភេទសត្វទន់ខ្សោយយកមកបរិភោគ និងធ្វើជារបស់ខ្លួន បែរជាទេវតា និងព្រះឥន្ទ្រអនុញ្ញាតឱ្យពួកគេរស់នៅស្រួល ដោយប្រទានព្រៃភ្នំខ្ពស់ៗ គ្មានទឹកជំនន់អាចលិចបានទៅវិញ ចំណែកខ្លួនអាត្មាអញ ប្រពន្ធ និងកូនដែលជាសត្វល្អ ឆ្អែល្អ មិនហ៊ានស៊ីសាច់ជាអាហារ និងធ្វើតែអំពើបុណ្យកុសលជាមួយមនុស្សគ្រប់ពេលវាលាទាំងអស់ បែរជាព្រះឥន្ទ្រ និងទេវតាដាក់ទណ្ឌកម្មឱ្យព្រាត់ប្រាស់គ្នាទៅវិញ។ តើមានយុត្តិធម៌ឬទេ ចំពោះសត្វដែល-សាងតែអំពើល្អ ហើយមកទទួលផលបែបនេះទៅវិញ។ ក្រោយពីទួញសោក បោកប្រាណ និង រៀបរាប់អស់ចិត្ត អាខ្មៅក៏បានសំរេចចិត្តបោកក្បាលសំលាប់ខ្លួនទៅតាមមីឆ្មោត និងអាតឿ ដែលត្រូវជាប្រពន្ធ និងកូនរបស់ខ្លួន។

ក្រោយពីការសម្លាប់ខ្លួនរបស់អាខ្មៅ ដំណឹងនេះក៏ឮដល់ព្រះឥន្ទ្រា ដែលជាស្ដេចអស់ទេវតា។ ព្រះឥន្ទ្រា បានកោះហៅទេវតា រន្ទះ ផ្គរ ភ្លៀង និងអារក្សមកសួរអំពីសោកនាដកម្មរបស់ក្រុមគ្រួសារអាខ្មៅ។ ទេវតាផ្គរឮដូច្នេះក៏ភិតភ័យជាខ្លាំង ហើយលុតជង្គង់សំពះសុំទោសព្រះឥន្ទ្រាយ៉ាងប្រញាប់ ដោយទូលថា ប៉ុន្មានថ្ងៃមុនខ្លួនបានសោយទឹកចន្ទច្រើន (ភាសាទេវតា គឺហៅថា ទឹកចន្ទ ប៉ុន្តែភាសាមនុស្សហៅថា ស្រា) ពេក ហើយជាពិសេសមានទេពអប្សរបានចូលមកជួប និងផ្គាប់ផ្គន់ខ្លួន ដែលធ្វើឱ្យខ្លួនជាទេវតាផ្គរភ្លេចអស់តួនាទី និងភារកិច្ចរបស់ខ្លួន ដែលត្រូវបំពេញដើម្បីជួយដល់ការរស់នៅរបស់មនុស្ស និងសត្វលោក។ ដោយសារការស្រវឹងបាត់សតិរបស់ខ្លួន ជាពិសេសចង់បង្ហាញឫទ្ធិអំណាចរបស់ខ្លួនឱ្យស្រីទេពអប្សរមើលផង ទេវតាផ្គរ ក៏ចាប់ផ្ដើមធ្វើការវាយផ្គរតាមចិត្តរបស់ខ្លួន ដោយមិនបានទូលសុំការអនុញ្ញាតពីព្រះឥន្ទ្រា។ ទេវតាផ្គរទូលព្រះឥន្ទ្រមិនទាន់ចប់ផង ស្រាប់តែទេវតារន្ទះលុតជង្គង់ភ្លាមរួចសារភាពកំហុសរបស់ខ្លួនថា ខ្លួនក៏មានកំហុសដែរ គឺបានផ្ដល់សញ្ញារន្ទះជាច្រើនពាន់

ផ្គូនៗ ដោយមិនបានសួរនាំទេវតាផ្គរឱ្យបានច្បាស់លាស់ និងមិនបានពិនិត្យមើលផែនការផ្តល់ចំនួនសញ្ញារន្ទះឱ្យគ្រប់ជ្រុងជ្រោយ ជាពិសេសមិនបានសុំយោបល់ពីព្រះឥន្ទ្រា ដែលវាជាមូលហេតុមួយនៃការស្លាប់របស់គ្រួសារអាខ្មៅដែរ។ ចំណែកទេវតាភ្លៀងវិញ មានការភិតភ័យជាខ្លាំង ហើយទូលទៅព្រះឥន្ទ្រាទាំងអួលអាក់ថា ខ្ញុំព្រះបាទ បានរត់ទៅសុំចូលគាល់ព្រះអង្គ ដើម្បីផ្តល់ចំនួនទឹកភ្លៀងតាមផែនការ ហើយជាពិសេស ខ្ញុំដឹងថា ទេវតាផ្គរ រន្ទះ បានធ្វើខុសផែនការដែរ ព្រោះចំនួនផ្គរលាន់ និងចំនួនផ្លេកបន្ទោលដែលបញ្ចេញដោយទេវតារន្ទះមានការខុសចំនួន និងចង្វាក់គ្នា។ ប៉ុន្តែនៅពេលដែលទូលព្រះបង្គំសុំចូលគាល់ ដើម្បីសុំព្រះយោបល់ពីព្រះអង្គជាបន្ទាន់ ស្រាប់តែទេវតាថែរក្សាព្រះដំណាក់ប្រាប់ទូលបង្គំថា ព្រះអង្គរវល់ខ្លាំងណាស់ កំពុងតែប្រលែងលេងជាមួយអ្នកម្នាង និង សោយទឹកចន្ទជាច្រើន ដែលមូលហេតុទាំងអស់នេះហើយ ទើបទូលព្រះបង្គំពុំមានលទ្ធភាពទប់ស្កាត់ដល់ទេវតាផ្គរ និងរន្ទះ។ ឮបន្ទូលរបស់ទេវតាភ្លៀងទូលដូច្នេះ ព្រះឥន្ទ្រាចប់យោបល់ដែរ ព្រោះវាជាកំហុសរបស់ខ្លួនមួយផ្នែកដែរ។ ដើម្បីបង្វែរការអាម៉ាស់របស់ខ្លួន ព្រះឥន្ទ្រាក៏មានបន្ទូលសួរទៅអារក្សទឹក ដែលជាម្ចាស់ទឹកគ្រប់គ្រងនៅក្នុងទន្លេមេគង្គវិញម្តងថា មើលលោកអារក្សទឹក លោកឃើញហេតុការណ៍ដូច្នេះហើយ ហេតុអ្វីបានជាលោកមិនជួយសង្គ្រោះអាខ្មៅ មីត្នោត និងអាតឿផង ហេតុអ្វីបានជាទុកបណ្តោយឱ្យពួកវាស្លាប់ទាំងអយុត្តិធមិដូច្នេះ ដែលនេះជាការអាម៉ាស់មុខរបស់លោក និងយើងណាស់ណា? អារក្សទឹក មានបន្ទូលទូលទៅព្រះឥន្ទ្រាយ៉ាងសុភាពរាបសាថា បពិត្រព្រះឥន្ទ្រា ដែលជាម្ចាស់ឋានទាំងបី ទូលព្រះបង្គំជ្រាបថា ហេតុការណ៍ដែលបានកើតឡើងចំពោះគ្រួសារឆ្កែខ្មៅ វាមានភាពអយុត្តិធមិ និងវាជាទណ្ឌកម្មមួយមិនសមស្របទាល់តែសោះ។ ទូលបង្គំចង់ជួយសង្គ្រោះដែរ ប៉ុន្តែគ្មានបញ្ជាពីថ្នាក់លើ ដូចជាទេវតាផ្គរ រន្ទះ និងភ្លៀងជាដើម ហើយស្ថានការណ៍នៅពេល

នោះដូចជាបន្ទាន់ពេក ដែលមើលទៅឃើញដូចជាទណ្ឌកម្មរបស់ថ្នាក់លើដាក់ឱ្យគ្រួសារអាខ្មៅ ទើបទូលបង្គំមិនហ៊ានជួយ។ ទូលព្រះបង្គំមានកំហុសមួយកាលពីជាងមួយសតវត្សមុន ដោយសារជួយយកអាសារប្រជារាស្ត្រស្លូតត្រង់នៅក្នុងភូមិមួយដែលមានគ្រោះទឹកជំនន់។ ទង្វើល្អរបស់ទូលបង្គំនាពេលនោះ ត្រូវបានពពួកទេវតា និងព្រះអង្គស្តីបន្ទោសដល់ទូលបង្គំជាខ្លាំង ដោយចោទថា ទូលព្រះបង្គំមិនគោរពបញ្ជា ហើយចេះតែជួយប្រជារាស្ត្រស្រេចតែចិត្តឯង ដោយមិនសុំការអនុញ្ញាតពីព្រះអង្គ និងពពួកទេវតាដែលមានឋានៈនៅពីលើ។ ឆ្លងតាមបទពិសោធន៍ទាំងនេះ ទើបទូលព្រះបង្គំមិនហ៊ានអន្តរាគមន៍ចំពោះរឿងគ្រួសារអាខ្មៅ ខ្លាចត្រូវព្រះអង្គ និងពពួកទេវតាស្តីបន្ទោសឱ្យទូលព្រះបង្គំជាខ្ញុំទៀត។ ឮបន្ទូលតបរបស់អារក្សទឹកដូច្នេះ ព្រះឥន្ទ្រាកប់យោបល់ដែរ ពីព្រោះពីមុនមក ខ្លួនបានប្រព្រឹត្តិយ៉ាងដូច្នេះមែន ដោយគិតថា ព្រះអង្គមានអំណាចខ្លាំងជាងគេ ហើយរាល់ការគិតរបស់ព្រះអង្គគឺល្អជាងពពួកទេវតាដទៃទៀតដែលនៅក្រោមបង្គាប់បញ្ជារបស់ព្រះអង្គ។

ក្រោយពីស្តាប់ការបកស្រាយរបស់ពពួកទេវតា និងអារក្សទឹករួចមក ព្រះឥន្ទ្រា មានព្រះបន្ទូលថា យើងទាំងអស់គ្នាមានកំហុសរួមដូចគ្នា គឺដោយសារយើងធ្លាក់ក្នុងអំពើអប្បាយមុខលើសម្រស់ស្រីទេពអប្សរ ស្រា ល្បែង និងបក្សពួកនិយម ដោយភ្លេចខ្លួន ហើយលំហូរព័តិមាន និងការធ្វើរបាយការណ៍ពីថ្នាក់ក្រោមមកថ្នាក់លើមិនច្បាស់លាស់ទើបបណ្តាលឱ្យគ្រួសារអាខ្មៅ និងខ្លួនវាស្លាប់ទាំងអយុត្តិធម៌ ដោយមិនអស់ចិត្ត ហើយមុននឹងដាច់ខ្យល់ស្លាប់ អាខ្មៅវាបានស្រែកទ្រហោយំ និងទាមទារយុត្តិធម៌ពីយើងទាំងអស់គ្នា ដែលជាអ្នកគ្រប់គ្រងលើឋានទាំងបីនេះ។ ជាពិសេសទៀតនោះ អាខ្មៅ មីត្នោត និងអាតឿ គឺជាឆ្កែ ដែលប្រជារាស្ត្រនៅឋានកណ្តាលក្នុងតំបន់ទន្លេមេគង្គស្រលាញ់ជាទីបំផុត ដោយអំពើយកអាសារបស់វា ហើយសំលេង

ស្រែករកភាពយុត្តិធម៌របស់អាខ្មៅត្រូវបានប្រជារាស្ត្រដឹងគ្រប់ៗគ្នា ហើយប្រជារាស្ត្រខ្លះទៀត បានជួយស្រែករកយុត្តិធម៌ជំនួសអាខ្មៅផងដែរ ។ ដូច្នេះ ដើម្បីកុំឱ្យមានការតវ៉ាបះបោរពីសំណាក់សត្វ និងមនុស្សនៅឋានកណ្តាល និងព្រលឹងក្រុមគ្រួសារអាខ្មៅ និងជាពិសេសដើម្បីលុបលាងកំហុសរបស់យើង និងបង្ហាញឱ្យគ្រប់ឋានឃើញថា យើងជាឋានល្អជាងគេជានិច្ចនោះ ។ យើង( ព្រះឥន្ទ្រា) ត្រាស់បង្គាប់បញ្ជាឱ្យទេវតាកិត្តិយសផ្តល់កិត្តិយសដល់គ្រួសារអាខ្មៅ ។ ទេវតាកិត្តិយស យល់ថា អាខ្មៅ និងគ្រួសាររបស់វាស្រលាញ់កិត្តិយស និងឈ្មោះល្អណាស់ ដូច្នេះបើអញផ្តល់កិត្តិយសល្អដល់វា ព្រលឹងគ្រួសាររបស់វានឹងស្ងប់ ហើយឈប់តវ៉ារឿងអយុត្តិធម៌នេះទៀតហើយ ។ គិតឃើញដូច្នេះ ទេវតាកិត្តិយសក៏ជប់ឱ្យសាកសពមីត្នោត និងអាតឿ ដែលស្លាប់ទាំងអាតឿជិះលើខ្នងមីត្នោតនោះឱ្យក្លាយទៅជាថ្មមានរូបរាងដូចឆ្កែម៉ែកូនទាំងពីរបេះបិត ហើយនៅត្រើយម្ខាងទៀតដែលអាខ្មៅយំសោកបោកខ្លួនទាល់តែស្លាប់នេះឱ្យឈ្មោះថា កំពង់ឆ្កែខ្មៅ តាំងពីសម័យនោះមក លុះដល់សម័យក្រោយមក សង្គមមានការរីកចំរើន ដូច្នេះការហៅឈ្មោះក៏ប្រែប្រួលទៅតាមការរីកចំរើនដែរ ហើយអ្នកភូមិបានប្រែក្លាយពីការហៅថា កំពង់ឆ្កែខ្មៅ មកជាកំពង់ឆ្កែវិញ ព្រោះវាមានលក្ខណៈខ្លីងាយស្រួលហៅជាង ។

ស្រាវជ្រាវ និងសរសេរ : លោក តឹក វណ្ណារ៉ា

ប្រធានកម្មវិធីទំនាក់ទំនង និងស្រាវជ្រាវ

នៃសមាគមថែរក្សាបរិស្ថាន និងវប្បធម៌

កោះស្រឡៅ, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨

# ១៩. ពូជស្រូវខ្មែរលើ[១]

បងប្អូនជនជាតិដើមភាគតិច ដែលកំពុងមានវត្តមាន និងរស់នៅភូមិភាគឥសាន្តនៃប្រទេសកម្ពុជាយើង គឺប្រកបរបរចិញ្ចឹមជីវិតដោយពឹងផ្អែកលើការធ្វើកសិកម្មពនេចរ (ចំការវិលជុំ) និងធនធានធម្មជាតិ មានផល និងអនុផលព្រៃឈើ ព្រមទាំងធនធានទឹក ដែលមានមុខរបរនេសាទជាស្នូល។ ធនធានធម្មជាតិបានចូលរួមយ៉ាងសកម្មក្នុងការកំនត់មុខរបរ និងសង្គមវប្បធម៌របស់បងប្អូនជនជាតិយើង។ ស្រូវចំការ និងស្រូវវស្សា គឺជាមុខរបរមួយដ៏សំខាន់ ក្នុងចំណោមមុខរបរដែលបងប្អូនជនជាតិដើមភាគតិចមាន។ ការធ្វើស្រែចំការរបស់បងប្អូនជនជាតិដើមភាគតិច មានលក្ខណៈខុសគ្នាជាមួយនឹងអ្នកស្រុកក្រោម (ប្រជាជនដែលរស់នៅទំនាបកណ្តាលនៃប្រទេស) ទាំងពីរបៀបធ្វើ បច្ចេកទេស និងប្រភេទពូជស្រូវ។ លក្ខណៈប្លែកគ្នាដូច្នេះ គឺបណ្តាលមកពីភាពខុសគ្នារវាងទីតាំងភូមិសាស្ត្រ គុណភាពដី បច្ចេកទេស និងសង្គមវប្បធម៌។

ខ្មែរលើ (អ្នកស្រុកលើ ឬជនជាតិដើមភាគតិច)[២] ពួកគាត់បានប្រើប្រាស់ពូជស្រូវ៣ប្រភេទ គឺស្រូវស្រាល ស្រូវកណ្តាល និងស្រូវធ្ងន់។ ពូជស្រូវទាំងនោះមានដូច

---

[១] ខ្មែរលើនៅក្នុងអត្ថបទនេះ គឺនិយាយសំដៅទៅលើបងប្អូនជនជាតិដើមភាគតិច ដែលកំពុងរស់នៅភូមិភាគឥសាន្តនៃប្រទេសកម្ពុជាមានខេត្តស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី។

[២] ការហៅថា ខ្មែរលើ ឬអ្នកស្រុកលើ ឬជនជាតិដើមភាគតិច គឺជាការហៅសំដៅទៅលើប្រជាជនរស់នៅតំបន់ភ្នំ និងតំបន់ខ្ពង់រាបនៃភូមិភាគឥសាន្តនៃប្រទេសកម្ពុជា។ ការហៅបែបនេះ គឺមិនមែនជាការរើសអើង ឬការបែងចែកខ្មែរទៅជាពួកអ្វីនោះទេ ប៉ុន្តែវាគ្រាន់តែជាការកត់សំគាល់របស់អ្នកនិពន្ធទៅលើសង្គមវប្បធម៌ និងការប្រើប្រាស់ពាក្យដែលអ្នកស្រុកគាត់ បានប្រើប្រាស់នាពេលកន្លងមកតែប៉ុណ្ណោះ។

ខាងក្រោម ៖

**១. ពូជស្រូវស្រាល ៖**

ស្រូវស្រាល ជាប្រភេទស្រូវដំណាប និងស្រូវដែលមានរយៈពេលពីចន្លោះ ៣ ទៅ៤ខែទទួលបានផល។ ប្រភេទស្រូវស្រាល ដែលជនជាតិដើមភាគតិចចូលចិត្តដាំ មានដូចជា ស្រូវសែនពិដោរ, ស្រូវអ៊ីអ៊ែ, ស្រូវនាងខាត់, ស្រូវដំណើបឡាវ, ស្រូវក្រហមស្រាល, ស្រូវកួយ, ស្រូវដំណើបខ្មៅ, ស្រូវដំណើបផ្កាម្លិះ និងស្រូវដំណើបធាងចេក។

**ស្រូវសែនពិដោរ** ៖ ជាប្រភេទស្រូវស្រាល មានកំពស់៤តឹក និងការដាំមានរយៈពេល៤ខែ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយទន់ ហូបឆ្ងាញ់ ជាពិសេសដាំឆាប់ឆ្អិនបានហូប ហើយប្រភេទស្រូវនេះមានគួរខ្លី សង្កីអង្ខើលពិបាកប្រមូលផល។

**ស្រូវអ៊ីអ៊ែរ** ៖ ជាប្រភេទស្រូវស្រាល មានកំពស់ពី៣ទៅ៤តឹក និងការដាំ-មានរយៈពេល៤ខែ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយរឹង អាចធ្វើនំបញ្ចុកបានល្អ ដាំឆាប់ឆ្អិនបានហូប ។ ប្រភេទស្រូវនេះ មានគួរខ្លី ដើមខ្លី ពិបាកប្រមូលផល។

**ស្រូវនាងខាត់**៖ ជាប្រភេទស្រូវស្រាល មានកំពស់១ម៉ែត្រ៣តឹក និងការ-ដាំមានរយៈពេល៤ខែ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយទន់ក្រអូប។ ប្រភេទស្រូវនេះ មានគួរវែង ធន់នឹងភាពរាំងស្ងួត ហើយស្រូវនេះចូលចិត្តដីរដីគោក ប៉ុន្តែស្រូវនេះ មានស្រកីរង្វើលមិនធន់នឹងទឹកលិចជ្រៅ។

**ស្រូវដំណើបឡាវ**៖ ជាប្រភេទស្រូវស្រាល មានកំពស់១ម៉ែត្រ៩តឹក និង-ការដាំមានរយៈពេល៤ខែ ហើយត្រូវគ្រប់ស្ថានភាពដី។ ហើយអង្ករនៃប្រភេទស្រូវនេះ

មានលក្ខណៈបាយទន់ក្រអូប។ ប្រភេទស្រូវនេះ មានកួរវែង ធន់នឹងភាពរាំងស្ងួត ស្រកីញឹក អង្ករល្អ និងដើមរឹង ប៉ុន្តែស្រូវនេះ មិនធន់នឹងទឹកលិចជ្រៅ។

**ស្រូវក្រហមស្រាល**: ជាប្រភេទស្រូវស្រាល មានកំពស់១ម៉ែត្រ២តឹក និងការដាំមានរយៈពេល៤ខែ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយទន់ក្រអូប។ ប្រភេទស្រូវនេះ មានកួរវែង ស្រកីញឹក ហើយអង្ករមិនបាក់ ប៉ុន្តែស្រូវនេះ មានសភាពទន់ មិនធន់នឹងទឹកលិចជ្រៅ។

**ស្រូវក្អួយ**: ជាប្រភេទស្រូវស្រាល មានកំពស់១ម៉ែត្រ២តឹក និងការដាំ-មានរយៈពេល៤ខែ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយទន់ក្រអូប។ ប្រភេទស្រូវនេះ មានកួរវែង ស្រកីញឹក ដើមរឹង មិនរើសដី ប៉ុន្តែស្រូវនេះ មានសភាពមិនធន់នឹងទឹកលិចជ្រៅ។

**ស្រូវដំណើបខ្មៅ** : ជាប្រភេទស្រូវស្រាល មានកំពស់១ម៉ែត្រ និងការ-ដាំមានរយៈពេល៤ខែ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយទន់ក្រអូប។ ប្រភេទស្រូវនេះ មានកួរវែង ស្លុងស្រែទឹក ស្រកីញឹក ដើមរឹងមានពណ៌ស្វាយ ប៉ុន្តែស្រូវនេះ មានសភាពមិនធន់នឹងទឹកលិចជ្រៅ។

**ស្រូវដំណើបផ្កាម្លិះ** : ជាប្រភេទស្រូវស្រាល មានកំពស់១ម៉ែត្រ និងការដាំមានរយៈពេល៣ខែ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយទន់ក្រអូប។ ប្រភេទស្រូវនេះ មានកួរខ្លីល្មម ស្លុងស្រែគោក ស្រកីញឹក ដើមរឹង អង្ករល្អ មិនរើសដី ប៉ុន្តែស្រូវនេះ មានសភាពមិនធន់នឹងទឹកលិចជ្រៅ។

**ស្រូវដំណើបធានចេក**: ជាប្រភេទស្រូវស្រាល មានកំពស់១ម៉ែត្រ៣តឹក និងការដាំមានរយៈពេល៣ខែ ហើយប្រភេទស្រូវនេះ មានកួរវែង ដើមរឹង និងអង្កររលូន ប៉ុន្តែស្រូវនេះ មានស្រកីអង្វើល និងឆាប់រោយគ្រាប់។

## ២. ស្រូវកណ្ដាល ៖

ស្រូវកណ្ដាល ជាប្រភេទស្រូវដំណាប ខ្សាយ និងស្រូវដែលមាន-រយៈពេលពីចន្លោះ ៥ ទៅ៦ខែទទួលបានផល។ ប្រភេទស្រូវកណ្ដាល ដែលជនជាតិដើមភាគតិចចូលចិត្តដាំ មានដូចជា ស្រូវចង្កោមសរ, ស្រូវក្រមួនសរ, ស្រូវសំបុកអង្រ្កង, ស្រូវផ្កាដូង, ស្រូវផ្កាខ្ញី, ស្រូវប្រាំតោន, ស្រូវល្ងាក់ ឬស្រូវស្អិន, ស្រូវដំណើបថៃ ស្រូវដំណើបក្រអូបទ្បារ, ស្រូវដំណើបទឹកឃ្មុំ, ស្រូវដំណើបដំបូក, ស្រូវដំណើប-ឈាមអន្ទង់, ស្រូវដំណើបក្រមួន, ស្រូវដំណើបពងទា, ស្រូវក្រចេះ, ស្រូវដំណើប-កូនឃ្មុំ, ស្រូវផ្ការំដួល, ស្រូវតាឡយ, ស្រូវផ្ការំដួល និងស្រូវនាងកង។

**ស្រូវចង្កោមសរ** ៖ ជាប្រភេទស្រូវកណ្ដាល មានកំពស់១ម៉ែត្រ ៣តឹក និងការដាំមានរយៈពេល៥ខែ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយទន់ល្មម។ ប្រភេទស្រូវនេះ មានគួរវែង ស្រកីញឹក អង្ករលួនល្អ ប៉ុន្តែស្រូវនេះមានដើមទន់ មិនធន់នឹងទឹកជំនន់លិចជ្រៅ ហើយប្រមូលផលយឺត និងមានគ្រាប់រោយ។

**ស្រូវក្រមួនសរ** ៖ ជាប្រភេទស្រូវកណ្ដាល មានកំពស់១ម៉ែត្រ ២តឹក និងការដាំមានរយៈពេល៥ខែ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយទន់ល្មម។ ប្រភេទស្រូវនេះ មានស្រកីញឹក អង្កររលួនល្អ និងទទួលបានផលច្រើន ប៉ុន្តែស្រូវនេះមានដើមទន់ ប្រមូលផលមិនទាន់ដាច់សង្ក រោយគ្រាប់ និងមិនធន់នឹងទឹកជំនន់។

**ស្រូវសំបុកអង្រ្កង** ៖ ជាប្រភេទស្រូវកណ្ដាល មានកំពស់១ម៉ែត្រ និងការដាំមានរយៈពេល៥ខែ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយរឹង ហូប-ចំណេញ ។ ប៉ុន្តែប្រភេទស្រូវនេះ មានស្រកីគ្រាប់រង្វើល និងទុំញោសពេក និងរោយ

គ្រាប់ស្រូវ។

**ស្រូវផ្កាដូង** : ជាប្រភេទស្រូវកណ្ដាល មានកំពស់១ម៉ែត្រ ២តឹក និងការ-ដាំមានរយៈពេល៥ខែ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយទន់ឆ្ងាញ់។ ប្រភេទស្រូវនេះ មានស្រកីញឹក គួរវែង ផ្ដល់ផលច្រើន ប៉ុន្ដែស្រូវនេះឆាប់រោយគ្រាប់ប្រមូលផលមិនទាន់។

**ស្រូវផ្កាខ្ញី** : ជាប្រភេទស្រូវកណ្ដាល មានកំពស់១ម៉ែត្រ ៣តឹក និងការដាំមានរយៈពេល៥ខែហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយទន់ អង្ករលក់បានតំលៃខ្ពស់។ ប្រភេទស្រូវនេះ មានគួរវែង ទទួលបានផលច្រើន ប៉ុន្ដែស្រូវនេះមានដើមទន់មិនធន់នឹងទឹកជ្រៅ។

**ស្រូវច្រាំគោន** : ជាប្រភេទស្រូវកណ្ដាល មានកំពស់១ម៉ែត្រ ២តឹក និង-ការដាំមានរយៈពេល៥ខែ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយទន់ល្មម។ ប្រភេទស្រូវនេះ មានស្រកីញឹក និងអាចដាំបាននៅតាមស្រែជំរៅ ប៉ុន្ដែស្រូវនេះមានស្រកីរួតពិបាកជំរុះគ្រាប់។

**ស្រូវល្វាក់ (ស្អិន)** : ជាប្រភេទស្រូវកណ្ដាល មានកំពស់១ម៉ែត្រ ២តឹក និងការដាំមានរយៈពេល៥ខែ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយទន់ល្មម។ ប្រភេទស្រូវនេះ មានសភាពធន់នឹងទឹកលិចជ្រៅ និងគ្រោះរាំងស្ងួត ប៉ុន្ដែស្រូវនេះមានគួរខ្លី ស្រកីរង្វើល។

**ស្រូវដំណើបថៃ** : ជាប្រភេទស្រូវកណ្ដាល មានកំពស់១ម៉ែត្រ ២តឹក និងការដាំមានរយៈពេល៥ខែ។ ប្រភេទស្រូវនេះ មានស្រកីញឹក គួរវែង និងទទួលបានផលច្រើន ប៉ុន្ដែស្រូវនេះមិនធន់នឹងទឹកជំនន់ ឬទឹកជ្រៅ។

**ស្រូវដំណើបក្រអូបឡាវ** ៖ ជាប្រភេទស្រូវកណ្ដាល មានកំពស់១ម៉ែត្រ ២តឹក និងការដាំមានរយៈពេល៥ខែ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយក្រអូបឆ្ងាញ់។ ប្រភេទស្រូវនេះមានគួរវែង អង្ករក្រអូបឆ្ងាញ់ និងធន់នឹងភាពរាំងស្ងួត ប៉ុន្តែស្រូវនេះមានស្រកីរង្វើល និងឆាប់រោយគ្រាប់។

**ស្រូវដំណើបទឹកឃ្មុំ** ៖ ជាប្រភេទស្រូវកណ្ដាល មានកំពស់១ម៉ែត្រ ២តឹក និងការដាំមានរយៈពេល៥ខែ។ ប្រភេទស្រូវនេះ មានស្រកីញឹក គួរវែង និងទទួលបានផលច្រើន ប៉ុន្តែស្រូវនេះមានសភាពមិនធន់នឹងភាពរាំងស្ងួតទេ។

**ស្រូវដំណើបដំបូក** ៖ ជាប្រភេទស្រូវកណ្ដាល មានកំពស់១ម៉ែត្រ ២តឹក និងការដាំមានរយៈពេល៥ខែ។ ប្រភេទស្រូវនេះមានស្រកីញឹក ធន់នឹងភាពរាំងស្ងួត។ ប៉ុន្តែស្រូវនេះមិនធន់នឹងទឹកជ្រៅ និងទឹកជំនន់ទេ។

**ស្រូវដំណើបឈាមអន្ទង់** ៖ ជាប្រភេទស្រូវកណ្ដាល មានកំពស់១ម៉ែត្រ ២តឹក និងការដាំមានរយៈពេល៥ខែ។ ប្រភេទស្រូវនេះមានគួរវែង ធន់នឹងភាពរាំងស្ងួត ប៉ុន្តែស្រូវនេះមានស្រកីរង្វើល និងឆាប់រុះរោយគ្រាប់។

**ស្រូវដំណើបក្រមួន** ៖ ជាប្រភេទស្រូវកណ្ដាល មានកំពស់១ម៉ែត្រ និង-ការដាំមានរយៈពេល៥ខែ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយទន់ល្មមក្រអូប។ ប្រភេទស្រូវនេះ មានស្រកីញឹក គួរវែង ដើមរឹង អង្ករល្អ ប៉ុន្តែស្រូវនេះមានសភាពមិនធន់នឹងទឹកលិចជ្រៅ និងទឹកជំនន់។

**ស្រូវដំណើបពងទា** ៖ ជាប្រភេទស្រូវកណ្ដាល មានកំពស់១ម៉ែត្រ និង-ការដាំមានរយៈពេល៥ខែ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយទន់។ ប្រភេទស្រូវនេះមានស្រកីញឹក ដើមរឹង អង្កររល្អ ប៉ុន្តែស្រូវនេះមានសភាពមិនធន់នឹង

ទឹកលិចជ្រៅ និងទឹកជំនន់។

**ស្រូវក្រចេះ** : ជាប្រភេទស្រូវកណ្តាល មានកំពស់១ម៉ែត្រ ២តឹក និង-ការដាំមានរយៈពេល៥ខែ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយទន់ក្រអូប។ ប្រភេទស្រូវនេះ មានគួរវែង ស្រកីញឹក ដើមរឹង មិនរើសដី ប៉ុន្តែស្រូវនេះមានសភាពមិនធន់នឹងទឹកលិចជ្រៅ និងទឹកជំនន់។

**ស្រូវដំណើបកូនឃ្មុំ** : ជាប្រភេទស្រូវកណ្តាល មានកំពស់១ម៉ែត្រ និង-ការដាំមានរយៈពេល៥ខែ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយទន់ក្រអូប។ ប្រភេទស្រូវនេះមាន គួរវែង ស្រកីញឹក ដើមរឹង និងអង្ករល្អ ប៉ុន្តែស្រូវនេះមានសភាពមិនធន់នឹងទឹកលិចជ្រៅ។

**ស្រូវផ្ការំដួល** : ជាប្រភេទស្រូវកណ្តាល មានកំពស់១ម៉ែត្រ ២តឹក និង-ការដាំមានរយៈពេល៥ខែ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយទន់ក្រអូប។ ប្រភេទស្រូវនេះ មានស្រកីញឹក ដើមវែង មិនរើសដី ប៉ុន្តែស្រូវនេះមានសភាពមិនធន់នឹងទឹកលិចជ្រៅ។

**ស្រូវតាឡយ** : ជាប្រភេទស្រូវកណ្តាល មានកំពស់១ម៉ែត្រ ២តឹក និង-ការដាំមានរយៈពេល៥ខែ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយទន់។ ប្រភេទស្រូវនេះមាន គួរវែង ដើមរឹងពណ៌ស អង្ករល្អ ប៉ុន្តែស្រូវនេះមានស្រកីរង្វើល និងមិនធន់នឹងទឹកលិចជ្រៅ។

**ស្រូវផ្ការំដួល** : ជាប្រភេទស្រូវកណ្តាល មានកំពស់១ម៉ែត្រ ២តឹក និង-ការដាំមានរយៈពេល៥ខែ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយរឹងល្មម។ ប្រភេទស្រូវនេះមានដើមរឹង និងត្រូវជាមួយស្រែដីខ្សាច់។

**ស្រូវនាងគង** : ជាប្រភេទស្រូវកណ្ដាល មានកំពស់១ម៉ែត្រ ៣តឹក និង-ការដាំមានរយៈពេល៥ខែ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយមិនរឹង មិនទន់ គឺល្មម។ ប្រភេទស្រូវនេះមានគួរវែង និងត្រូវគ្រប់ស្ថានភាពដី ប៉ុន្តែស្រូវនេះមានស្រកីរង្វើល និងទទួលបានផលតិច។

៣. **ស្រូវធ្ងន់** :

ស្រូវធ្ងន់ ជាប្រភេទស្រូវខ្សាយ និងស្រូវដែលមានរយៈពេលចាប់ពី៥ខែកន្លះឡើង ទៅទើបទទួលបានផល។ ប្រភេទស្រូវធ្ងន់ ដែលជនជាតិដើមភាគតិចចូលចិត្តដាំមានដូចជា ស្រូវហាសិបប្រាំមយ, ស្រូវប្រវឹក, ស្រូវក្រញ៉ែង, ស្រូវប្រវឹកស និងស្រូវផ្កាស្លា។

**ស្រូវហាសិបប្រាំមួយ (៥៦)** : ជាប្រភេទស្រូវធ្ងន់ មានកំពស់១ម៉ែត្រ ២តឹក និងការដាំមានរយៈពេល៦ខែ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយរឹងល្មម។ ប្រភេទស្រូវនេះមានកួរវែង ស្រកីញឹក ប៉ុន្តែស្រូវនេះមានដើមទន់ មិនធន់នឹងទឹកជំនន់លិចជ្រៅ។

**ស្រូវប្រវឹក** : ជាប្រភេទស្រូវធ្ងន់ មានកំពស់១ម៉ែត្រ ៣តឹក និងការដាំ-មានរយៈពេល៦ខែ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយរឹងល្មម។ ប្រភេទស្រូវនេះមានកួរវែង ស្រកីញឹក និងទទួលបានផលច្រើន ប៉ុន្តែស្រូវនេះមានដើមទន់ និងទឹកលិចឆាប់រលួយ។

**ស្រូវក្រញ៉ែង** : ជាប្រភេទស្រូវធ្ងន់ មានកំពស់១ម៉ែត្រ ២តឹក និងការដាំ-មានរយៈពេល៦ខែ។ ប្រភេទស្រូវនេះមានកួរវែង ដើមរឹង ស្រកីញឹកនិងអង្ករមិនបាក់ ប៉ុន្តែស្រូវនេះមានសភាពមិនធន់នឹងទឹកលិចជ្រៅ។

**ស្រូវប្របីកស** ៖ ជាប្រភេទស្រូវធ្ងន់ មានកំពស់១ម៉ែត្រ ៣តឹក និងការដាំមានរយៈពេល៥ខែកន្លះ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយរឹងល្មម។ ប្រភេទស្រូវនេះមានគួរវែង ស្រកីញឹក និងទទួលបានផលច្រើន ប៉ុន្តែស្រូវនេះមានដើមទន់ មិនធន់នឹងទឹកលិចជ្រៅ។

**ស្រូវផ្កាស្លា** ៖ ជាប្រភេទស្រូវធ្ងន់ មានកំពស់១ម៉ែត្រ ៣តឹក និងការដាំមានរយៈពេល៥ខែកន្លះ ហើយអង្ករនៃប្រភេទស្រូវនេះមានលក្ខណៈបាយទន់។ ប្រភេទស្រូវនេះមានដើមរឹង ធន់នឹងទឹក និងបែកគុម្ពធំ ប៉ុន្តែស្រូវនេះមានស្រកីរង្វើល គួរខ្លី និងប្រសិនបើយើងដាំលើស្រែគោកមិនសូវទទួលបានផល។

ដើម្បីធ្វើការកែប្រែចរិតធ្វើកសិកម្មបែបប្រពៃណី (ចំការពនេចរ, ចំការស្រែធម្មតាពឹងផ្អែកលើទឹកភ្លៀង និងស្រែចំការតាមទីជំរាលនៃជ្រលងភ្នំ និងទំនាបភ្នំ) ដែលជាប្រភេទកសិកម្មសំរាប់ផ្គត់ផ្គង់ត្រឹមតែតំរូវការក៏រិតគ្រួសារ មកធ្វើកសិកម្មបែបប្រពលវប្បកម្ម និងកសិកម្មទំនើប ដើម្បីផ្គត់ផ្គង់ចង្វាក់ផលិតកម្មកសិកម្ម ដែលអាចបំរើឱ្យផលប្រយោជន៍សេដ្ឋកិច្ចទាំងក៏រិតគ្រួសារ សហគមន៍ និងសេដ្ឋកិច្ចខ្នាតធំ ជាដំបូង យើងត្រូវធ្វើការផ្លាស់ប្តូរអត្តចរិត ការយល់ឃើញ ទំលាប់ និងអាកប្បកិរិយារបស់បងប្អូនជនជាតិដើមភាគតិចសិន តាមរយៈផ្តល់ជាវគ្គបណ្តុះបណ្តាលកសិកម្ម និងវគ្គជំនាញផលិតកម្មកសិកម្មផ្សេងៗ និងជាពិសេសយើងត្រូវធ្វើជាស្រែគំរូ សំរាប់ឱ្យពួកគាត់មើលឃើញជាក់ស្តែង សំរាប់ពួកគាត់អាចយកទៅអនុវត្តនៅក្នុងភូមិ ស្រុក និងតំបន់របស់ពួកគាត់បាន។ ស្រែគំរូ គួរធ្វើឡើងទៅតាមភូមិ និងតំបន់នីមួយៗ ឱ្យស្របតាមទីតាំងភូមិសាស្ត្រ ប្រភេទពូជ និងជំនាញ។ នៅពេលដែលសហគមន៍ឃើញថា ពូជថ្មីអាចទទួលបានផលច្រើន ចំណេញពេលវេលា និងថវិកា ហើយ

ជាពិសេស បែបបទនៃការបញ្ចូលកសិកម្មទំនើបនោះ មិនសូវធ្វើឱ្យប៉ះពាល់ដល់ប្រពៃណីទំនៀមទំលាប់ដើមរបស់ជនជាតិនីមួយៗ នោះពួកគាត់នឹងទទួលយក និងអាចអនុវត្តបាន ប្រកបដោយភាពជោគជ័យ។ ដូច្នេះអ្នកធ្វើផែនការទាំងឡាយគួរគិតពីសង្គមវប្បធម៌ នៃជនជាតិដើមភាគតិចនីមួយៗ និងរបៀបបញ្ចូលគ្នារវាងបច្ចេកទេសកសិកម្មបែបប្រពៃណី និងកសិកម្មបែបទំនើប ដែលអាចធានាឱ្យមាននិរន្តរភាពជីវភាពរស់នៅ។

---

**សំគាល់** : ការស្រាវជ្រាវខាងលើធ្វើឡើងក្នុងរយៈពេល៤៥ថ្ងៃ ដោយធ្វើការសំភាសន៍ផ្ទាល់ជាមួយជនជាតិដើមភាគតិចនៅក្នុងខេត្តស្ទឹងត្រែង និងរតនគិរីចំនួន២៥នាក់ ក្នុងនោះមានស្ត្រីចំនួន៨នាក់ និងចុះពិនិត្យជាក់ស្តែងចំពោះប្រភេទស្រូវនៅក្នុងភូមិចំនួន ៦ គឺភូមិរំពាត់នៅទន្លេសេសាន ភូមិក្បាលរមាស ទន្លេស្រែពក និង-ភូមិអូរចាយ ទន្លេសេកុង ក្នុងខេត្តស្ទឹងត្រែង ហើយនៅក្នុងភូមិកាចូន ភូមិផាកណាម និងភូមិកាលីម។ ដូច្នេះសូមឱ្យមានការសិក្សាស្រាវជ្រាវបន្ថែមទៀតឱ្យបានច្បាស់លាស់ ដើម្បីជួយកែប្រែពីការធ្វើកសិកម្មបែបប្រពៃណីសំរាប់តែផ្គត់ផ្គង់គ្រួសារមកជាកសិកម្មទំនើប សំរាប់ផ្គត់ផ្គង់ក៏រិតគ្រួសារផង និងបែបផែនសេដ្ឋកិច្ចផង ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅ និងគុណភាពជីវិតរបស់បងប្អូនជនជាតិដើមភាគតិចឱ្យស្របទៅតាមការរីកចំរើននៃប្រទេសជាតិ និងសមស្របទៅតាមយុគសម័យសាកលភាវូបនីយកម្ម។

ស្រាវជ្រាវ និងសរសេរ : លោក តឹក វណ្ណារ៉ា
ប្រធានកម្មវិធីទំនាក់ទំនង និងស្រាវជ្រាវ
នៃសមាគមថែរក្សាបរិស្ថាន និងវប្បធម៌
ស្ទឹងត្រែង, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៨

## ២១. សំលេងទឹកហូរ

សំលេងទឹកហូរនារាត្រី    គាក់តែងតន្ត្រីតាមធម្មជាតិ[1]
កំដរអារម្មណ៍ដល់មនុស្សជាតិ    ឱ្យបានចាកឃ្លាតអស់ទុក្ខព្រួយ ។
សំលេងទឹកហូរខ្យល់ត្រជាក់    ធ្វើឱ្យយើងហាក់គិតលើកស្ទួយ
ធនធានទន្លេជាតិតែមួយ    ដុះលាស់ជាត្រួយស្ទួយជីវភាព ។
សំលេងទឹកហូរមិនចេះហត់    ហូរសែនប្រាកដខ្ពស់ទៅទាប
ធ្វើឱ្យប្រជារស់ជ្រួតជ្រាប    ធនធានខ្ពង់រាបខ្សែទឹកហូរ ។
សំលេងទឹកហូរខ្សឹបប្រាប់យើង    ឱ្យខិតខំឡើងធ្វើស្រែប្តូរ
ទៅតាមរដូវដូចទឹកហូរ    ផលស្រូវជន់ជោរហូបមិនខ្វះ ។
សំលេងទឹកហូរ ហូរមិនឈប់    ហូរតាំងព្រលប់ ដល់ថ្ងៃរះ
បញ្ជាក់ប្រាប់យើងឱ្យរូតរះ    ខិតខំជំនះរាល់ឧបសគ្គ ។
សំលេងទឹកហូរជាតន្ត្រី    បំពេគ្រប់វ័យរសាយជាក់
អស់ទុក្ខកង្វល់ដែលថ្មាំងថ្នាក់    ចេះគិតជ្រៅរាក់សាមគ្គីខ្ពស់ ។
សំលេងទឹកហូរស្ងួររងំ    ប្រៀបបានដូចឃ្មុំផ្គុំចេះរស់
ក្រេបលំអងផ្កាដ៏សែនស្រស់    យកមកព្រំប្រោះរស់សំបុក ។
សំលេងទឹកហូរស្នូរឈ្ងូឈ្ងូ    ហូរជាគំរូមិនគំហុក

---

[1] ស្នូរទឹកហូរនៃល្បាក់ទឹកនានានៅតាមដងទន្លេមេគង្គ សេសាន សេកុង និងស្រែពក គឺជាតន្ត្រីធម្មជាតិ ដែលអាចរំសាលដល់អារម្មណ៍ទុក្ខព្រួយទាំងឡាយរបស់សត្តនិករនៅក្នុងលោកនេះ ជាពិសេសអ្នកដែលមានវិបត្តផ្លូវចិត្ត។ តន្ត្រីធម្មជាតិនេះ កាន់តែពិរោះ និងមានភាពកាន់តែស្រស់បំព្រងថែមទៀតនារាត្រីច័ន្ទពេញវង់។

សន្ទឹមៗពេញជង្ហុក
រស់នៅពេញមុខសមកិត្តិយស ។
សំលេងទឹកហូរ ហូរទៅឆ្ងាយ
នឹកឡើងសែនស្តាយការងារហួស
មិនចង់ឃ្លាតទេកន្លែងរស់
ឃ្លាតទៅទាំងប្រេះចិត្តអាល័យ ។
សំលេងទឹកហូរប៉ះផ្ទាំងថ្ម
ជាតន្ត្រីករចិត្តប្រពៃ
តស៊ូអត់ធ្មត់រស់មានន័យ
រស់ពិសម័យចិត្តកីឡា ។
សំលេងទឹកហូរពេលខ្យល់ស្ងប់
ធ្វើឱ្យចិត្តជាប់សែនជ្រះថ្លា
រូបយើងទាំងទ្វេរពីរហត្ថា
ឃ្លាតតែកាយាចិត្តជាប់នៅ ។
សំលេងទឹកហូរដាស់កសិករ
ឱ្យខំបន្តគិតឱ្យជ្រៅ
ធ្វើស្រែឱ្យបានច្រើនរដូវ
ជីវភាពរស់នៅនឹងធូរធារ ។
សំលេងទឹកហូរប្រាប់វេលា
ប្រាប់ដល់គ្រប់គ្នាកុំរុញរា
ខិតខំការពារទឹកគង្គា
ឱ្យបានល្អជារៀងរហូត ។

តែងដោយៈ លោក តឹក វណ្ណារ៉ា
មន្ត្រីគ្រប់គ្រងកម្មវិធីទំនាក់ទំនង
និងស្រាវជ្រាវ
សមាគមថែរក្សាបរិស្ថាន និងវប្បធម៌
ស្ទឹងត្រែង. ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ
២០០៨





ទិដ្ឋភាពផ្ទះ និងចំការពនេចរ(ចំការវិលជុំ) របស់ជនជាតិគ្រឹងនៅភូមិឃួន ឃុំផាកណាម ស្រុកវើនសៃ ខេត្តរតនគិរី

បោះពុម្ពផ្សាយដោយសមាគមថែរក្សាបរិស្ថាន និងវប្បធម៌

ក្រោមជំនួយឧបត្ថម្ភថវិកាពីអង្គការ

**OXFAM AMERICA, FORUMSYD និង SSNC**

**ចំនួន ៧៥៥ ក្បាល**

Published by Culture and Environment Preservation Association (CEPA) with financial support from Oxfam America, ForumSyd and SSNC

755 Copies

រក្សាសិទ្ធិដោយសមាគមថែរក្សាបរិស្ថាន និងវប្បធម៌ (ស.ថ.ប.វ)

Copyright by: Culture and Environment Preservation Association (CEPA)

បោះពុម្ពដោយ : រោងពុម្ព ភីរ៉ូ ២០០៨ ភ្នំពេញ កម្ពុជា

Printed by : PIRO Printing 2008 Phnom Penh, Cambodia.

# “ការស្រាវជ្រាវដោយអ្នកភូមិ គឺជាចំនុចគន្លឹះ ដ៏សំខាន់មួយសំរាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព”


| | | |
|---|---|---|
| អាស័យដ្ឋាន | : | ផ្ទះលេខ ៥៩ ផ្លូវលេខ ១៥៦ សង្កាត់ ផ្សារដេប៉ូ១ ខណ្ឌទួលគោក ភ្នំពេញ |
| ទូរស័ព្ទ និងទូរសារ | : | ០២៣ ៨៨១ ៦១៣, ០២៣ ៣៦៩ ១៧៦ |
| ទូរស័ព្ទចល័ត | : | ០១២ ៧៩៣ ៤៨៩, ០១២ ៨៩៥ ៦២៤ |
| ប្រអប់សំបុត្រ | : | P.O.Box: 1486, CCC Box: 357 |
| សារអេឡិចត្រូនិច | : | tek@cepa-cambodia.org<br>cepa@cepa-cambodia.org |
| គេហទំព័រ | : | www.cepa-cambodia.org |



ISBN-9789995092313

9 789995 092313